ការណែនាំងាយៗ -ពីគ្រាប់ពូជរហូតកើតជាដើមឈើ

# FARMERS' TREE PLANTING MANUAL

A Practical Guide - From Seed to Tree



Preparation and Printing Supported by:

Cambodia-EU

# សេចក្តីថ្លែងអំណរគុណ

សៀវភៅ "**បច្ចេកទេសដាំឈើសំរាប់កសិករ**" នេះជាសមិទ្ធិផលថ្មីមួយនៃការងារផ្សព្វផ្សាយព្រៃឈើរបស់នាយកដ្ឋានរុក្ខា-ប្រមាញ់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ជោគជ័យក្នុងដំណើរការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងទៅលើកិច្ចសហប្រតិបត្តិការ និង ការចូលរួមរបស់ បុគ្គល និងស្ថាប័នជាច្រើន។ ដើម្បីកត់ត្រាទុកនូវវិភាគទានដ៏មានតម្លៃទាំងនេះនាយកដ្ឋានរុក្ខា-ប្រមាញ់ សូមថ្លែងអំណរគុណចំពោះក្រុមការងាររៀបចំសៀវភៅ រួមមានលោក នុព សុធា លោក យៀង អៀងគិច លោក ប៉ុល ចាន់ថា លោក សៀង ស្រ៊ុន លោក អ៊ី ឈាងម៉េង លោក សូ ធា លោក ឡុង ប៊ុង និង លោក ហុង គីមហ៊ាន ដែលបានខិតខំស្រាវជ្រាវ ចងក្រង និង រចនារូបភាព ធ្វើឱ្យសៀវភៅនេះបានលេចជារូបរាងឡើងប្រកបដោយអត្ថប្រយោជន៏សំរាប់វិស័យព្រៃឈើ ក៏ដូចវិភាគទានចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទកម្ពុជា។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Jürgen Fichtenau ជំនាញការផ្នែកផ្សព្វផ្សាយ និង សហគមន៍ព្រៃឈើនៃគំរោងសហប្រតិបត្តិការវិស័យព្រៃឈើកម្ពុជា-អាល្លឺម៉ង់ លោក Arvid Sloth ទីប្រឹក្សានៃគំរោង គ្រាប់ពូជឈើកម្ពុជា និង លោក Minoru Arai ជំនាញការបណ្តុះបណ្តាលនៃគំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ ដែលបានចូលរួមផ្តល់ការពិគ្រោះយោបល់ដ៏មានតម្លៃនានាក្នុងដំណើរការរៀបចំសៀវភៅនេះ។

សូមថ្លែងអំណរគុណ ចំពោះ លោក លិ វុឌ្ឍី លោក វន មុនិន្ទ លោក ឌី សុភី និង លោក ឃន សារ៉េត ដែលបានជួយផ្តល់នូវចំណេះដឹងពីបទពិសោធន៍ និងឯកសារមួយចំនួនដល់ការចងក្រង។

សូមសំដែងនូវកតញ្ញូតាធម៌ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ GTZ, DANIDA JICA, PRASAC II Kompong Speu ដែលបានផ្តល់ការឧបត្ថម្ភដល់ការចងក្រង និង បោះពុម្ពសៀវភៅនេះ ។

នាយកដ្ឋានរុក្ខា-ប្រមាញ់ក៏សូមសំដែងអំណរគុណជាពិសេសចំពោះថ្នាក់ដឹកនាំនាយកដ្ឋាន ប្រធាន អនុប្រធាន អង្គភាពក្រោមឱវាទ និង មន្ត្រីរាជការនៃនាយកដ្ឋានរុក្ខា-ប្រមាញ់ ដែលបានផ្តល់ភាពងាយស្រួល ជំរុញលើកទឹកចិត្ត ដឹកនាំអង្គប្រជុំពិគ្រោះយោបល់ និង ផ្តល់គំនិតកែលំអលើសេចក្តីព្រាងសៀវភៅបច្ចេកទេសដាំឈើសំរាប់កសិករនេះ រហូតដល់សៀវភៅនេះត្រូវបានរៀបចំចប់សព្វគ្រប់ និង បោះពុម្ពផ្សព្វផ្សាយនាពេលនេះ ។

# បុព្វកថា

ព្រៃឈើមានចំណោងទាក់ទងផ្ទាល់ជាមួយជីវិតនៅលើភពផែនដីនេះ ។ ព្រៃឈើគឺជាបញ្ហាសកលសំរាប់សង្គមមនុស្សទាំងមូល ។ ដូច្នេះក្នុងកិច្ចការពារវិស័យព្រៃឈើត្រូវមានការចូលរួមជាចាំបាច់ពីគ្រប់ភាគីទាំងអស់ ជាពិសេសសហគមន៍មូលដ្ឋាន ដែលជាកំលាំងចលករសំខាន់បំផុត និង មានឥទ្ធិពលដ៏ខ្លាំងក្លា។ សៀវភៅ "**បច្ចេកទេសដាំឈើសំរាប់កសិករ**" ដែលបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយបច្ចេកទេសដាំឈើ ដែលមានលក្ខណៈងាយស្រួលយល់សំរាប់ជំនួយឱ្យការងាររបស់អ្នកផ្សព្វ-ផ្សាយនៅមូលដ្ឋាន និង សំរាប់ការស្វែងយល់ពីបច្ចេកទេសរបស់អ្នកមានបំណងដាំឈើទាំងឡាយមានៈ កសិករ ផ្នែកឯកជន សាលារៀន វត្តអារាម កងកំលាំងប្រដាប់អាវុធ ។ល។ ការចងក្រងបានដកស្រង់យកបច្ចេកទេសពីឯកសារបច្ចេកទេសមួយចំនួនរបស់ជាតិ និង អន្តរជាតិ រួមផ្សំនឹងការផ្តល់ បទពិសោធន៏ល្អៗពីមន្ត្រីបច្ចេកទេសដែលមានបទពិសោធន៏ក្នុងការងារដាំឈើ និង សហគមន៏មកសំយោគបង្កើតជាបច្ចេកទេសមួយ ដែលមានលក្ខណៈសមស្របអាចអនុវត្តបាននៅក្នុងលក្ខខណ្ឌនៃប្រទេសកម្ពុជា។ ឯកសារនេះកសាងឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយគំរោងវិស័យព្រៃឈើកម្ពុជា-អាល្លឺម៉ង់ (CGFP/GTZ) និងមានការចូលរួមគាំទ្រថវិកាពីគំរោងគ្រាប់ពូជឈើកម្ពុជា (CTSP/DANIDA) គំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ (CBFS/JICA) និង កម្មវិធីគាំទ្រផ្នែកកសិកម្មនៅកម្ពុជា (PRASAC II ) ប្រចាំខេត្តកំពង់ស្ពឺ ។

ជាមួយការចូលរួមអនុវត្តដោយជោគជ័យតាមកម្មវិធីកំណែទំរង់វិស័យព្រៃឈើដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាលអណត្តិទី ២ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ម៉ឺងម៉ាត់ និង ឈ្លាសវៃបំផុតរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយបង្កើតបាននូវប្រក្រតីភាព និង សណ្តាប់ធ្នាប់ក្នុងវិស័យព្រៃឈើ ដែលអាចចាត់ទុកជាមូលដ្ឋានគ្រឹះសំរាប់ឈានឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនាពេលអនាគត។ ខ្ញុំសង្ឃឹមជឿជាក់ថា សៀវភៅ "**បច្ចេកទេសដាំឈើសំរាប់កសិករ**" នឹងក្លាយជាវិភាគទានដ៏មានតម្លៃសំរាប់ជំរុញលើកទឹកចិត្ត និង ផ្តល់ភាពងាយស្រួលដល់ពលរដ្ឋកម្ពុជា ដែលភាគច្រើនជាកសិករអាចចូលរួមយ៉ាងសកម្ម និង ប្រកបដោយប្រសិទ្ធភាពក្នុងសកម្មភាព វិស័យព្រៃឈើ ជាពិសេសការដាំដុះដើមឈើ ដើម្បីបង្កើនប្រភពចំណូល លើកកំពស់កំរិតជីវភាព និង គុណភាពជីវិតរស់នៅ ក៏ដូចជួយបង្កើនគំរបធនធានព្រៃឈើសំរាប់ថែរក្សាលំនឹងបរិស្ថាន ដែលជាប្រពៃណីអភិរក្សដ៏ល្អរបស់ជាតិសាសន៏កម្ពុជា។

**ទី សុគន្ធ**

**ប្រធាននាយកដ្ឋានរុក្ខា ប្រមាញ់**

# សេចក្តីផ្តើម

នៅប្រទេសកម្ពុជា ព្រៃឈើជាសរសៃឈាមក្នុងវិស័យកសិកម្ម ជាអាយុជីវិតរបស់ប្រជាកសិករ និង ជាប្រភព នៃសេដ្ឋកិច្ចជាតិ ។ តែបច្ចុប្បន្ន ធនធាននេះកំពុងរងការបាត់បង់គួរឱ្យព្រួយបារម្ភ ។ គោលនយោបាយវិស័យព្រៃឈើជាតិបានជំរុញឱ្យមានការស្តារព្រៃឈើឡើងវិញក្នុងទូទាំងប្រទេស ។ ការដាំដើមឈើគឺជាសកម្មភាពមួយសំខាន់ ហើយចាំបាច់ក្នុងការស្តារព្រៃឈើឡើងវិញ ហើយការងារដាំឈើក៏ទាមទារឱ្យមានការចូលរួមពីប្រជាពលរដ្ឋផងដែរ ពិសេសប្រជាជននៅទីជនបទ ។ ប៉ុន្តែអ្នកទាំងនោះក៏ត្រូវការចំណេះដឹងបន្ថែមពីបច្ចេកទេសដាំឈើ ។ ហេតុនេះការផ្តល់ចំណេះដឹងពីបច្ចេកទេសដាំឈើដល់ប្រជាជនជាការចាំបាច់ ។

សៀវភៅ "**បច្ចេកទេសដាំឈើសំរាប់កសិករ**" ផលិតឡើងដើម្បីឆ្លើយតបទៅនឹងតំរូវការចំណេះដឹងពីបច្ចេកទេសដាំឈើរបស់ប្រជាកសិករ ។ សៀវភៅនេះបានចងក្រងដោយខិតខំតំរូវឱ្យមានភាពងាយស្រួល និង មានលក្ខណៈសមស្របសំរាប់ប្រជាកសិករ តាមរយៈការប្រើអត្ថបទខ្លីៗគួបផ្សំរូបភាពជាជំនួយក្នុងការអធិប្បាយពី សកម្មភាពក្នុងការងារ ក្នុងន័យជួយសំរួលដល់ប្រជាកសិករដែលពុំសូវចេះអក្សរ និង ដើម្បីឱ្យការពន្យល់ពីបច្ចេកទេសនីមួយៗមានការបង្ហាញខ្លះ ។

សៀវភៅនេះបានចែកចេញជាបីជំពូកគឺៈ ផលប្រយោជន៍នៃការដាំដើមឈើ ការរៀបចំផែនការដាំឈើរបស់ កសិករ និង បច្ចេកទេសដាំឈើ ។ ជំពូកផលប្រយោជន៍នៃការដាំដើមឈើមានបង្ហាញពីប្រយោជន៍ដែលទទួលបានពី ការដាំដើមឈើដូចជា ការដាំឈើជាចំការ ការដាំឈើជុំវិញចំការ ការដាំឈើតាមដងផ្លូវ ការដាំឈើតាមទីសាធារណៈ ការដាំឈើដើម្បីការពារការហូរច្រោះ ការដាំឈើសំរាប់ជាចំណីសត្វ ការដាំឈើជាប្រព័ន្ធកសិរុក្ខកម្ម ការដាំឈើជា របាំងការពារខ្យល់ព្យុះ ទឹកជំនន់ ក្នុងអត្ថន័យជួយផ្តល់គំនិតសំរាប់ការសំរេចចិត្តជ្រើសរើសការកែច្នៃដីព្រៃ ឬ ដោះស្រាយបញ្ហាទៅតាមស្ថានភាពទីកន្លែងជាក់ស្តែងដែលកសិករបានជួបប្រទះ ដោយប្រើមធ្យោបាយដាំដើមឈើឡើងវិញ ។ ជំពូកការរៀបចំផែនការដាំឈើរបស់កសិករ មានពន្យល់ពីការងារចាំបាច់មួយចំនួនសំរាប់ត្រៀមមុននឹងឈានទៅដល់ការដាំឈើដូចជា ការវិភាគស្ថានភាពដីព្រៃ ការកំណត់តំបន់ និង បំណងដាំ ការរៀបចំក្រុមការងារ ការបង្កើនចំណេះដឹងដល់សមាជិកក្រុម ឬ សហគមន៍ និង ការស្វែងរកអ្នកគាំទ្រក្នុងការងារដាំឈើ ។ ក្នុងជំពូកបច្ចេកទេសដាំឈើមានពន្យល់ចាប់ពីការប្រមូលថែរក្សាគ្រាប់ពូជឈើ ការរៀបចំថ្នាល ការធ្វើប្រព្រឹត្តិកម្មគ្រាប់ បណ្តុះ ថែរក្សា ការរៀបចំទីកន្លែងដាំតាមបំណងដាំ រហូតដល់ការថែទាំកូនឈើដាំរួច ។

ពតិមានលំអិតពីបច្ចេកទេសធ្វើប្រព្រឹត្តិកម្មគ្រាប់តាមប្រភេទនីមួយៗ មានពន្យល់បន្ថែមនៅក្នុងតារាង ឧបសម្ព័ន្ធ ដើម្បីជាជំនួយក្នុងការអនុវត្តន៍ ។

# មាតិកា


សេចក្ដីថ្លែងអំណរគុណ ........ I

បុព្វកថា ........ II

សេចក្ដីផ្ដើម ........ III

មាតិកា ........ V

ជំពូកទី១: ផលប្រយោជន៍នៃការដាំដើមឈើ ........ ១

១-ការដាំឈើជាចំការ ........ ៣

២-ការដាំឈើធ្វើជារបងជុំវិញលំនៅដ្ឋាន និង ដាំឈើជុំវិញចំការ ........ ៤

៣-ការដាំឈើតាមដងផ្លូវ ........ ៥

៤-ការដាំឈើតាមទីសាធារណៈ ........ ៦

៥-ការដាំឈើដើម្បីការពារការហូរច្រោះ ........ ៧

៦-ការដាំឈើសំរាប់ជាចំណីសត្វ ........ ៨

៧-ការដាំឈើជាប្រព័ន្ធកសិ-រុក្ខកម្ម ........ ៩

៨-ការដាំឈើជារបាំងការពារខ្យល់ព្យុះ ទឹកជំនន់ ........ ១០

ជំពូកទី២: ការរៀបចំផែនការដាំដើមឈើរបស់កសិករ ........ ១១

១-ការវិភាគស្ថានភាពដីព្រៃរបស់កសិករ ........ ១៣

២-ការធ្វើផែនការដាំឈើរបស់កសិករ ........ ១៤

៣-ការរៀបចំក្រុម និង ការគ្រប់គ្រងក្នុងការដាំឈើរបស់កសិករ ........ ១៥

៤-ការបង្កើនចំណេះដឹងពីបច្ចេកទេសដាំឈើរបស់កសិករ ........ ១៦

៥-ការស្វែងរកអ្នកគាំទ្រក្នុងការដាំឈើរបស់កសិករ ........ ១៧

ជំពូកទី៣: បច្ចេកទេសដាំឈើ ........ ១៩

ការប្រមូលគ្រាប់ពូជឈើ ........ ២១

១-ការជ្រើសរើសដើមផ្ដល់ពូជ ........ ២៣

១.១-ជ្រើសរើសដើមមេសមស្រប ........ ២៣

១.២ - ការជ្រើសរើសប្រភេទឈើតាមបំណង ........ ២៥
១.៣ - ទីតាំងប្រភពផ្តល់ពូជដែលសមស្រប ........ ២៦
២. របៀបប្រមូលគ្រាប់ពូជឈើ ........ ២៧
២.១ - កំណត់ពេលប្រមូលគ្រាប់ ........ ២៧
២.២ - របៀបបេះប្រមូល ........ ២៨
៣. ការសំអាតគ្រាប់ ........ ៣៣
៣.១ - ការប្រឡេះគ្រាប់ ........ ៣៣
៣.២ - ការសំងួតគ្រាប់ឈើដែលទុកបានយូរ ........ ៣៧
៤. របៀបទុក និងថែទាំគ្រាប់ពូជ ........ ៣៨
៤.១ - ប្រភេទគ្រាប់ឈើមិនអាចរក្សាទុកបានយូរ និង អាចរក្សាទុកបានយូរ ........ ៣៨
៤.២ - របៀបរក្សាទុក ........ ៣៩
៥. ការដឹកជញ្ជូនគ្រាប់ពូជឈើ ........ ៤៣
៥.១ - ការដឹកជញ្ជូនសំរាប់គ្រាប់ឈើឆាប់ខូច ........ ៤៣
៥.២ - ការដឹកជញ្ជូនសំរាប់គ្រាប់ឈើទុកបានយូរ ........ ៤៥

ការបណ្តុះកូនឈើ ........ ៤៧
១. ការរៀបចំថ្នាលបណ្តុះកូនឈើ ........ ៤៩
១.១ - ការជ្រើសរើសទីតាំងថ្នាល ........ ៤៩
១.២ - ការធ្វើរង ........ ៥១
១.៣ - គំរបថ្នាល ឬ គំរបតាមរងនីមួយៗ ........ ៥៣
១.៤ - ការធ្វើរបងព័ទ្ធជុំវិញថ្នាលបណ្តុះកូនឈើ ........ ៥៤
១.៥ - ប្រភពទឹក ........ ៥៥
១.៦ - ជីកំប៉ុស្ត ........ ៥៦
២. ការរៀបចំបណ្តុះ ........ ៦០

២.១ -ការរៀបចំថង់ដី ........ ៦០

២.២ -ការធ្វើប្រព្រឹត្តិកម្មគ្រាប់ពូជ ........ ៦៣

២.៣ -របៀបស្ទូងក្នុងថង់ដី ........ ៧០

៣. ការថែទាំកូនឈើនៅថ្នាលបណ្ដុះ ........ ៧៣

៣.១ -ការស្រោចទឹក ........ ៧៣

៣.២ -ការបោចស្មៅ ........ ៧៣

៣.៣ -ការបករំលោះកូនឈើ និង ស្ទូងជួស ........ ៧៤

៣.៤ -ការកំចាត់សត្វល្អិត ........ ៧៥

៣.៥ -ការដាក់ជី ........ ៧៥

៣.៦ -ការកាត់ឫសកូនឈើធ្លាយថង់ ........ ៧៦

៣.៧ -ការប្តូរថង់កូនឈើ ........ ៧៦

៣.៨ -ការបើកចំហកូនឈើក្នុងថ្នាល ........ ៧៧

៣.៩ -ការបង្កើនពន្លឺថ្ងៃ និង បន្ថយទឹក ........ ៧៧

ការងារដាំកូនឈើ ........ ៧៩

១. ការរៀបចំទីកន្លែងសំរាប់ដាំ ........ ៨១

១.១ -ចំពោះការដាំឈើជាចំការ ........ ៨១

១.២ -ចំពោះការដាំឈើជារបាំងការពារខ្យល់ ........ ៩១

១.៣ -ចំពោះការដាំឈើតាមដងផ្លូវ ........ ៩៤

១.៤ -ចំពោះការដាំឈើដើម្បីបង្កើតម្លប់លើវាលស្មៅ ........ ៩៦

១.៥ -ចំពោះការដាំឈើដើម្បីការពារការហូរច្រោះ និង សំណឹក ........ ៩៧

១.៦ -ចំពោះការដាំឈើធ្វើជាចំណីសត្វ ........ ១០៣

១.៧ -ចំពោះការដាំឈើក្នុងប្រព័ន្ធកសិ-រុក្ខកម្ម ........ ១០៥

២. របៀបកាប់រណ្ដៅដាំកូនឈើ ........ ១០៨

៣. របៀបដាំកូនឈើក្នុងរណ្ដៅ ........ ១០៩

ការថែទាំកូនឈើ ........ ១១១

១. ការដាំជួសកូនឈើ ........ ១១៣

១.១ -ការគណនាភាគរយកូនឈើងាប់ ........ ១១៣

១.២ -ពេលវេលាសមស្របសំរាប់ការដាំជួស ........ ១១៤

១.៣ -របៀបដាំជួស ........ ១១៤

២. ការការពារកូនឈើពីសត្វពាហនៈបំផ្លាញ ........ ១១៦

២.១ -ការធ្វើរបងការពារ ........ ១១៦

២.២ -ការអប់រំកុមារ ឬ ក្មេងឃ្វាលគោ ........ ១១៨

២.៣ -ប្រើនូវច្បាប់ទាំងឡាយរបស់ភូមិ ឬ សហគមន៍ ........ ១១៨

៣. ការការពារកូនឈើពីការបំផ្លាញដោយពពួកសត្វកកេរ កណ្តុរ ឬជន្លួនផ្សេងៗ. ១១៩

៣.១ -បញ្ហា ........ ១១៩

៣.២ -វិធានការ ........ ១២០

៤. ការការពារភ្លើងឆេះព្រៃ ........ ១២១

៤.១ -ការងារបង្ការភ្លើងឆេះព្រៃ ........ ១២១

៤.២ -ការពន្លត់ភ្លើងឆេះព្រៃ ........ ១២៥

៥. ការជំរះស្មៅ ........ ១២៨

៦. ការក្រីមែកដើមឈើ( កូនឈើ) ........ ១៣០

៧. ការធ្វើឱ្យប្រហាល ........ ១៣១

៨. ការថែទាំព្រៃខ្លុង ........ ១៣២

៨.១ -ការងារជំនួយក្រោយពេលប្រមូលផល ដើម្បីឱ្យខ្លុងដុះបានល្អ ........ ១៣៣

៨.២ -របៀបថែទាំដើមខ្លុង ........ ១៣៤

បណ្ណាល័យសាស្ត្រ ........ ១៣៧

ឧបសម្ព័ន្ធ ........ ១៣៩

# ជំពូកទី១

# ផលប្រយោជន៍នៃការដាំដើមឈើ

# ផលប្រយោជន៍នៃការដាំដើមឈើ

## ១. ការដាំឈើជាចំការ




យើងដាំឈើជាចំការព្រៃដើម្បីផលប្រយោជន៍ជាច្រើនដូចជា ៖ រក្សាប្រភពទឹក បង្កើនគុណភាពដី ធ្វើឱ្យអាកាសធាតុល្អ ផ្តល់ជាឈើសំណង់ ឈើថាមពល ជាជំរកសត្វ លើសពីនេះក៏នៅមានប្រយោជន៍ខាងសង្គមកិច្ច ថែរក្សាវប្បធម៌ ប្រពៃណី លំអទេសភាព។ល។

## ២.ការដាំឈើធ្វើជារបងជុំវិញលំនៅដ្ឋាន និង ដាំឈើជុំវិញចំការ





ការដាំដើមឈើតាមព្រំប្រទល់ចំការធំៗ និង នៅជុំវិញភូមិដ្ឋាន មានប្រយោជន៍ធ្វើជាបង្គោលរបងរស់យ៉ាងរឹងមាំ ជួយជារបាំងខ្យល់ ផ្តល់ជាឈើថាមពល និង ផលបន្ទាប់បន្សំជាច្រើនទៀតដូចជា ផ្តល់ជាចំណីសត្វ។ល។ ប្រភេទឈើដែលយើងនិយមដាំមានដូចជាៈ ដើមកន្ទំថេត អំពិលទឹក អង្គារដី ស្វាយអាកាស្យា រលួស ស្តៅ ប្រេងខ្យល់ និង ប្រភេទឈើសំណង់ផ្សេងទៀត។

## ៣-ការដាំឈើតាមដងផ្លូវ





ការដាំឈើតាមដងផ្លូវមានផលប្រយោជន៍ច្រើនយ៉ាងដូចជាៈ ផ្តល់ម្លប់ត្រជាក់តាមដងផ្លូវ បង្កើតសោភ័ណភាព និង ទេសភាពតាមដងផ្លូវ ធ្វើឱ្យខ្យល់អាកាសបរិសុទ្ធល្អ ការពារផ្លូវទប់ទល់នឹងសំណឹក ឬការហូរច្រោះ ការពារធូលីហុយទៅលើលំនៅដ្ឋាន និង ផ្តល់ឈើសំរាប់ប្រើប្រាស់ផ្សេងៗទៀត។ ប្រភេទឈើដែលសមស្របដាំមានដូចជាៈ ដើមក្ទោក ស្វាយ អំពិលបារាំង ដើងគោ គ្រាប់បែក គគីរ ត្រសេក ត្រាំកង់ ល្មៀងរាជ ត្របែកព្រៃ ប្រេងខ្យល់ អង្កាញ់ ឈើទាល អាកាស្យា ។ល។

## ៤. ការដាំឈើតាមទីសាធារណៈ





ការដាំឈើតាមទីកន្លែងសាធារណៈមានៈ មន្ទីរពេទ្យ សាលារៀន វត្តអារាម និង តាមទីធ្លាសួនសាធារណៈដែលមានគុណប្រយោជន៍សំរាប់បរិស្ថានយ៉ាងពិសេស ដូចជាផ្តល់ម្លប់ដ៏ត្រជាក់ និង ទេសភាពជាទីមនោរម្យដល់ជនគ្រប់រូប ។ ប្រភេទដើមឈើដែលគប្បីដាំមានដូចជា : ដើមគគីរ ឈើទាល ក្រាក អំពិលបារាំង អង្កាញ់ ស្មៀងរាជ ស្វាវ បេង ធ្នង់។ល។

## ៥. ការដាំឈើដើម្បីការពារការហូរច្រោះ







គំរបព្រៃនៅលើដីអាចជួយការពារការហូរច្រោះ ចំណែកឫសរបស់រុក្ខជាតិដុះតាមដងផ្លូវទឹកជួយបង្ការទប់ច្រាំងមិនឱ្យបាក់ដី។ តាមដងផ្លូវទឹកនានាដែលគ្មានដើមឈើ ឬ រុក្ខជាតិដុះងាយទទួលរងនូវការបាក់ច្រាំងហើយរាលដាលធំទៅៗអាចបាត់បង់ដីកសិកម្ម និង ដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ។ ដូចនេះត្រូវមានវិធានការដាំដើមឈើឡើងវិញជាបន្ទាន់ ដើម្បីការពារនៅតាមតំបន់នេះ។ ប្រភេទដើមឈើត្រូវដាំមានដូចជា: រាំង អំពិលទឹក ឫស្សី ត្រប៉ែត ក្តុល អាកាស្យា ប្រេងខ្យល់ ខ្ទុម ថ្កាន់ ល្វា។ល។

## ៦.ការដាំដើមឈើសំរាប់ជាចំណីសត្វ



ការដាំឈើសំរាប់ជាចំណើសត្វ គឺដើម្បីបង្កើននូវបរិមាណចំណើអាហារបន្ថែមដល់សត្វដែលយើងចិញ្ចឹម។ គឺជាប្រភេទឈើដែលងាយលូតលាស់បាននៅលើដីគ្រប់ប្រភេទហើយធន់នឹងសភាពដីខ្វះជីជាតិ ងាយដាំ និង ផ្តល់ទិន្នផលខ្ពស់សំរាប់ជាចំណើសត្វ។ ម្យ៉ាងទៀត ប្រភេទឈើដែលដាំសំរាប់ជាចំណីសត្វនោះអាចមានប្រយោជន៍ផ្សេងទៀតមានៈ សំរាប់ធ្វើជារបង និង ផ្តល់សោភ័ណភាពជុំវិញលំនៅដ្ឋានភូមិដ្ឋានបានយ៉ាងល្អប្រសើរ។ ប្រភេទឈើទាំងនោះមានដូចជាៈ ដើមកន្ទំថេត ម្រុំ រលូស អង្គារដី ។ល។ តែសំខាន់គឺកសិករត្រូវជ្រើសរើសប្រភេទឈើដែលងាយរក និង ងាយដុះនៅក្នុងមូលដ្ឋាន ហើយសត្វចូលចិត្តស៊ីទៀតផង។

## ៧. ការដាំឈើជាប្រព័ន្ធកសិ-រុក្ខកម្ម



ការដាំឈើជាប្រព័ន្ធកសិ-រុក្ខកម្ម ជាការដាំចំរុះគ្នារវាង ដើមឈើ និង ដំណាំកសិកម្ម ក្នុងបំណង យកផលប្រយោជន៍ជាបន្តបន្ទាប់ និង ច្រើនប្រការ គឺៈ ឱ្យដើមឈើបង្កើតលក្ខខណ្ឌសមស្របសំរាប់ដំណាំ ដោយជួយកំចាត់ស្មៅស្បូវនៅជំហានដំបូង ឬ ផ្តល់ម្លប់សំរាប់ដំណាំ ឬ រុក្ខជាតិឱសថដែលត្រូវការម្លប់ ឬ ជួយកែលំអជីជាតិដី ឬ ទប់សំណឹកជាដើម ហើយជាបណ្តើរៗកសិករអាចប្រមូលផលពីដំណាំទាំងនោះ និង ទីបញ្ចប់កសិករអាចប្រមូលផលឈើ ។ ពេលខ្លះផលពីដើមឈើអាចប្រមូលបណ្តើរៗ ជាចំណីសត្វ អុស ឬ ជាអនុផលព្រៃឈើផ្សេងទៀត ។ប្រភេទដើមឈើដែលនិយមដាំជាប្រព័ន្ធកសិ-រុក្ខកម្មមានដូចជាៈ កន្ធំថេត អង្កាដី ម្រុំ ។ល ។

## ៨.ការដាំឈើជារបាំងការពារខ្យល់ព្យុះ និង ទឹកជំនន់



នៅតំបន់វាលល្ហល្ហេវច្រើនមានខ្យល់បោកបក់ខ្លាំង ហើយអាចមានជាខ្យល់ព្យុះ ឬ ទឹកជំនន់ញឹកញាប់ជាងតំបន់ដែលមានព្រៃ។ ព្យុះ ឬ ទឹកជំនន់ បំផ្លាញទាំងហេដ្ឋារចនាសម្ព័ន្ធ ផ្ទះសំបែង និងផលិតផលកសិកម្មរបស់កសិករ ។ល ។ វិធីទប់ស្កាត់ដែលទទួលបានលទ្ធផលល្អគឺ ការដាំឈើធ្វើជារបាំងជាច្រើនសង្កាត់ ឬ ជាច្រើនជាន់។ ប្រភេទដើមឈើដែលសមស្របក្នុងស្ថានភាពនេះមានដូចជាៈ ដើមស្វាយប្រេងខ្យល់ អាកាស្យា ពួច ក្រោក ឬស្សី ច្រេស ។ល ។

# ជំពូកទី២

# ការរៀបចំផែនការដាំដើមឈើ

# របស់កសិករ

## ១-ការវិភាគស្ថានភាពដីព្រៃរបស់កសិករ





កសិករត្រូវធ្វើការពិភាក្សាគ្នាដើម្បីកំណត់ឱ្យឃើញពី តំរូវការ និង បញ្ហា ក្នុងការប្រើប្រាស់ធនធានព្រៃឈើនៅក្នុងមូលដ្ឋាន ព្រមទាំងឱកាសដែលមាន អាចជួយស្តារធនធនព្រៃឈើបំពេញតំរូវការឡើងវិញបាន ដូចជាមានដីអាចដាំឈើ មានព្រៃខ្ចង មានប្រភេទដើមឈើអ្វីខ្លះដុះលើដីព្រៃនោះ ។ល ។ ហើយត្រូវរកដំណោះស្រាយដើម្បីស្តារព្រៃឈើឡើងវិញ ។

ប្រសិនបើចាំបាច់ កសិករគួរទំនាក់ទំនងជាមួយមន្ត្រីព្រៃឈើ ឬ អ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងមូលដ្ឋាន ដែលអាចជួយគាំទ្រក្នុងការស្តារព្រៃឈើឡើងវិញ ។

## ២. ការធ្វើផែនការដាំឈើរបស់កសិករ



ក្នុងការធ្វើផែនការនេះ កសិករត្រូវធ្វើការពិភាក្សាគ្នាដើម្បី:

-កំណត់តំបន់ត្រូវដាំដើមឈើឡើងវិញ និង ផលប្រយោជន៍

-ជ្រើសរើសពូជឈើសមស្របតាមស្ថានភាព ឆន្ទៈ និង តំរូវការ

-វាយតំលៃជាក់លាក់នូវចំនួនកូនឈើដែលត្រូវដាំឡើងវិញ

-រកវិធីសាស្ត្រដើម្បីជួយឱ្យសំរេចផែនការដាំឈើឡើងវិញនេះ ។

ប្រសិនបើចាំបាច់ កសិករគួរទំនាក់ទំនងជាមួយមន្ត្រីព្រៃឈើ ឬ អ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងមូលដ្ឋានដែលអាចជួយគាំទ្រក្នុងការធ្វើផែនការស្តារព្រៃឈើឡើងវិញ ។

## ៣-ការរៀបចំក្រុម និង ការគ្រប់គ្រងក្នុងការដាំឈើរបស់កសិករ



កសិករត្រូវរៀបចំក្រុម និង ជ្រើសរើសតំណាងក្រុមដើម្បីងាយស្រួលក្នុង ការដឹកនាំដំណើរការអនុវត្តន៍ផែនការដាំឈើ និង រ៉ាប់រងកិច្ចការទំនាក់ទំនងសហការជាមួយបណ្ដាដៃគូ ឬ អ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យដំណើរការអនុវត្តផែនការដាំឈើឡើងវិញនេះ ប្រព្រឹត្តិទៅបានជោគជ័យ ។

## ៤.ការបង្កើនចំណេះដឹងពីបច្ចេកទេសដាំឈើរបស់កសិករ



ត្រូវបង្កើនចំណេះដឹងពីបច្ចេកទេសដាំឈើដល់ សមាជិកក្រុម ឬ សហគមន៍ តាមរយៈ

-ការអានសៀវភៅ ផ្សព្វផ្សាយបច្ចេកទេសដាំឈើសំរាប់កសិករ

-រៀបចំវគ្គបណ្តុះបណ្តាលពីបច្ចេកទេសដាំឈើដល់សមាជិកក្រុម ឬ សហគមន៍ ។

ប្រសិនបើចាំបាច់ កសិករគួរទំនាក់ទំនងជាមួយមន្ត្រីព្រៃឈើ ឬ អ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងមូលដ្ឋានដែលអាចជួយគាំទ្រក្នុងការបណ្តុះបណ្តាលពីបច្ចេកទេសដាំឈើ ឬ បច្ចេកទេសអ្វីដែលកសិករត្រូវការចាំបាច់ ។

## ៥. ការស្វែងរកអ្នកគាំទ្រក្នុងការដាំឈើរបស់កសិករ



អ្នកតំណាងក្រុម ឬ សហគមន៍របស់កសិករត្រូវៈ

-ស្វែងយល់ពីគោលបំណងនៃកម្មវិធីអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន ដែលកំពុងមានសកម្មភាព។

-រាយការណ៍ ឬ បង្ហាញផែនការស្តារព្រៃឈើឡើងវិញរបស់ក្រុម ឬ សហគមន៏ ដល់អាជ្ញាធរមូលដ្ឋាន ឬ អ្នកផ្សព្វផ្សាយកម្មវិធីអភិវឌ្ឍន៍ ឬ មន្ត្រីព្រៃឈើនៅមូលដ្ឋាន ដើម្បីសុំការគាំទ្រទាំងស្មារតី និង សំភារៈ ដល់ផែនការស្តារព្រៃឈើឡើងវិញរបស់ក្រុម ឬ សហគមន៏។

# ជំពូកទី៣

# បច្ចេកទេសដាំឈើ

# ការប្រមូលគ្រាប់ពូជឈើ

# ការប្រមូលគ្រាប់ពូជ

## ១-ការជ្រើសរើសដើមផ្តល់ពូជ

ការជ្រើសរើសដើមផ្តល់ពូជបានត្រឹមត្រូវ នាំអោយដើមឈើដែលដាំមានគុណភាព និង សុខភាពល្អ ហេតុនេះត្រូវជ្រើសរើសប្រភពពូជឱ្យបានសមស្របដូចខាងក្រោម:

### ១.១-ជ្រើសរើសដើមមេសមស្រប

-ត្រូវជ្រើសរើសដើមមេក្នុងព្រៃធម្មជាតិ ឬ ព្រៃដាំ។ ព្រោះគ្រាប់ឈើដែលបានពីដើមមេដុះទោលតែឯងច្រើនតែសំបូរជំងឺ ដុះលូតលាស់យឺត ហើយទំរង់ដើមច្រើនតែមិនសូវល្អ។



ព្រៃធម្មជាតិ ឬព្រៃដាំ



ដើមមេដុះទោលតែឯង

-ត្រូវជ្រើសរើសយកដើមមេណាដែលមានទំរង់ដើមត្រង់ស្រឡូនល្អ មែកតិច មិនមានប្រហោងក្នុង គ្មានជំងឺ។



-មិនត្រូវជ្រើសយកដើមមេដែលចាស់ពេក ឬ ក្មេងពេក។



## ១.២.ការជ្រើសរើសប្រភេទឈើតាមបំណង

ត្រូវជ្រើសរើសប្រភេទឈើទៅតាមបំណងៈ



-ប្រភេទផ្តល់ផលឈើសំណង់ៈ ដើមមេមានលក្ខណៈត្រង់ស្រឡូនល្អ ហើយមានមែកតិច។



-ប្រភេទផ្តល់ផលជាអុសៈ ត្រូវជ្រើសយកប្រភេទឈើ ដែលដុះលូតលាស់លឿន សំបូរមែកច្រើន ហើយកាន់តែប្រសើរបើមានលទ្ធភាពដុះខ្នែងឡើងវិញ សំរាប់ប្រមូលផលសារក្រោយទៀត។

- បើចង់បានផលសំរាប់ធ្វើជាចំណីសត្វ ត្រូវជ្រើសរើសយកប្រភេទឈើដែលៈ
  - សត្វចូលចិត្តស៊ី ស្លឹក ឬ ផ្លែ
  - ដុះលូតលាស់លឿន
  - មានមែកច្រើន សំបូរស្លឹក
  - មានលទ្ធភាពដុះខ្នែងបានរហ័ស

**គួរចងចាំថាៈ** ដើមឈើដែលមាន ស្លឹកបៃតងជានិច្ចពេញមួយឆ្នាំ ផ្តល់ចំណីសត្វ ច្រើនជាងប្រភេទឈើដែលជ្រុះស្លឹកនៅខែខ្លះក្នុងមួយឆ្នាំ។



## ១.៣-ទីតាំងប្រភពផ្តល់ពូជដែលសមស្រប

-គួរប្រមូលគ្រាប់ពូជ នៅក្នុងតំបន់ណា ដែលមានលក្ខណៈបរិស្ថានប្រហាក់ប្រហែលតំបន់ ដែលចង់ដាំដើមឈើ ដូចជារយៈកំពស់ សីតុណ្ហភាព របបទឹកភ្លៀង ប្រភេទដីជាដើម។



-មិនគួរយកគ្រាប់ពូជ ដែលប្រមូលពីព្រៃដុះនៅតំបន់ខ្ពស់( ភ្នំ ឬ ខ្ពង់រាប) មកដាំនៅលើតំបន់ទំនាបទេ ហើយក៏មិនគួរយកគ្រាប់ពូជ ដែលប្រមូលពីព្រៃដែលដុះនៅតំបន់ទំនាបទៅដាំនៅតំបន់ខ្ពស់( ភ្នំ ឬ ខ្ពង់រាប) វិញដែរ ។

-ប្រការដែលល្អបំផុត គឺត្រូវប្រមូលគ្រាប់ពូជដែលរកបានក្នុងតំបន់ដែលត្រូវដាំ មកដាំពីព្រោះដើមឈើទាំងនោះបានរស់ស៊ាំនឹងទីកន្លែងរួចហើយ ។

## ២.របៀបប្រមូលគ្រាប់ពូជ

### ២.១-កំណត់ពេលប្រមូលគ្រាប់

-ពេលវេលាដែលល្អ សំរាប់ប្រមូលគ្រាប់គឺ នៅពេលដែលផ្លែ ឬគ្រាប់ឈើទុំស្រុះល្អ ឬ ទុំច្រើន ។

-ត្រូវអោយច្បាស់ថា ផ្លែឈើដែលត្រូវបេះនោះទុំល្មមហើយ មិនត្រូវបង្ខំបេះទាំងខ្ចីពេកឬទុកអោយទុំជ្រុលពេកទេ ។

ជាទូទៅ យើងអាចសំគាល់ផ្លែឈើទុំដោយលក្ខណៈមួយចំនួនដូចខាងក្រោមៈ

ក-លក្ខណៈសំបុរៈ

+សំបុរលើសំបកផ្លែៈ ប្រែពណ៌ពីខៀវឬបៃតងទៅជាសំបុរត្នោតក្រម៉ៅ ឬលឿង ឬស្ងួតសំបក ។

+សំបុរលើស្លាបៈ ផ្លែដែលមានស្លាប ពេលទុំស្លាបរបស់វាឡើងសរសៃហើយរឹងស្ងួត និង ប្រែសំបុរជូនពីផ្កាឈូក ទៅក្រហមចាស់ ជូនពីបៃតងខ្ចីទៅបៃតងចាស់លាយក្រហមព្រឿងៗ ។

ខ-លក្ខណៈក្លិនៈ ផ្លែរបស់ប្រភេទឈើខ្លះ ផ្តល់ក្លិននៅពេលទុំ ។

គ-សត្វមកស៊ីៈ ផ្លែរបស់ប្រភេទឈើខ្លះពេលទុំសត្វចូលចិត្តស៊ី ។ ហេតុនេះនៅពេលសត្វចាប់ផ្តើម ចូលមកស៊ីនោះអាចសំគាល់បានថា ផ្លែឈើនោះទុំហើយ ។

ឃ-ពិនិត្យផ្លែសាកៈ ផ្លែរបស់ប្រភេទឈើខ្លះ ទុំរលុងសំបក (សំបកផ្លែ និង គ្រាប់មិនជាប់គ្នា) បើកាត់គ្រាប់មើលផ្នែកខាងក្នុងឃើញពណ៌សរឹង ដូចជា គ្រាប់បេង ក្រកោះ ក្លោក ជាដើម ចំណែកប្រភេទខ្លះទៀតមើលឃើញពន្លកគ្រាប់ច្បាស់មានពណ៌ស ឬ បៃតងខ្ចី ដូចជា គ្រាប់ឈើទាល គគីរ ខ្លង ត្បែង ជាដើម ។

## ២.២-របៀបបេះប្រមូល

### ២.២.១.ត្រូវបេះប្រមូលពីសំណុំស្លឹកទាំងមូល

គ្រាប់នៅមែកស្រទាប់ក្រោម ងាយបេះដល់ តែជាគ្រាប់ពុំសូវល្អទេ ចំនែកគ្រាប់នៅមែកស្រទាប់លើ ពិបាកឡើងដល់តែជាគ្រាប់ល្អជាង ហេតុនេះត្រូវប្រមូលយកទាំងមែកស្រទាប់លើ ទាំងមែកស្រទាប់ក្រោម និង មែកស្រទាប់កណ្ដាលផងដែរ។



### ២.២.២.របៀបផ្សេងៗក្នុងការប្រមូលគ្រាប់

**ក-ប្រមូលគ្រាប់ជ្រុះដោយធម្មជាតិ:**

ជាមធ្យោបាយមួយងាយស្រួលជាងគេ។ វិធីនេះងាយប្រើសំរាប់ពូជឈើ ដែលមានគ្រាប់ ឬ ផ្លែធំដូចជា មៃសាក់ និង ប្រភេទមួយចំនួននៃអំបូរផ្លែស្លាប។

-<u>សំភារ:ត្រូវប្រើ</u>: រនាស់, កាំបិត, សំភារះសំរាប់ដាក់គ្រាប់, កំរាលកន្ទេលស្លឹកត្នោត ឬ តង់ប្លាស្ទិច។

- ជំហានអនុវត្ត:

១-សំអាតដីក្រោមដើមពូជ ( ស្លឹក ស្មៅ ព្រិច ) មុនពេលគ្រាប់ទុំធ្លាក់ ដើម្បីស្រួលប្រមូល ។

២-ក្រាលក្រណាត់ប្លាស្ទិចត្រងគ្រាប់ ។

៣-ប្រមូលគ្រាប់រាល់ថ្ងៃហើយសំអាតគ្រាប់ដោយរើសយកសំរាមចេញ ។



### ខ-អង្រួនដើមឬមែក

គ្រាប់ឬផ្លែប្រភេទឈើខ្លះជ្រុះដោយធម្មជាតិមិនស្រុះគ្នា នោះត្រូវការអង្រួនដើម ឬមែក ដើម្បីជំរុះគ្រាប់ ឬផ្លែ ឱ្យធ្លាក់មកដីនៅពេលតែមួយ ។ នេះជាវិធីមួយធ្វើឱ្យការប្រមូលមានភាពងាយស្រួល ។

ជំហានអនុវត្តៈ

១-សំអាតដីក្រោមដើម ក្រាលកន្ទេល ឬ កៅស៊ូតង់

២-អង្រួនដើម ឬ មែក ដោយប្រើទំពក់វែង

៣-ប្រមូលដោយបំបែកផ្លែស្រស់ចេញពីផ្លែស្ងួត



**គ-កាត់យកមែកមានផ្លែ**

នៅពេលដែលផ្លែ ឬគ្រាប់ឈើនៅខ្ពស់ផុតដៃឈោង ហើយមានសណ្ដង់ស្វិតជាប់មែកយ៉ាងមាំ មិនអាចអង្រួនបាន ពេលនោះត្រូវប្រើការកាត់យកមែកដែលមានផ្លែមកប្រឡេះ នៅដី។

១-ជ្រើសរើសយកមែកដែលមានផ្លែល្អៗ

២-ប្រើខ្វាង ឬថ្នោលចងរណារចុង កាត់ផ្ដាច់មែកមានផ្លែ

៣-បេះប្រឡេះយកផ្លែ ឬ គ្រាប់ពីមែកដែលធ្លាក់មកដី



## ឃ-ឡើងបេះប្រមូលគ្រាប់

ជាវិធីមួយប្រើដើម្បីប្រមូលផ្លែ ឬ គ្រាប់ឈើដែលមានសណ្ឋស្ថិតជាប់មែកមិនងាយជ្រុះ ឬ ផ្លែដែលពេលទុំចំហឱ្យគ្រាប់តូចៗងាយជ្រុះពីលើដើម ។ វិធីនេះត្រូវការភាពស្ទាត់ក្នុងការឡើងដើមឈើ ។

ប្រើជណ្ដើរពាក់ឡើងបេះដល់លើមែកជាមធ្យោបាយមួយរហ័ស ហើយមានសុវត្ថិភាព ។ ជណ្ដើរធ្វើពី អាលុយមីញ៉ូមអាចបត់បាន ស្រួលប្រើ និង រហ័ស ។ ប៉ុន្តែ កសិករអាចប្រើជណ្ដើរដែលងាយធ្វើដោយខ្លួនឯង អំពីឬស្សីប្រវែងពី ៧-៩ម ។





ម្យ៉ាងវិញទៀត អាចឡើងទៅលើមែកដើមឈើ ហើយប្រើរណារ ឬ ខ្វាង ឬ កាំបិត ឬ មធ្យោបាយប្រហាក់ប្រហែលគ្នានេះ ដើម្បីកាត់ទំលាក់មែកឈើតូចដែលមានផ្លែ រួចប្រឡេះនៅដី ។

## ៣-ការសំអាតគ្រាប់

### ៣.១-ការប្រឡេះគ្រាប់

ផ្លែឬគ្រាប់ឈើ(ភាពផ្សេងគ្នារវាងផ្លែ និង គ្រាប់ឈើមានបង្ហាញក្នុងឧបសម្ព័ន្ធ២)ដែលប្រមូលបានទោះជាផ្លែទុំមានសាច់ ឬ ផ្លែក្ងរ ឬ ផ្លែដែលមានសំបកទុំស្ងួត ឬ ជាគ្រាប់ទោលក៏ដោយ ត្រូវតែប្រឡេះចេញឱ្យបានស្អាត ជៀសវាងការខូចខាតទៅវិញដោយសារ ការដុះផ្សិត ឬ រលួយ និង ដើម្បីងាយស្រួលក្នុងការទុកដាក់ថែរក្សាផងដែរ។ ដោយទាក់ទងទៅនឹងប្រភេទផ្លែដូចខាងលើ នោះការប្រឡេះ និង ការសំអាតដែលសមស្រប ត្រូវការរបៀបសំអាត ឬ ប្រឡេះផ្សេងៗពីគ្នា។

របៀបប្រឡេះគ្រាប់ភាគច្រើនទាមទារការសំងួតផ្លែជាមុន។ ប៉ុន្តែប្រភេទឈើខ្លះទៀតទាមទារការត្រាំទឹកជាមុនក្នុងបំនងប្រឡេះគ្រាប់បានងាយ។ ខាងក្រោមជារបៀបប្រឡេះ និងសំអាតគ្រាប់ដែលមានលក្ខណៈងាយស្រួលដល់កសិករ:

#### ក-សំរាប់ផ្លែស្ងួត

១-ហាលសំងួតផ្លែ ក្រោមកំដៅថ្ងៃនៅលើកំរាលថ្មស៊ីម៉ងតិ៍ កៅស៊ូតង់ ឬក្រណាត់បាវរហូតដល់ផ្លែប្រេះបែក។ វិធីនេះប្រើចំពោះផ្លែដូចជា ប្រេងខ្យល់ អាកាស្យា ស្វាវ ស្រល់ អង្កាញ់ជាដើម។ ផ្លែទាំងនេះអាច ដាក់ហាលលើកញ្រ្ចែង ឬស្បែសំណាញ់លួសដោយមានតំរងពីក្រោម ដល់ពេលផ្លែប្រេះបែកគ្រាប់ធ្លាក់ចូលទៅក្នុងតំរងជាការស្រេច។



ចំពោះផ្លែស្ងួតខ្លះ ហាលសំងួតហើយតែមិនប្រេះបែកដោយខ្លួនវាទេ។ ករណីនេះត្រូវបែនដោយបេ ជើង ឬ ដាក់ក្នុងបាវដំ ឬបុកធ្វើឱ្យផ្លែបែកលឿន ដូចជាផ្លែត្រសេក ផ្លែច្រេស ផ្លែនាងនួន ជាដើម ។



ផ្លែខ្លះមិនប្រេះបែកទេ តែក៏មិនអាចបុក ឬ ដំបានដែរ ព្រោះអាចបែកគ្រាប់ ហេតុនេះត្រូវបក ដោយដៃហើយប្រឡេះយកគ្រាប់ ដូចជា ផ្លែម្រុំ ជាដើម ។

២-សំអាតគ្រាប់ដោយបក់ ឬ ក៏រោយយកក្រញ៉ម ឬ សំអងចេញ។



៣-លាងជំរះគ្រាប់នៅក្នុងផើង ( កាធុនទឹក ) ស្រង់យកគ្រាប់អណ្តែតចេញ រួចស្រិតទឹកចេញឱ្យបានរហ័ស ។



៤-ហើយសំងួតគ្រាប់ឡើងវិញ ។ បើគ្រាប់នោះត្រូវការដាំប្រញាប់នោះមិនចាំបាច់សំងួតទេ ។



## ខ-សំរាប់ផ្លែមានសាច់

ដើម្បីឱ្យងាយស្រួល គួរធ្វើការប្រឡេះគ្រាប់ឈើនៅឯផ្ទះ តែកុំអូសបន្លាយពេលធ្វើការប្រឡេះគ្រាប់យូរពេក ហើយកុំរក្សាទុកគ្រាប់ត្រួតគរលើគ្នា និងកុំធ្វើអ្វីដែលរំខានដល់គ្រាប់។ ការឡើងកំដៅ និង ការធ្វើឱ្យឡើងជូរនៅក្នុងគំនរគ្រាប់អាចសំលាប់ ឬបន្ថយគុណភាពដំណុះរបស់គ្រាប់។



ខាងក្រោមជារបៀបប្រឡេះនិងសំអាត:

១-ត្រាំផ្លែក្នុងទឹក(១-២ថ្ងៃ) រហូតដល់សាច់ផ្លែទន់អាចលាងជំរះបាន។

២-លាង ឈ្លី ឬ ដុសគ្រាប់ដោយដៃ ដើម្បីបំបែកសាច់ផ្លែចេញដោយប្រិតប្រៀងកុំឱ្យប៉ះទង្គិច ខ្លាំងធ្វើអោយខូចដល់គ្រាប់។

៣-ប្រមូលយកគ្រាប់អណ្តែត និង សាច់ផ្លែចោលសរិតទឹកចេញ លាងជំរះគ្រាប់ឡើងវិញ។

៤-ហាលសំងួតដោយខ្យល់។

៥-អុំ ឬ រោយសំអាតគ្រាប់ឡើងវិញ។



## ៣.២-ការសំងួតគ្រាប់ឈើដែលទុកបានយូរ

ត្រូវសំងួតគ្រាប់ដោយកំដៅថ្ងៃ ដើម្បីឱ្យគ្រាប់អាចរក្សាទុកបានយូរ។ ខាងក្រោមជាវិធីសំងួតដែលសមស្រប:

១-រីគ្រាប់ឈើឱ្យស្តើង និងស្មើលើកន្ទេលស្លឹកត្នោត ឬ តង់កៅស៊ូ ឬ បន្ទះប្លាស្ទិចពណ៌ភ្លឺ (បន្ទះខ្មៅអាចធ្វើឱ្យគ្រាប់ក្តៅខ្លាំងពេក) ឬ ចង្អេរអុំ ឬ រនាំង ដាក់នៅកន្លែងណា ដែលព្រះអាទិត្យ ចាំងមកពេញមួយថ្ងៃ។

២-រីប្រែគ្រាប់ ៤-៥ ដង ក្នុងមួយថ្ងៃអោយស្ងួតសព្វ។ ប្រសិនបើអាចធ្វើបាន ទុកគ្រាប់ក្នុងម្លប់នៅពេលក្តៅខ្លាំង (ថ្ងៃត្រង់ដល់រសៀល)។

៣-មុនភ្លៀង ឬ មេឃងងឹត ត្រូវយកគ្រាប់ចូលផ្ទះ។

៤-ហាលសំងួតពី ១-៣ថ្ងៃ អាស្រ័យទៅតាមសំណើមគ្រាប់ សើមតិច ឬ ខ្លាំង។

៥-ពេលហាលសំងួតគ្រាប់ ត្រូវការពារគ្រាប់អោយផុតពីសត្វកកេរ និងបក្សីស៊ី។



**<u>ចំណាំ:</u>** ពពួកគ្រាប់ដែលឆាប់ខូច ដូចជាអំបូរផ្លែមានស្លាប គួរតែយកទៅសាប ឬ បណ្តុះឱ្យបានឆាប់បំផុត ក្រោយពីប្រមូល។ ពពួកគ្រាប់ទាំងនេះមិនអាចសំងួតបានទេ។

## ៤.របៀបទុក និង ថែទាំគ្រាប់ពូជ

បើគ្រាប់ឈើត្រូវយកទៅបណ្តុះភ្លាមៗ ក្រោយពីប្រមូលបាន ២-៣ថ្ងៃ នោះការថែរក្សាពេលខ្លីនេះអាចទុកក្នុងថង់ក្រណាត់ដាក់ក្នុងម្លប់ធម្មតា( ក្នុងលំនៅដ្ឋាន) ដោយមិនចាំបាច់មានសំភារៈត្រួតពិនិត្យសំណើមពិសេសអ្វីទេ។ តែបើត្រូវទុកគ្រាប់ក្នុងរយៈពេលមួយយូរ នោះត្រូវយល់ដឹងពីរបៀបទុកដាក់ដែលសមស្រប ។

### ៤.១-ប្រភេទគ្រាប់ឈើមិនអាចរក្សាទុកបានយូរ និង អាចរក្សាទុកបានយូរ

ជាដំបូងត្រូវយល់ដឹងថា តើគ្រាប់ប្រភេទណា ដែលមានលក្ខណៈធម្មជាតិអាចទុកបានយូរ ។ ពពួកគ្រាប់ឆាប់ខូច (Recalcitrant) មិនអាចទុកបានយូរទេ ត្រូវសាបក្រោយពីប្រមូលបានភ្លាម ។




ពពួកគ្រាប់ស្ងួតដូចនេះទើបអាចរក្សាទុកយូរបាន ។



**៤.២ -របៀបរក្សាទុក** (សំរាប់តែគ្រាប់អាចរក្សាទុកបាន-Orthodox)

ជាទូទៅចំនុចសំខាន់ដើម្បីឱ្យគុណភាពគ្រាប់រក្សាទុកបានប្រសើរ គឺត្រូវរក្សាសំណើម និង សីតុណ្ហភាពរបស់គ្រាប់ដែលរក្សានោះឱ្យបានទាប ហើយត្រូវតាមដានមើលជាប្រចាំ។

ខាងក្រោម គឺជាការងារត្រូវយកចិត្តទុកដាក់ក្នុងការរក្សាទុកគ្រាប់ពូជឈើ:

១-ត្រូវរក្សាទុកតែគ្រាប់ណាដែលថ្មី ទុំ ហើយសំងួតបានល្អហើយ។

២-រក្សាគ្រាប់ក្នុងកន្លែងស្ងួតមិនត្រូវទឹកភ្លៀងហើយត្រជាក់ ពន្លឺថ្ងៃតិចមានលក្ខខណ្ឌអំណោយផលឱ្យខ្យល់ចេញចូលបានស្រួល ដើម្បីធ្វើឱ្យគ្រាប់មានលទ្ធភាពរស់បានយូរ។



៣-ចំពោះគ្រាប់ណាងាយបឺតសំណើមត្រូវទុកវាក្នុងរបស់ណា ដែលអាចបិទខ្យល់ចេញចូលបាន ដូចជា ពីដុង កំប៉ុង ឬ ដបកែវដែលមានគំរបបិទជិតឈឹងល្អ ឬ ដាក់សារធាតុបឺតទឹកបន្តិច ដូចជា ផេះស្ងួត ឬ ធ្យូងស្ងួត ឬ បាយក្រៀម ឬកំទេចក្រដាសកាសែត។ ត្រូវដាក់សារធាតុស្ងួតស្រូបសំណើមស្មើមួយភាគបួននៃចំណុះផ្ទុកគ្រាប់។



សំភារៈផ្ទុកគ្រាប់


ការលាយផេះស្ងួតជាមួយគ្រាប់


Farmers' Tree Planting Manual, 2003
Producers: CTSP-DANIDA, GTZ-CGFP, DFW, JICA, PRASAC

៤-ត្រូវបិទផ្លាកលើសំភារៈផ្ទុកគ្រាប់ ដោយមានដាក់ឈ្មោះប្រភេទគ្រាប់ ទីកន្លែង និងថ្ងៃខែឆ្នាំ ដែលបាន ប្រមូលគ្រាប់ពូជនោះ ។




៥-ប្រសិនបើអាចធ្វើបាន ត្រូវកត់ត្រាភាគរយដំណុះរបស់គ្រាប់ចូលក្នុងផ្លាកផងដែរ ។ ដើម្បីដឹងភាគរយដំណុះគ្រាប់ត្រូវសាកបណ្តុះគ្រាប់មួយចំនួនមើលថា តើដុះបានចំនួនប៉ុន្មាន? បើគ្រាប់៨បានដុះក្នុងចំណោមគ្រាប់សាក១០គ្រាប់ នោះលទ្ធភាពដំណុះរបស់គ្រាប់៨០% ។ ពតិមាននេះនឹងជួយឱ្យដឹងថា ប្រភេទគ្រាប់នីមួយៗ បានខូចលទ្ធភាពដំណុះអស់ប៉ុន្មានក្នុងពេលស្តុកចាប់ពីពេលប្រមូលរហូត ដល់ពេលដាំ ។



៦-ដើម្បីការពារគ្រាប់ឈើដែលត្រូវរក្សាទុក កុំឱ្យ ខ្មូត ស្រមោច កណ្ដៀរស៊ី និង ដុះផ្សិត ត្រូវលាយគ្រាប់ឈើជាមួយកំទេចស្លឹកស្ដៅស្ងួត មុនពេលដាក់ចូលទៅក្នុងកន្លែងទុកដាក់ ឬមួយប្រើប្រេងស្ដៅ ឬ ប្រេងសណ្ដែក ឬ ប្រេងគ្រាប់គរ ដោយយកប្រេងមួយស្លាបព្រាលាយជាមួយគ្រាប់មួយគីឡូក្រាម ឬ ម៉្យាងទៀតប្រើថ្នាំកន្លាតមួយឬពីរគ្រាប់លាយជាមួយគ្រាប់ឈើ ១០គីឡូក្រាម ។




៧-ការពារគ្រាប់ឈើផុតពីសត្វកកេរ និង បក្សីស៊ីពេលរក្សាទុក ។

**នៅពេលរក្សាទុកគ្រាប់ពូជឈើនៅក្នុងសំភារៈបិទជិត :**

-ជៀសវាងទុកគ្រាប់ដែលនៅសើម ក្នុងរបស់ដែលបិទជិត ( ហាប់ )

-ត្រូវប្រើសំភារៈផ្ទុកដែលប្រាកដថា មិនអាចឱ្យខ្យល់ចេញចូលបានដូចជា កានជ័រ កែវមានគ្របធុង ជាដើម ។

-ត្រូវបើកសំភារៈផ្ទុកគ្រាប់ពូជឈើតែពេលណាដែលចាំបាច់ ។

គ្រាប់ប្រភេទខ្លះមិនធន់នឹងការសំងួត ឬសីតុណ្ហភាពត្រជាក់ទេ ដូចជា គ្រាប់ធូរេន ស្វាយ ខ្នុរ ស្ដៅ មង្ឃុត សាវម៉ាវ គីនីន ជាដើម។ គ្រាប់ទាំងនេះអាចរក្សាបានត្រឹមតែពីប៉ុន្មានថ្ងៃ រហូតដល់១-២ខែទេក្នុងលក្ខខណ្ឌក្នុងបន្ទប់ធម្មតា។ ជាការប្រសើរ បើយកគ្រាប់ប្រភេទទាំងនេះទៅដាំឱ្យបានឆាប់ ក្រោយពីប្រមូលបានមក។

**បើរក្សាទុកត្រូវ:**

-កុំសំងួតគ្រាប់ខ្លាំងពេក។ ត្រូវដកសំណើមវាតិចតួចបានហើយ ដើម្បីសំងួតសំបកគ្រាប់តែសាច់គ្រាប់នៅសើម។

-ដាក់គ្រាប់តែពាក់កណ្ដាលថង់ប្លាស្ទិច និង ពាក់កណ្ដាលទៀតដាក់ធ្យូងល្អិតតិចៗ ឬ អាចំរណា ឬ ដីខ្សាច់។

-រក្សាទុកថង់គ្រាប់ក្នុងកន្លែងត្រជាក់

-ចំហថង់រយៈពេល ១ម៉ោងកន្លះក្នុងមួយថ្ងៃ ដើម្បីអោយខ្យល់ចូលក្នុងបាន។

## ៥.ការដឹកជញ្ជូនគ្រាប់ពូជឈើ

### ៥.១ -ការដឹកជញ្ជូនសំរាប់គ្រាប់ឈើឆាប់ខូច

ក្រោយពីប្រមូលគ្រាប់បានហើយត្រូវរូសរាន់ដឹកជញ្ជូន តាមវិធីដូចខាងក្រោម:

**ក.ប្រើថង់ច្រក:**

១-ច្រកគ្រាប់៣-៥គីឡូក្រាម ក្នុងថង់ប្លាស្ទិច ឬ ថង់ក្រណាត់ នីមួយៗហើយបត់មាត់ថង់ផ្នែកខាងលើ (ខ្យល់អាចចេញចូលបាន)។

២-តំរៀបថង់គ្រាប់បញ្ឈរក្នុងកន្លែងដែលត្រូវផ្ទុក



៣-គ្របក្រណាត់តង់ប្លាស្ទិចពីលើ នៅពេលដឹកជញ្ជូន ។




ខ. ប្រើដីខ្សាច់គប់:

១-រាយដីខ្សាច់មួយស្រទាប់ នៅបាតកន្លែងត្រូវផ្ទុក

២-រាយស្រទាប់គ្រាប់ពីលើដីខ្សាច់ កំរាស់ ២-៣ គ្រាប់

៣-បង្កើតបែបនេះ ២-៣ ស្រទាប់ ហើយបញ្ចប់ដោយស្រទាប់ដីខ្សាច់ពីលើ



## ៥.២-ការដឹកជញ្ជូនសំរាប់គ្រាប់ឈើទុកបានយូរ

ការដឹកជញ្ជូនគ្រាប់បែបនេះ ត្រូវយកចិត្តទុកដាក់ជាមួយការងារដូចខាងក្រោម:

១-ត្រូវទុកដាក់គ្រាប់ឱ្យបានល្អបន្ទរបួតទាំងក្នុងពេលដឹកនាំយកទៅថ្នាល និង ពេលថែទុកក្នុងថ្នាលមុនពេលសាប ។

២-ពេលដឹកជញ្ជូន ត្រូវវេចខ្ចប់គ្រាប់ឱ្យបានពីរជាន់ មួយជាន់ក្នុងជាថង់ប្លាស្ទិចការពារទឹក ឬ ទឹកភ្លៀង និង ជាន់ក្រៅជាឡាំងក្រដាស ឬ បាវក្រណាត់ ការពារការប៉ះទង្គិចរបស់រឹង និង ការពារពន្លឺថ្ងៃ ។




៣-ដំបូន្មានសំរាប់អ្នកទទួលភារៈដឹកជញ្ជូនគ្រាប់ពូជ:

-ត្រូវប្រយ័ត្នកុំឱ្យកញ្ចប់គ្រាប់ពូជទទឹកភ្លៀង ឬ នៅហាលថ្ងៃ ជាពិសេសនៅពេលដឹកតាមរថយន្តដែលមានឧបករណ៍វាស់ស្ទង់សីតុណភាព និង សំណើមក្នុងបន្ទប់ផ្ទុក ត្រូវប្រយ័ត្នកុំឱ្យកញ្ចប់គ្រាប់ពូជនៅក្រៅរង្វង់ត្រួតពិនិត្យរបស់ឧបករណ៍ខាងលើ ដែលអាចសំលាប់គ្រាប់បានដោយងាយ ។

-ប្រយ័ត្នកុំឱ្យជ្រុះបាត់ផ្លាកកត់ត្រាគ្រាប់ពូជនៅលើកញ្ចប់ ។

៤-ដំបូន្មានសំរាប់អ្នកទទួលភារះថ្នាល

-ត្រូវរក្សាទុកគ្រាប់ឱ្យបានល្អភ្លាម១ ក្រោយពេលទទួលបានគ្រាប់ដែលបានផ្តល់

-ត្រូវប្រយ័ត្នកុំឱ្យអ្នកយកគ្រាប់ទៅសាបបន្សល់គ្រាប់ ឬ ភ្លេចគ្រាប់នៅក្រៅស្បោងប្លាស្ទិច នៅលើថ្នាលសាប ឬ នៅហាលថ្ងៃ ដែលធ្វើឱ្យគ្រាប់ទាំងនោះអន់គុណភាព ឬ ខូចបាន ។



-ត្រូវប្រើស្បោងតូច១រំលែកគ្រាប់ចេញពីស្បោងធំ ដើម្បីបញ្ចៀសការស្រាយស្បោងធំច្រើនសារ ដែលនាំឱ្យគ្រាប់ដែលនៅសល់ក្នុងស្បោងធំកើនសំណើមបណ្តាលឱ្យខូច។



# ការបណ្តុះកូនឈើ

# ការបណ្ដុះកូនឈើ

## ១_ការរៀបចំថ្នាលបណ្ដុះកូនឈើ

### ១.១-ការជ្រើសរើសទីតាំងថ្នាល

ថ្នាលបណ្ដុះកូនឈើមានពីរប្រភេទ គឺថ្នាលបណ្ដុះកូនឈើអចិន្ត្រៃយ៍ និង ថ្នាលបណ្ដុះកូនឈើបណ្ដោះអាសន្ន។

**ក.ថ្នាលបណ្ដុះកូនឈើអចិន្ត្រៃយ៍:** ជាថ្នាលបណ្ដុះកូនឈើ ដែលមានលក្ខណៈទ្រង់ទ្រាយធំ ហើយអាចផលិតកូនឈើបានច្រើន និងអាចបណ្ដុះកូនឈើប្រភេទចំរុះ រួមមានកូនឈើរយៈពេលវែង រយៈពេលមធ្យម រយៈពេលខ្លី និង ឈើហូបផ្លែ។ ថ្នាលនេះសាងសង់ឡើងដោយមាន ការបំពាក់ប្រព័ន្ធស្រោចស្រព និង សំភារៈដែលអាចធានាការប្រើប្រាស់បានយូរអង្វែង។

ដូចនេះត្រូវជ្រើសទីតាំងថ្នាលបណ្ដុះដែលមានលក្ខណៈដូចតទៅ: ជាទីទួលរាបស្មើ មានពន្លឺ និងប្រភពទឹកគ្រប់គ្រាន់ មានផ្លូវអាចចេញចូលបានងាយស្រួល ជាតំបន់ដែល មានកំលាំងពលកម្មច្រើន និងជិតទីកន្លែងដាំឈើឡើងវិញ។ ក្នុងករណីជាតំបន់ខ្វះប្រភពទឹក យើងត្រូវជីកស្រះ ឬ អណ្ដូង ដើម្បីយកទឹកស្រោចស្រព។

ថ្នាលបណ្ដុះកូនឈើអចិន្ត្រៃយ៍



**ខ.ថ្នាលបណ្តុះកូនឈើបណ្តោះអាសន្ន៖** ជាថ្នាលបណ្តុះកូនឈើ មានទ្រង់ទ្រាយតូច មានលក្ខណៈងាយ និង ប្រើប្រាស់សំរាប់រយៈពេលខ្លី ហើយតំរូវទៅតាមស្ថានភាពជាក់ស្តែង សំរាប់ផ្គត់ផ្គង់ កូនឈើក្នុង បរិមាណតិច។

ដូចនេះត្រូវជ្រើសទីតាំងថ្នាលបណ្តុះ ដែលមានលក្ខណៈដូចតទៅ៖ ជាទីទួលរាបស្មើ មានពន្លឺ និង ប្រភពទឹកគ្រប់គ្រាន់ មានផ្លូវអាចចេញចូលបានងាយស្រួល និង ជិតទីកន្លែងដាំឈើឡើងវិញ។

ថ្នាលបណ្តុះកូនឈើបណ្តោះអាសន្ន



## ១.២-ការធ្វើរង

ក.រងសាបគ្រាប់ពូជៈ រងសាបគ្រាប់ពូជអាចជា រងផ្ទាល់ដី រងរៀបឥដ្ឋ និង រងស្ទូក។




**រងផ្ទាល់ដីៈ** រងផ្ទាល់ដីមានពីរប្រភេទទៀត គឺ រងពូនដី និង រងជីកដី។ រងពូនដីសំរាប់សាបគ្រាប់ពូជល្អិតៗ ដូចជាប្រេងខ្យល់ ដែលតំរូវឱ្យដីរងមានសភាពខ្សោះទឹកល្អ។
ឯរងជីកដីសំរាប់សាបគ្រាប់ពូជដែលត្រូវការសំណើមខ្ពស់ ដូចជាគ្រាប់ គគីរ។

**រងរៀបឥដ្ឋៈ** ជារងធ្វើអំពីឥដ្ឋប្រើបានយូរនៅក្នុងថ្នាលអចិន្ត្រៃយ៍ សំរាប់សាបគ្រាប់ពូជពិសេសឈើហូបផ្លែ។

**រងស្ទូកៈ** ធ្វើអំពីឈើ ប្រើសំរាប់សាបគ្រាប់ពូជតូចៗដូចជាប្រេងខ្យល់ ដែលងាយស្រមោចស៊ី ឬ ដុះផ្សិតក្នុងពេលដីសើមខ្លាំង ។

**ខ_រងសំរាប់រៀបថង់កូនឈើ:** អាចជា រងចងខ្សែ ឬ រងប្រើ បន្ទះក្តារ ឬ ឫស្សី ឬ លើកដីពូនបាំងទប់ថង់កូនឈើកុំឱ្យដួលរលំ ។




ពូនដីទប់ថង់ ប្រើក្តារទប់ធ្វើជារង ប្រើកឫស្សីទប់ធ្វើជារង

រងរៀបថង់កូនឈើដោយប្រើ ខ្សែចង ឬ បន្ទះក្តារ ឬ ឫស្សី ឬ លើកដីពូន បាំងទប់ថង់កូនឈើកុំឱ្យដួលរលំ គឺប្រើប្រាស់ក្នុងលក្ខខ័ណ្ឌ ដីបាតថ្នាលជាដីពិបាកជ្រាបទឹក ឬ មានសភាពសើមខ្លាំង និង អាចប្រើប្រាស់ទាំងក្នុងថ្នាលបណ្តោះអាសន្ន និង ថ្នាលអចិន្ត្រៃយ៍ ។ ក្នុងការធ្វើរងកូនឈើយើងត្រូវ :

-សំអាតគល់ស្មៅ ឬវល្លិ៍ ពីដីបាតថ្នាលមុនពេលធ្វើរង ព្រោះវាអាចស្រូបជីក្នុងថង់កូនឈើ ។

-ធ្វើចង្អូរដើម្បីបង្ហូរទឹកកុំឱ្យដក់នៅបាតថ្នាល ។

-រងកូនឈើត្រូវធ្វើជាជួរបណ្តោយថ្ងៃ ដើម្បីជួយឱ្យដីចន្លោះរងឆាប់ស្រស់ទឹកល្អ ។

## ១.៣-គំរូថ្នាល ឬ គំរូតាមរងនីមួយៗ

ក្នុងថ្នាលអចិន្ត្រៃយ៍គេធ្វើរោងស្បៃដែលមានលក្ខណៈ ខ្ពស់ស្រឡះ រឹងមាំល្អ និង ប្រើបានយូរ ។ សំរាប់ថ្នាលបណ្តោះអាសន្ន ឬ ថ្នាលបណ្តុះកូនឈើរបស់កសិករ គំរូថ្នាលអាចធ្វើ ក្នុងលក្ខណៈងាយៗ ពីបង្គោលឈើ ប្រក់ស្លឹកដូង ឬរបស់ផ្សេងៗទៀតទៅតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង ។



### ១.៩-ការធ្វើរបងព័ទ្ធជុំវិញថ្នាលបណ្តុះកូនឈើ

របងព័ទ្ធជុំវិញថ្នាលបណ្តុះកូនឈើមានពីរប្រភេទៈ គឺរបង និង របងរស់ ។

**របងៈ** ជារបងធ្វើអំពី បង្គោល ស៊ីម៉ង់ ត្រាក់ ឬស្សី ហ៊ុំព័ទ្ធជុំវិញដោយលួសបន្លា កូនឈើ ឬ បន្ទះឫស្សី។ល។ ប្រើប្រាស់សំរាប់ថ្នាលបណ្តុះកូនឈើបណ្តោះអាសន្ន ឬ ការរៀបចំថ្នាលបណ្តុះកូនឈើអចិន្ត្រៃយ៍ថ្មីៗ មុននឹងឈានទៅដាំដើមឈើធ្វើរបងរស់បាន។

**របងរស់ៈ** ជារបងដែលមានដាំដើមឈើព័ទ្ធជុំវិញបន្ថែមដើម្បីការពារខ្យល់បក់បោកដែលអាចបំផ្លិចបំផ្លាញកូនឈើដែលនៅក្នុងថ្នាល។ របងប្រភេទនេះសាងសង់ឡើងក្នុងទិសដៅសំរាប់ការពារកូនឈើដែលត្រូវផលិតច្រើន និង ជាយុទ្ធសាស្ត្រក្នុងការប្រើប្រាស់ ការពារថ្នាលបណ្តុះកូនឈើអចិន្ត្រៃយ៍ក្នុងរយៈ ពេលយូរអង្វែង។



## ១.៥-ប្រភពទឹក

ប្រភពទឹកដែលយើងយកមកប្រើប្រាស់សំរាប់ស្រោចស្រពកូនឈើមានៈ

-ទឹកនៅលើដី មានដូចជាប្រភពទឹកដែលបូមឬដងពី ទន្លេ ស្ទឹង អូរ ទឹកផុស បឹង ត្រពាំង ។ល។

-ទឹកក្រោមដី ជាទឹកដែលយើងយកបានពីអណ្តូងដៃ ឬ អណ្តូងស្នប់ តែទឹកបានមកពីប្រភពនេះច្រើនមានផលប៉ះពាល់ដល់កូនឈើ ដោយសារមានជាតិកំបោរ ។



## ១.៦-ជីកំប៉ុស្ត

### ១.៦.១.របៀបធ្វើជីកំប៉ុស្ត

ជីកំប៉ុស្ត គឺជាជីធម្មជាតិដែលផ្សំពីការរលួយ ឬ ពុកចូលគ្នានៃស្លឹកឈើ កំទេច ឬ សំបកឈើ អាចម៍រណារ សំបកបន្លែ ផ្លែឈើ ស្មៅស្រស់ ឬ ងាប់ ចំបើង កំប្លោក ចក ទន្រ្ទានខែត្រ លាមក គោ ក្របី ជ្រូក មាន់ ទា ផេះ និង កំទេចកំទីសំរាមដទៃទៀត ដែលងាយរលួយ។ ជីកំប៉ុស្តនេះ ធ្វើឱ្យដីធូរ មានគុណភាពល្អសំរាប់ដំណាំ និង រុក្ខជាតិ ហើយមានគុណភាពល្អជាងជីគីមី។ ដើម្បីធ្វើជីកំប៉ុស្តបានល្អ ត្រូវធ្វើទ្រុង ឬ ជង្រុកសំរាប់ដាក់សំរាមជាមុនសិន។




### ក-របៀបធ្វើទ្រុង ឬ ជង្រុកសំរាប់ផលិតជីកំប៉ុស្ត

អាចធ្វើបានច្រើនបែប ទៅតាមតំបន់ និង លទ្ធភាព ដូច ជាយក ឫស្សី មកត្បាញ ឬ វាយជាផ្ទាំង ឬ ប្រើស្លឹកកណ្តប់ជាសំភារៈ ដោយចំណាយអស់ថវិកាតិច។ របៀបធ្វើ គឺ យកបន្ទះ ឫស្សី ឬ ស្លឹកមកត្បាញ ឬ គ្រងវាយ ឬ ចងជាផ្ទាំងដោយទុកឱ្យមានចន្លោះអាចឱ្យខ្យល់ចេញចូលបាន ហើយផ្គុំគ្នាជាទ្រុងបួនជ្រុង ឬ មូលក៏បាន ហើយវាយបង្គោលនៅជ្រុងទាំងបួនទៅក្នុងដី រួចចងភ្ជាប់គ្នា ពេលនោះបង្កើតបានទ្រុងផលិតជីកំប៉ុស្តមួយ ដែលអាចប្រើប្រាស់បាន។

## ខ-របៀបផលិតជីកំប៉ុស្ត




នៅពេលសង់ជង្រុកបានហើយ ត្រូវប្រមូលសំរាមដែលមាននៅជុំវិញលំនៅស្ថាន ឬ ប្រមូលមកពីទីឆ្ងាយយកមកដាក់នៅក្នុងជង្រុកនេះដោយជ្រើសរើសយកតែប្រភេទសំរាម ដែលងាយរលួយយកមកធ្វើជីកំប៉ុស្ត។ ត្រូវកាប់ចិញ្ច្រាំសំរាមណាដែលធំៗ ឱ្យទៅជាបំណែកតូចៗ ដើម្បីឱ្យឆាប់រលួយទៅជាជី។ ត្រូវប្រមូលសំរាមមកចាក់ក្នុងទ្រុង ឬ ជង្រុកនេះជារៀងរាល់ថ្ងៃរហូតទាល់តែពេញ រួចហើយយកបាវចាស់ៗ ឬ ស្លឹកចេកទុំ និង ដីឥដ្ឋ ដីដំបូកវាយឱ្យម៉ដ្ឋមកគ្របពីលើ បន្ទាប់មកនៅរដូវក្តៅ ត្រូវដងទឹកចាក់ចូលទៅក្នុងជង្រុកនេះឱ្យបានញឹកញាប់ ដើម្បីឱ្យសំរាមឆាប់រលួយ ក្លាយជាជី។ បើនៅរដូវវស្សាមានភ្លៀងធ្លាក់ញឹកញាប់ពុំចាំបាច់ស្រោចទឹកទេ។ សំរាមក្នុងជង្រុកក្លាយជាជីក្នុងរយៈពេលពី៤ ទៅ ៦ខែ អាស្រ័យទៅនឹងវត្ថុធាតុដើម ឆាប់រលួយ ឬ មិនងាយរលួយ។

**<u>ចំណាំ</u>**: កំប្លោកគឺជាវត្ថុធាតុដើមមួយល្អបំផុតសំរាប់ធ្វើជីកំប៉ុស្ត ។

## គ-ការប្រមូលផលជីកំប៉ុស្ត



ពេលណាសំរាមស្រុតចុះបានន័យថា ជីចាប់ផ្តើមរលួយហើយ ។ ពេលបរិមាណសំរាមស្រុតដល់ពាក់កណ្តាលជង្រុកសន្មតថា ជីកំប៉ុស្តអាចយកមកប្រើបានហើយ ។

ត្រូវរែងជីយកកំទេចម៉ដ្ឋខ្មៅសំរាប់ប្រើ រើសយកសំរាមដែលមិនទាន់រលួយចេញ ហើយដាក់ទៅក្នុងជង្រុកថ្មីសំរាប់ធ្វើ ជីបន្តចំណែកវត្ថុធាតុដែលមិនអាចរលួយត្រូវយកចេញឆ្ងាយ ។

បើផ្ទាំង ឬ បន្ទះឫស្សី ឬ កន្ទេល កញ្ចប់ស្លឹកត្នោតនៅល្អ ត្រូវរើទ្រុងកំប៉ុស្តទៅតំឡើងនៅកន្លែងថ្មីក្បែរនោះសំរាប់ដាក់សំរាមធ្វើជីកំប៉ុស្តបន្តទៀត ។

<u>**គួរកត់សំគាល់ថា**</u> : នៅពេលរែងជី ប្រសិនបើនៅក្នុងជីមានសត្វល្អិតច្រើនគឺជាការល្អបំផុត ព្រោះថាសត្វល្អិតទាំងនេះវាជួយឱ្យសំរាមឆាប់រលួយ ហើយរក្សាជាតិសើមផង ។ បើឃើញមានសត្វដង្កូវដូងសូមយកចេញមុននឹងយកទៅប្រើដាក់ដំណាំ ។ ត្រូវយកវាទៅដាក់ក្នុងជង្រុកធ្វើជីថ្មី ព្រោះវាជួយជំរុញឱ្យសំរាមក្នុងជង្រុកឆាប់ក្លាយទៅជាជីកំប៉ុស្ត ។

## ១.៦.២_ការប្រើប្រាស់ជីកំប៉ុស្ត និង ផលប្រយោជន៍



-ល្បាយជីកំប៉ុស្ត៣០ភាគរយជាមួយដីធម្មតា៧០ភាគរយ អាចប្រើប្រាក់ក្នុងថង់ ឬ កន្ទោង សំរាប់បណ្តុះកូនឈើ ឬដំណាំផ្សេង។

-ប្រើជីកំប៉ុស្ត សំរាប់ដាក់ជុំវិញគល់កូនឈើ ឬ ដំណាំដូចជា ដើមផ្កា ល្ហុង ក្រូចឆ្មារ ស្ពៃ ប៉េងប៉ោះ ម្ទេស ខ្ទឹ និងបន្លែដទៃទៀត ( ត្រូវជ្រួយដីជុំវិញគល់នៅពេលដាក់ជីកំប៉ុស្ត ) ។

-ប្រើជីកំប៉ុស្តលាយជាមួយដីគីមី សំរាប់ដាក់ស្រែស្រូវដើម្បីជួយធ្វើឱ្យដីធូរ និងរក្សាជីគីមីឱ្យមានគុណភាពបានយូរ ធ្វើឱ្យស្រូវមានទិន្នផលខ្ពស់ រសជាតិឆ្ងាញ់។

-ប្រើជីកំប៉ុស្តក្នុងស្រះចិញ្ចឹមត្រី ដើម្បីជួយបង្កើតឱ្យមានសត្វល្អិតសំរាប់ជាចំណីត្រីស៊ីផងដែរ។

-ការធ្វើជីកំប៉ុស្តអាចជួយដល់សង្គមដូចជាៈ សំអាតបរិស្ថាន និង សន្សំសំចៃប្រាក់ពីការទិញជីគីមី សំរាប់យកទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃវិញ។

## ២-ការរៀបចំបណ្តុះ

### ២.១-ការរៀបចំថង់ដី

#### ក-ប្រភេទដី និង ការប្រព្រឹត្តិកម្មដី

ដីដែលអាចប្រើសំរាប់ច្រកថង់បណ្តុះកូនឈើមានដូចជា: ដីល្បាប់មាត់ទន្លេ-ស្ទឹង ដីល្បាប់បាតបឹង-ត្រពាំង ដីដំបូក ឬ ដីស្រទាប់លើក្នុងព្រៃ។ តែបើគ្មានដីទាំងអស់ខាងលើ យើងអាចយកដីធម្មតាលាយជាមួយអង្កាមដុត ឬ ដីអាចម៍គោ ឬ ដីកំប៉ុស្តទៅតាមសមាមាត្រគឺ ដីចំនួន ៦ភាគជាមួយដីអាចម៍គោឬអង្កាមដុតចំនួន១ភាគ និង កំប៉ុស្ត៣ភាគ។

ត្រូវវាយដីឱ្យម៉ដ្ឋ លាយជាមួយដីដូចខាងលើឱ្យបានសព្វល្អ រួចយកទៅហាលថ្ងៃដោយរីឱ្យស្មើកំរាស់៤ធ្នាប់និងស្រោចទឹកផ្សើមបន្តិច រយៈពេលមួយថ្ងៃពេញ ទើបប្រមូលគរ យកគងកោស៊ូគ្របទុក។





Farmers' Tree Planting Manual, 2003
Producers: CTSP-DANIDA, GTZ-CGFP, DFW, JICA, PRASAC

## ខ-ការជ្រើសរើសថង់ និង ចោះថង់

-ត្រូវជ្រើសរើសទំហំថង់ទៅតាមប្រភេទកូនឈើត្រូវបណ្តុះ៖ កូនឈើបណ្តុះរយៈពេលខ្លី ប្រើថង់ទំហំ៩គុណ១៦សង្ទីម៉ែត្រ រយៈពេលមធ្យម និង វែងប្រើទំហំ១៥ គុណ២៥សង្ទីម៉ែត្រ ។តែរយៈពេលវែងទាមទារការផ្លាស់ថង់មួយដង ឬ ពីរដងក្នុងពេលថែទាំនៅថ្នាល ។ពូជឈើក្នុងព្រៃល្បោះខ្សាច់ត្រូវការថង់វែងដើម្បីឱ្យបានឫសវែង ពេលដាំមានលទ្ធភាពទប់ទល់រដូវប្រាំង ។

-កសិករអាចច្នៃប្រើថង់ប្លាស្ទិចដែលវេចខ្ចប់ទំនិញមកពីផ្សារ ឬ របស់ផ្សេងទៀតដូចជាបំពង់ទឹកត្នោតចាស់ៗជាដើម សំរាប់បណ្តុះកូនឈើ ។

-សំភារៈសំរាប់ច្រកដីបណ្តុះកូនឈើ ត្រូវចោះរន្ធ ដើម្បីកុំឱ្យទឹកនៅដក់រលួយកូនឈើ ។



## គ-របៀបច្រកដីក្នុងថង់

-ផ្សើមល្បាយដីដែលធ្វើប្រព្រឹត្តិកម្មរួចដោយទឹកបន្តិច

-ច្រកដីដែលបានរៀបចំរួចនោះចូលទៅក្នុងថង់ ដែលបានកាត់គូទរួច ដោយប្រើស្លាកចូក ឬ ក្បង់ដោយដៃ។

-ជញ្ជូន និង រៀបថង់ដីទៅក្នុងរងដោយដាក់ឱ្យឈរត្រង់ល្អ និង មានជួរបន្ទាត់ងាយរាប់។

-បន្ទាប់មកត្រូវស្រោចទឹកឱ្យបានជោគដោយធុងស្រោចដែលមានក្បាលផ្កាឈូក។



## ២.២-ការធ្វើប្រព្រឹត្តិកម្មគ្រាប់ពូជ

ប្រព្រឹត្តិកម្មគ្រាប់ជាវិធីជួយឱ្យគ្រាប់ដុះ ក្នុងបំណង:

-ជួយជំរុញឱ្យគ្រាប់ឆាប់ដុះ

-ធ្វើឱ្យកូនឈើដុះបានស្រុះគ្នា ហើយរហ័ស

-កាត់បន្ថយពេលវេលាដែលអាចឆ្លងជំងឺ ឬ វិបត្តិផ្សេងៗរបស់គ្រាប់ឱ្យមានតិចបំផុត។

ប្រព្រឹត្តិកម្មគ្រាប់ពូជឈើ អាចធ្វើតាមរបៀបជាច្រើន អាស្រ័យទៅតាមប្រភេទគ្រាប់ដូចជា គ្រាប់ឈើដែលអាចរក្សាទុកបានយូរ និង គ្រាប់ឈើដែលឆាប់ខូច ម្យ៉ាងទៀតអាស្រ័យទៅតាមលក្ខណៈ សំបកគ្រាប់ស្តើង ឬ ក្រាស់ ឆាប់ជ្រាបទឹក ឬ ពិបាក ទន់ ឬ រឹង។



គ្រាប់ទុកបានយូរ | គ្រាប់ឆាប់ខូច

ខាងក្រោមនេះជាប្រភេទប្រព្រឹត្តិកម្ម គ្រាប់ឈើងាយៗ ព្រមជាមួយឧទាហរណ៍

**ក-ប្រព្រឹត្តិកម្មដោយទឹកធម្មតាសំរាប់គ្រាប់ទុកបានយូរឆាប់ជ្រាបទឹក និង គ្រាប់ឆាប់ខូច**

ខាងក្រោមជាការងារជំណាក់ៗ

១-សំងួតគ្រាប់ក្រោមពន្លឺថ្ងៃមុនពេលត្រាំ (ហាលពួកគ្រាប់ដែលទុកបានយូរ តែពួកគ្រាប់ ដែលឆាប់ខូចមិនចាំបាច់ហាលថ្ងៃទេ តែត្រូវកាត់ស្លាបចេញ) ។

២-ត្រាំគ្រាប់ក្នុងទឹកធម្មតារយៈពេលពី១២-៤៨ម៉ោងអាស្រ័យតាមសំបកគ្រាប់ក្រាស់ ឬ ស្តើង

៣-លាងសំអាតគ្រាប់ជាមួយទឹកថ្មី ហើយដាក់ផ្អាប់គ្រាប់នោះក្នុងថង់ ឬ បាវក្រចៅសើម។

៤-ពិនិត្យ សំអាត ហើយផ្អាប់ទុកក្នុងថង់ ឬ បាវក្រចៅសើមវិញ ជារៀងរាល់ថ្ងៃ រហូតដល់ គ្រាប់ដុះពន្លក ទើបយកទៅស្ទូងក្នុងថង់ដី ឬ សាបក្នុងរង។

# ដំណើរធ្វើប្រព្រឹត្តិកម្មពពួកគ្រាប់ទុកបានយូរ




ដំណើរធ្វើប្រព្រឹត្តិកម្មពពួកគ្រាប់ធាប់ខ្ចប
ត្រាំទឹក
លាងស្អាត
បាវក្រចៅ
ផ្អាប់គ្រាប់
គ្រាប់ដុះពន្លក

ការធ្វើប្រព្រឹត្តិកម្មគ្រាប់ពូជនៃប្រភេទឈើនានាមានរាយក្នុងតារាងឧបសម្ព័ន្ធ១

**គួរចងចាំៈ**

- យើងអាចធ្វើប្រព្រឹត្តិកម្មដោយទឹកធម្មតាចំពោះពពួកគ្រាប់ទុកបានយូរតែមួយចំនួនទេ ចំពោះពពួកគ្រាប់ឆាប់ខូចត្រូវធ្វើប្រព្រឹត្តិកម្មដោយទឹកធម្មតាតែប៉ុណ្ណោះ ។
- ត្រូវចាប់គ្រាប់ដាក់ទៅក្នុងថង់ដីដោយថ្នម១ ដោយប្រើដង្កៀបចុងតូចចាប់ដែលមិនប៉ះពាល់ដល់ពន្លកឬស ។
- ត្រូវឧស្សាហ៍ពិនិត្យមើលគ្រាប់ផ្ទាប់ឱ្យបានញឹក នៅពេលដែលគ្រាប់ចាប់ផ្តើមចេញពន្លកឬស ដើម្បីកុំអោយពន្លកឬសដុះវែងជ្រុលពេក ។




- ត្រូវរក្សាទុកដាក់គ្រាប់ផ្ទាប់ដោយប្រុងប្រយ័ត្ននៅកន្លែងណា ដែលផុតពីដៃក្មេង ឬការបំផ្លាញពីសត្វ កកេរ ឬសត្វល្អិត ស្រមោច កណ្តៀរ... ។



## ខ-ប្រព្រឹត្តិកម្មដោយទឹកក្តៅ សំរាប់តែពពួកគ្រាប់ដែលអាចទុកបានយូរ

ខាងក្រោមជាការងារជំណាក់ៗ:

១-ហាលគ្រាប់ក្រោមកំដៅថ្ងៃ

២-ស្រុះ ឬ ត្រាំគ្រាប់ក្នុងទឹកក្តៅ

(ក្តៅតិចឬខ្លាំងអាស្រ័យប្រភេទគ្រាប់ មានបង្ហាញក្នុងតារាងឧបសម្ព័ន្ធ១)

៣-ការងារបន្តទៅទៀត: លាងសំអាត-ផ្ទាប់ មានដូចក្នុងប្រព្រឹត្តិកម្មដោយទឹកធម្មតាដែរ ។




ប្រព្រឹត្តិកម្មដោយទឹកក្តៅ ចាំបាច់សំរាប់ប្រភេទគ្រាប់ដូចជា: បេង កកោះ ត្រសេក អង្កាញ់ អាកាស្យា ... ។

### ឃ-ប្រព្រឹត្តិកម្មដោយឆាបសំបកគ្រាប់

១-កាត់ច្រឹប ឬ រូសសំបកគ្រាប់ ដោយប្រើកាំបិត ឬ កន្ត្រៃកាត់ក្រចក ក្រដាសខាត់ ឬ សំភារៈ គ្រើមដូចជាថ្មឆាប ដោយប្រយ័ត្នប្រយែងកុំអោយរបួសដល់ផ្នែកពន្លកគ្រាប់ ។ ត្រូវឱ្យដាច់ សំបកគ្រាប់ហើយដល់សាច់គ្រាប់តែបន្តិចបានហើយ ។




២-ត្រាំគ្រាប់ដែលបានកាប់សំបករួច ទៅក្នុងទឹកធម្មតាមួយយប់ ព្រឹកឡើងលាងសំអាត រួច ផ្ទាប់ និង តាមដានបន្តបន្ទាប់ដូចក្នុងប្រព្រឹត្តិកម្មដោយទឹកធម្មតាដែរ ។

អាចប្រើប្រព្រឹត្តិកម្មដោយឆាបសំបកគ្រាប់ ចំពោះតែពពួកគ្រាប់អាចទុកបានយូរ ដែលមាន សំបកក្រាស់ និងមានទំហំគ្រាប់ធំៗអាចកាន់ឆាប ឬកាប់បាន ដូចជា បេង កកោះ ជាដើម ។

## ២.៣.របៀបស្ទូងក្នុងថង់ដី

### ក-របៀបស្ទូងគ្រាប់ពូជឈើក្នុងថង់ដី

-ត្រូវស្រោចទឹកថង់ដីក្នុងរងឱ្យបានជោគដល់បាតថង់

-ត្រូវប្រើគ្រាប់ពូជឈើដែលបានធ្វើប្រព្រឹត្តិកម្មរួច មានដុះពន្លកបន្តិច មកស្ទូង

-ប្រើឈើ( ដូចរូប) ឬ ម្រាមចង្អុលដៃ ចុកដីជារណ្ដៅជំរៅស្មើទំហំគ្រាប់

-ដាក់គ្រាប់ ( គ្រាប់ដូចគ្រាប់ឈើទាលត្រូវដាក់ស្លាបផ្ដេក) រួចរោយដីសើរៗពីលើ

-គ្របចំបើង ឬ ស្មៅងាប់ ពីលើថង់ដែលបានដាក់គ្រាប់រួចហើយ

-ស្រោចទឹកស្រាលៗ ដោយប្រើធុងផ្កាឈូក ។

**ចំណាំ :**

+ត្រូវដាក់តំរុយចំណាំផ្នែករងដែលបានដាក់គ្រាប់រួចហើយ ចៀសវាងការច្រឡំ

+ត្រូវកត់ត្រាថ្ងៃខែចាប់បណ្ដុះទុក

+ដាក់ផ្លាកពីចំនួនថង់កូនឈើ ប្រភេទឈើ និង ថ្ងៃខែបណ្ដុះនៅតាមរង។



## ៤-របៀបស្ទូងកូនសំណាបក្នុងថង់

ការស្ទូងកូនសំណាបក្នុងថង់ ច្រើនប្រើចំពោះប្រភេទឈើដូចជា: ប្រេងខ្យល់ គគីរ ស្នាច់ ក្រញូង ត្រសេក ។ល។ ការងារ នេះមានពីរដំណាក់កាលគឺ សាបគ្រាប់ និង ស្ទូងកូនសំណាប ។

១-ការសាប

-គ្រាប់ពូជឈើដូចជា គគីរ ត្រាច ជាដើម ក្រោយពីប្រមូលត្រូវយកទៅសាបភ្លាមនៅលើរងសាបផ្ទាល់ដី (រងជីកដី) រួចគ្របចំបើង ស្រោចទឹក និង គ្របស្លឹកដូងធ្វើជាដំបូលរង ។

-ចំពោះប្រេងខ្យល់: យកគ្រាប់ប្រេងខ្យល់១ភាគ លាយដីខ្សាច់ម៉ដ្ឋ៣ភាគឱ្យសព្វ ដាក់ក្នុងកំប៉ុងម្រេចចាក់រោយលើរងសាប(រងពូនផ្ទាល់ដី ឬ ស្នូកដែលបានស្រោចទឹករួច)ឱ្យស្មើសាច់ល្អ (ប្រើគ្រាប់២០-២៥ក្រាមក្នុងផ្ទៃដីរងសាប១ម៉ែត្រការ៉េ) រួចរែងដីខ្សាច់ម៉ដ្ឋពីលើស្តើង បន្ទាប់មកបាញ់ទឹកដោយធុងបាញ់ថ្នាំឱ្យបានញឹកញាប់កុំឱ្យដីរងស្ងួត ។ត្រូវការពារដោយប្រុងប្រយ័ត្នចំពោះស្រមោចដោយប្រើថ្នាំ និង គ្របផ្លាស្ទិចពេលមេឃមានភ្លៀង រហូតដល់កូនឈើអាយុ ៣សប្តាហ៍ ។

២-ការស្ទូង

-ស្រោចទឹករងកូនសំណាបឱ្យជោក រួចដកយកកូនសំណាប ហើយត្រាំក្នុងថាសទឹក

-ស្រោចទឹកថង់ដីឱ្យជោក ចាក់ឈើច្រានឱ្យជ្រៅ ដាក់កូនឈើកុំឱ្យបត់ឫស រួចបិតដីស្រោចទឹក ។



## ឥ-ការបណ្តុះកូនឈើដោយប្រើកំណាត់មែក

ការកាត់បណ្តុះឫស ជាការផលិតកូនឈើចេញពីមែកឈើធំ ដែលមានវិធីអនុវត្តដូចតទៅ:

-ជ្រើសរើសយកមែកបំពង់ទំហំប៉ុនម្រាមដៃ មិនខ្ចីពេក តែមិនទាន់ចេញខ្នែងមែក ។

-កាត់ស្លឹកចេញ រួចកាត់ជាកំណាត់ៗ ( មានពីរៗថ្នាំងពី៨-១០ស.ម ) មុខកាត់ជាចំណិតត្រសក់ ។

-ស្ទូងកំណាត់មែក ក្នុងស្នូក ឬ ថង់ដី ( ករណីខ្លះគេប្រើថ្នាំបណ្តុះឫសជំនួយ ) ហើយថែរក្សាក្នុងម្លប់ និង ក្នុងកន្លែងរក្សាសំណើមល្អ ដូចជាប្រអប់ជិត ឬគ្របផ្លាស្ទិច ។




របៀបកាត់មែក និង សំអាតស្លឹកមុនពេលស្ទូង



ស្ទូងមែកក្នុងស្បោង




ស្ទូងមែកក្នុងស្នូក

## ៣.ការថែទាំកូនឈើនៅថ្នាលបណ្ដុះ

### ៣.១-ការស្រោចទឹកកូនឈើ

ពេលកូនឈើនៅតូច ត្រូវស្រោចទឹកពីរដងក្នុងមួយថ្ងៃ (ព្រឹក និង ល្ងាច) ទឹកជាមធ្យមមួយដង ពី២-៣លីត្រក្នុងមួយម៉ែត្រការ៉េ ។ នៅពេលកូនឈើធំត្រូវស្រោចទឹកក្នុងមួយថ្ងៃម្ដង ឬ ពីរថ្ងៃម្ដង ពី៤-៥លីត្រក្នុងមួយម៉ែត្រការ៉េក្នុងម្ដង ។ ពេលកូនឈើនៅតូច ត្រូវប្រើវិធីស្រោចដែលមានដំណក់ទឹកតូចៗ កុំឱ្យកូនឈើដួលក្រាបរលួយ ។




### ៣.២-ការបោចស្មៅ

-ស្រោចទឹកឱ្យជោកមុនពេលដក

-ដកដោយផ្ដេកដៃ

-ស្រោចទឹក ក្រោយពីដករួច



## ៣.៣ - ការបករំលោះកូនឈើ និង ស្ទូងជួស

នៅពេលកូនឈើក្នុងថង់ដល់អាយុឈប់ទទួលសារធាតុចិញ្ចឹមបំរុងរបស់វា ទើបអាចធ្វើការដករំលោះកូនឈើក្នុងថង់ និង ស្ទូងជួសថង់ទទេបាន។ ត្រូវអនុវត្តការងារតាមលំដាប់លំដោយដូចខាងក្រោម :



- ស្រោចទឹកថង់កូនឈើឱ្យជោក
- ដកកូនឈើពីថង់ដែលមានកូនឈើលើស (២ឬ៣ដើម)
- ត្រាំកូនឈើដែលបានដក ក្នុងថាសទឹក សំរាប់ប្រើស្ទូងថង់ទទេ
- ស្ទូងកូនឈើណាដែលថ្លោសល្អ ក្នុងថង់ទទេ
- ស្រោចទឹក និង គ្របពេលថ្ងៃ បើកនៅពេលយប់ ចំនួន២ថ្ងៃ។


Farmers' Tree Planting Manual, 2003
Producers: CTSP-DANIDA, GTZ-CGFP, DFW, JICA, PRASAC

### ៣.៤-ការកំចាត់សត្វល្អិត

-កំចាត់ដង្កូវ ឬ សត្វល្អិតចង្រៃដោយដៃ ឬ ប្រើថ្នាំពុលត្រាំពីរុក្ខជាតិល្វីង ជាវិធីល្អ ។

-ក្នុងករណីប្រើថ្នាំពុលគីមី ( ការបារីស ឬ មេតាហ្វូស ) ត្រូវប្រុងប្រយ័ត្ន ត្រូវប្រើនៅពេលល្ងាច និងមានសំភារៈការពារសុវត្ថិភាព ។




### ៣.៥-ការដាក់ជី

-ចាប់ដាក់ជីពេលកូនឈើអាយុ៤-៥សប្តាហ៍ ដោយមួយសប្តាហ៍ដាក់ជីម្តង ។ មុនពេលយកកូនឈើដាំ ២ ឬ ៣សប្តាហ៍ ត្រូវស្រោចជី អ៊ុយរ៉េ ដើម្បីជួយពង្រឹងដើម ។

-ក្រោយពេលស្រោចជីគីមីហើយភ្លាម ត្រូវស្រោចទឹកលាងជំរះស្លឹកកូនឈើ ។



## ៣.៦-ការកាត់ឫសកូនឈើធ្លាយថង់

កាត់ឫសដែលធ្លាយថង់ ដើម្បីកុំឱ្យវាចាក់ចូលដី រីកធំ ពេលដកកូនឈើទៅដាំ ឫសនោះដាច់នាំឱ្យកូនឈើអន់ ហើយងាប់ខូចប្រយោជន៏។ ហេតុនេះត្រូវៈ

-ចាប់ពីកូនឈើអាយុ៣ខែ ត្រូវតាមសង្កេតឫសកូនឈើ ដោយលើកកូនឈើមួយចំនួនចេញពីរង ដើម្បីពិនិត្យមើលឫសធ្លាយថង់។

-រើកូនឈើចេញពីរងហើយកាត់ឫស ចំពោះកូនឈើរយៈពេលវែង និង មធ្យម។ ក្រោយកាត់ឫស ត្រូវរៀបចូលរងវិញ ហើយស្រោចទឹក។



## ៣.៧-ការប្តូរថង់កូនឈើ

កូនឈើរយៈពេលវែង ទាមទារការប្តូរថង់ ដើម្បីឱ្យប្រព័ន្ធឫសរបស់វាលូតលាស់គ្រប់គ្រាន់អាចទប់ទល់ចិញ្ចឹមដើមបាននៅពេលយកទៅដាំនៅទីវាល។ ត្រូវប្តូរថង់នៅអាយុ ៦-៧ខែ ។



### ៣.៨-ការបើកលំហកូនឈើក្នុងថ្នាល

ការបើកលំហ ឬ ញែកថង់កូនឈើឱ្យទូលាយ ត្រូវធ្វើឡើងចំពោះកូនឈើដែលត្រូវថែរក្សាក្នុងថ្នាលរយៈពេលវែង។ ធ្វើដូច្នេះគឺដើម្បីឱ្យមានពន្លឺថ្ងៃចូលគ្រប់គ្រាន់ សម្លាប់ផ្សិត និង បាក់តេរីចង្រៃ ហើយកូនឈើមានដើមថ្លោស និងមានសភាពរឹងមាំល្អ ។

ក្នុងការបើកលំហ ជាដំបូងរើកូនឈើចេញពីរង ហើយរៀបជាថ្មីវិញ ឱ្យរង្វើលជាងមុន ហើយប្រើបន្ទះឬស្សី ឬ ធាងត្នោតឃាំងទប់ថង់កូនឈើ កុំឱ្យរលំ។




### ៣.៩-ការបង្កើនពន្លឺថ្ងៃ និង បន្ថយទឹក

កូនឈើនៅក្នុងថ្នាលត្រូវទំលាប់ឱ្យស៊ាំនឹងពន្លឺថ្ងៃព្រមទាំងភាពស្ងួត ដើម្បីឱ្យវាធន់នៅទីវាល ។ ត្រូវអនុវត្តការបង្កើនពន្លឺ និង បន្ថយទឹកដោយសន្សឹមៗច្រើនជំហាន ទុកពេលឱ្យកូនឈើអាចទទួលបាន ។



# ការចារដាំឈើ

# ការងារដាំឈើ

## ១.ការរៀបចំទីកន្លែងសំរាប់ដាំ

ការរៀបចំកន្លែងសំរាប់ដាំឈើ ជាការងារចាំបាច់ ដើម្បីផ្តល់លក្ខខណ្ឌសមស្របសំរាប់ឱ្យកូនឈើដែលដាំរួចដុះបានល្អ។ កិច្ចការនេះ ត្រូវធ្វើឱ្យបានចប់សព្វគ្រប់យ៉ាងហោចណាស់ត្រឹមខែ មិថុនា (ពិសាខ-ជេស)។

បច្ចេកទេសរៀបចំទីកន្លែងសំរាប់ដាំឈើ ប្រែប្រួលអាស្រ័យទៅតាមស្ថានភាពទីកន្លែង និងបំណងដាំឈើផ្សេងៗគ្នាដូចខាងក្រោម:

### ១.១-ចំពោះការដាំឈើជាចំការ

ជាទូទៅការងាររៀបចំទីកន្លែងសំរាប់ដាំឈើជាចំការ រួមមានការងារមួយចំនួនដូចខាងក្រោម :




**ផែនទីគំរោងដាំឈើរបស់សហគមន៍**

### ក- ការកំណត់ទីតាំង និង ទំហំដីដាំ

យើងត្រូវកំណត់យកទីតាំងដាំឈើជាឡូត៍ប្រចាំឆ្នាំ តាមលំដាប់លំដោយជាប់ៗគ្នាពី មួយឆ្នាំទៅមួយឆ្នាំ និងត្រូវឱ្យឡូត៍មានរាងស្មើរបួនជ្រុងស្មើផង ដើម្បីឱ្យកូនឈើនៅជុំងាយស្រួលគ្រប់គ្រងថែរក្សា។ ទំហំដីឡូត៍ត្រូវគិតចេញពីចំនួនកូនឈើដែលយើងមានសំរាប់ដាំក្នុងមួយឆ្នាំ។ ឧបមាថា យើងមានកូនឈើ ៥ ០០០ដើម ហើយត្រូវដាំជាមធ្យមក្នុងមួយហិកតា ២ ៥០០ដើម នោះយើងត្រូវរៀបចំដី ចំនួន ២ ហិកតា។

### ខ-ការរៀបចំផ្លូវភ្លើង និង ផ្លូវដឹកជញ្ជូន



យើងត្រូវរៀបចំធ្វើផ្លូវភ្លើងជុំវិញឡូត៍ប្រចាំឆ្នាំនីមួយៗ ទំហំយ៉ាងហោចណាស់ ៥ម ដោយធ្វើការកាប់គាស់-ឆ្ការឱ្យបានស្អាតទៅតាមទីកន្លែងដែលសំបូរសារធាតុងាយឆេះ ។ ផ្លូវភ្លើងនេះអាចប្រើប្រាស់ជាផ្លូវដឹកជញ្ជូនបានដែរ ។ ប្រសិនបើគំរោងដាំឈើរបស់សហគមន៍អាចមានដល់១០០ហិកតាក្នុងមួយឆ្នាំ នោះត្រូវធ្វើផ្លូវភ្លើងកាត់ខ្វែងចំកណ្តាលឡូត៍ប្រចាំឆ្នាំថែមទៀត ។

### គ-ធ្វើប្រឡាយបង្ហូរទឹក ឬ ប្រឡាយបញ្ចេញទឹក

ក្នុងករណីខ្លះដែលសណ្ឋានដីនៃទីកន្លែងដាំឈើ អាចមានទឹកដក់រយៈពេលយូរ ដូច្នេះចាំបាច់ត្រូវធ្វើប្រឡាយបង្ហូរទឹកចេញដូចរូបភាពខាងក្រោម ។




### ឃ-ត្រូវសំអាតទីកន្លែងដាំ និង ឈូសឆាយគូរវាស់ដី

### ង-ទាញខ្សែវាយច្បោះ កាប់រណ្តៅ

ចំពោះដីចំការដាំឈើដែលមានលក្ខណៈវាលស្រឡះល្អ ។ ការងារទាញខ្សែវាយច្បោះកាប់រណ្តៅគឺជួយឱ្យកូនឈើដាំរួចរត់ជួរល្អ ងាយស្រួលក្នុងការសំអាតរុក្ខជាតិ ចង្រៃ និងការធ្វើអនាម័យព្រៃ ។

### ច-ការធ្វើរបងចំការ

ធ្វើរបង គឺដើម្បីការពារកូនឈើកុំមានការបំផ្លិចបំផ្លាញពីសត្វពាហនៈ ។ ការធ្វើរបង ត្រូវថ្លៃទៅតាមលទ្ធភាពដែលមូលដ្ឋានអាចរកបាន( ចំនុចនេះមានរៀបរាប់លំអិតក្នុងការថែទាំកូនឈើនៅទីវាលក្នុងជំពូកបច្ចេកទេស) ។

បច្ចេកទេសរៀបចំទីកន្លែងដាំឈើជាចំការប្រែប្រួលទៅតាមស្ថានភាពទីកន្លែងជាក់ស្តែងដូចជាៈ

### ១.១.១ .ការដាំឈើជាចំការនៅលើដីរាប

(សំរាប់ដីខ្សាច់ដីជាតិ មានដុះតែរុក្ខជាតិបន្លាតូចៗ និង ស្មៅ)

-ត្រូវកំណត់ពីទំហំដីត្រូវដាំ និងគិតអត្រាកូនឈើដាំក្នុងមួយហិកតា( ឧទាហរណ៏៣ ៣០០ដើម )

-ត្រូវធ្វើប្រឡាយបង្ហូរទឹកចេញពីកន្លែងដែលមានទឹកដក់រយះពេលយូរ

-គួរធ្វើការឈូសឆាយ និង ភ្ជួររាស់ដីបើមានលទ្ធភាព

-ត្រូវទាញខ្សែវាយចៀរ និង កាប់រណ្តៅឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស

-គួរដាំកូនឈើលើដីប្រភេទនេះក្នុងគំលាតពីជួរមួយទៅជួរមួយចំងាយ ១.៥-២ម និង គំលាតពីដើមមួយទៅដើមមួយ១.៥-២ម ។

-ត្រូវការពារ ឬ ធ្វើរបងការពារសត្វពាហនៈក្នុងករណីចាំបាច់ និង តាមលទ្ធភាព ។



### ១.១.២-ការដាំឈើជាចំការលើដីដុះស្បូវឬស្មៅច្រើន

-ត្រូវកំណត់យក ទំហំដីដាំ ដោយគិតចំនួនកូនឈើជាមធ្យមក្នុងមួយហិកតា ពី ២ ៥០០ ទៅ ៥០០០ដើម ទើបកូនឈើអាចដុះ លូតលាស់ទប់ទល់ និង កំចាត់ស្មៅ-ស្បូវបាន។

-ត្រូវធ្វើផ្លូវភ្លើងឱ្យបានស្រឡះល្អព័ទ្ធជុំវិញចំការឈើ ទំហំពី៦-១០ម។ គួរដាំប្រភេទឈើងាយលូតលាស់ និង បៃតងជានិច្ច ឬប្រភេទឈើដែលមានសំបកក្រាស់ ធ្វើជារបាំងការពារភ្លើងកាន់តែប្រសើរ។



-ត្រូវកាប់សំអាតស្បូវ ស្មៅ។ ក្នុងការដាំព្រៃជាចំការឈើរដ្ឋ ដែលមានទ្រង់ទ្រាយធំ គេអនុវត្តការភ្ជួររាស់ដោយត្រាក់ទ័រ ទៅលើផ្ទៃចំការទាំងមូល។ តែសហគមន៍អាចកាប់សំអាតស្បូវ និងភ្ជួរផ្លាក់ដីជាប្រឡោះៗ ទំហំពី ២-២,៥ម៉ែត្រ សំរាប់ដាំកូនឈើ ២-៣ជួរ និង ទុកចន្លោះរវាងប្រឡោះនីមួយៗ ២ឬ១,៥ម៉ែត្រ។ ត្រូវកាប់សំអាតស្បូវឱ្យបានស្អាតល្អ ទើបកូនឈើលូតលាស់បានល្អ។ មានបាញ់ថ្នាំកំចាត់ស្មៅ ឬ ស្បូវ តែប្រើបាញ់តែស្បូវខ្ចីៗ ប្រសិនស្បូវចាស់ត្រូវច្រូតឱ្យលាស់ត្រួយខ្ចីទើបបាញ់ថ្នាំរួចសង្កត់ ឬ ជាន់ឱ្យរាបពេលវាងាប់។ កាន់តែប្រសើរពេលដាំកូនឈើត្រូវកាប់រណ្ដៅធំៗ ហើយជជុសយកគល់ស្បូវឱ្យអស់ ។




១-ឆ្ការសំអាតជាប្រឡោះ



២-ភ្ជួរ ឬ កាប់ផ្កាក់តាមប្រឡោះ



៣-សង្កត់ស្បូវដោយអន្ទូបតាមចន្លោះប្រឡោះ



៤-ដាំកូនឈើ ពីរ ឬ បីជួរ ក្នុងមួយប្រឡោះ

### ១_១_៣_ការដាំឈើជាចំការនៅចន្លោះព្រៃ






ការដាំឈើឡើងវិញលើដីប្រភេទនេះ គឺដើម្បីបង្កើនបរិមាណព្រៃបន្ថែមទៅលើប្រភេទឈើមានប្រយោជន៍មួយចំនួនដែលមានស្រាប់នៅក្នុងដែនដីព្រៃរេចរឹល ។ ដូច្នេះការរៀបចំទីកន្លែងដាំ ត្រូវធ្វើទៅតាមកន្លែងចន្លោះដែលគ្មានដើមឈើ ឬកន្លែងដែលគ្មានដើមឈើមានប្រយោជន៍ដុះ ។

ការកាប់ឆ្ការបើកប្រឡោះព្រៃដើម្បីដាំឈើឡើងវិញនេះ ត្រូវគិតបន្សល់ទុកដើមឈើណាដែលមានប្រយោជន៍ ហើយកាប់រណ្តៅដាំកូនឈើឱ្យស្ថិតនៅចន្លោះដើមឈើដែលបានបន្សល់ទុកនោះតាមខ្នាតបច្ចេកទេសដែលបានត្រៀមទុក ។ ដូចនេះ មិនចាំបាច់គំរង់ជួររណ្តៅកូនឈើទេ ។

ក្នុងករណី មានដើមឈើដែលបានបន្សល់ទុកមានមែកសាខា ហើយចាំបាច់ត្រូវដាំកូនឈើឡើងវិញនៅក្បែរនោះ ត្រូវកាប់ ឬ លះមែកវាចោលខ្លះដើម្បីបើកពន្លឺ និង ឱ្យទឹកសន្សើមចូលដល់កូនឈើដែលទើបដាំរួចរីកលូតលាស់បានល្អ ។



### ១.១.៤.ការដាំឈើជាចំការនៅលើដីព្រៃគុម្ពោត

រុក្ខជាតិព្រៃគុម្ពោតមានពពួក ពួច ឃ្លាស ឃ្លាយ ។ល។ ភាគច្រើនគឺមិនសូវរំខានដល់ការលូតលាស់របស់ប្រភេទពូជឈើធំៗដែលត្រូវធ្វើការដាំឡើងវិញទេ។ ដូច្នេះការកាប់ឆ្ការដើម្បីបើកប្រឡោះព្រៃ អាចធ្វើទៅតាមជួរនីមួយៗ ដោយបើកចន្លោះត្រឹមតែអាចចូលកាប់រណ្តៅ និង ដាំកូនឈើបាន។



ការដាំឈើឡើងវិញនៅលើដីប្រភេទនេះ ត្រូវដាំឱ្យបានស្មើសព្វកន្លែង ដោយប្រើគំលាតដាំមិនតូចជាង ២×២ម ហើយកូនឈើមានចំនួនយ៉ាងច្រើន ២៥០០ដើមក្នុងមួយហិកតា។ ត្រូវប្រើបង្គោលឆ្លុះវាយច្បោះឱ្យបានខ្ពស់ជាងគម្ពោតព្រៃ និង មានចំនួនយ៉ាងតិចបីដើមដើម្បីតំរង់ជួរកាប់រណ្តៅ ហើយប្រើបន្ទះ ឫស្សី ឬ ប្រើដំបងស្មានធ្វើជាខ្នាតសំរាប់កាប់រណ្តៅ។



### ១.២ -ចំពោះការដាំឈើជារបាំងការពារខ្យល់

ការដាំដើមឈើជារបាំងការពារខ្យល់ត្រូវដាំចំរុះពូជឈើរួមមាន: ប្រភេទពូជឈើ ដើមខ្ពស់ ដើមមធ្យម និង ពពួកគុម្ពព្រឹក្ស។ សមាមាត្រត្រូវដាំមាន ប្រភេទពូជឈើដើមខ្ពស់១៥% ពូជឈើខ្ពស់មធ្យម ២០% និង ពូជឈើគុម្ពព្រឹក្ស ៦៥%។

ពូជឈើដើមខ្ពស់ និងមធ្យម គួរតែជ្រើសរើសយកមកដាំតែប្រភេទណាដែល :

-រឹងមាំធន់នឹងខ្យល់ (មែកស្វិត)

-អាចលូតលាស់បានឆាប់រហ័ស

-មានលទ្ធភាពដុះខ្នែង

-មានសារៈសំខាន់ខាងសេដ្ឋកិច្ច

-មិនគួរជ្រើសរើសដាំនូវប្រភេទឈើដែលមានសំណុំស្លឹកខាងលើធ្ងន់ពេកទេ។

ការដាំឈើសំរាប់ជារបាំងខ្យល់ដែលសមស្រប គឺត្រូវដាំឱ្យមានសភាពណែននៅស្រទាប់ក្រោម ស្រទាប់កណ្តាលឱ្យមានសភាពណែនល្មម និងឱ្យមានសភាពរង្វើលនៅស្រទាប់ខាងលើ ដើម្បីជួយសំរួលចរន្តខ្យល់កុំឱ្យបក់វិលវល់នៅពីក្រោយរបាំងព្រៃ ចំពោះចំនួនជួរដើមឈើត្រូវដាំចាប់ពី ១-៥ ជួរ។



ការដាំដើមឈើជារបាំងខ្យល់គឺដាំចាប់ពី ៥ជួរឡើងទៅ គឺសំរាប់ទប់ទល់ខ្យល់ខ្លាំងដោយផ្ទាល់ហៅថា របាំងខ្យល់ចំបង ហើយរបាំងខ្យល់នេះត្រូវដាំចន្លោះពីមួយទៅមួយចំងាយពី៣០០-៤០០ម ។ ចំពោះការដាំដើមឈើជារបាំងពី១-៣ជួរកូនឈើ គឺសំរាប់ជារបាំងខ្យល់បន្ទាប់ ហើយត្រូវដាំនៅចន្លោះ និងស្រប ឬ កែង នឹងរបាំង ខ្យល់ចំបង។ ឧទា: អង្កាញ់ ស្រស់ ស្វារ ។ល។



ត្រូវដាំឱ្យមានគំលាតពី ១-១,៥ម ហើយត្រូវដាំជាលក្ខណះប្រមូលផ្តុំនូវប្រភេទឈើតែមួយមាន ចំនួនពី២-៧ដើម។ ចំណាំៈ ឈើប្រភេទដើមខ្ពស់ត្រូវដាំនៅជួរកណ្តាល ឈើប្រភេទដើមកំពស់មធ្យម និង ទាបពពួកគុម្ពព្រឹក្សដាំនៅសងខាង។



### ១.៣ -ចំពោះការដាំឈើតាមដងផ្លូវ

បច្ចុប្បន្នការអភិវឌ្ឍន៍ផ្លូវលំតាមជនបទ មានការរីកដុះដាលយ៉ាងខ្លាំងសំរាប់ជួយសំរួលដល់ការធ្វើចរាចររបស់ប្រជាជនមូលដ្ឋាន ។ ដូច្នេះការដាំឈើនៅតាមដងផ្លូវលំនេះមានសារៈសំខាន់ណាស់ គឺជួយឱ្យមានសោភ័ណភាពតាមដងផ្លូវ ផ្តល់ម្លប់ ទប់ទល់ការហូរច្រោះបាក់ផ្លូវ ។ល ។(រូបក) ។

ដូច្នេះប្រជាជនមូលដ្ឋាន ត្រូវយល់ដឹងអំពីសារៈប្រយោជន៍នេះ និងបច្ចេកទេសមួយចំនួនក្នុងការដាំឈើតាមដងផ្លូវលំដូចខាងក្រោម:

-ត្រូវចាប់ផ្តើមដំណើរការដាំឈើឱ្យបាននៅដើមរដូវវស្សា ក្នុងអំឡុងខែ ពិសាខ-ជេស ឬ ឧសភា-មិថុនា ។

-ត្រូវដាំពីពាក់កណ្តាលជើងទេរនៃផ្លូវចុះមកខាងក្រោម មានគំលាតដាំពីដើមមួយទៅដើមមួយចំងាយ២-៣ម ចំពោះកូនឈើជាពូជឈើដែលពុំមានសំណុំស្លឹក ឬមែកធំៗ តែបើកូនឈើជាពូជធំមានមែកធំវែង (ដូចជាដើមគ្រាប់បែក) នោះត្រូវដាំខិតមកជិតជើងទេរខាងក្រោមនៃផ្លូវ (លើដីចំណីផ្លូវ) ហើយបើចំនុចដែលដាំស្ថិតចំដីស្រែ ឬ ទីមានដក់ទឹកនោះត្រូវលើកដីពូន ដើម្បីដាំ ក្នុងករណីបែបនេះកូនឈើត្រូវដាំមានគំលាតពីមួយទៅមួយចំងាយពី៣-៦ម (រូបខ) ។



-មិនគួរដាំកូនឈើនៅផ្នែកខាងក្នុងនៃផ្លូវកោងទេ ព្រោះអាចបាំងមើលមិនឃើញគ្នាពីម្ខាងទៅម្ខាងផ្លូវនៅពេលធ្វើចរាចរ ។

-ក្នុងការកាប់ជួររណ្តៅ ត្រូវទាញខ្សែឱ្យមានចំងាយស្មើគ្នាចេញពីពាក់កណ្តាលទ្រូងផ្លូវទៅជួរសងខាង (ទាញខ្សែឱ្យកែងនឹងខ្សែចិញ្ចើមផ្លូវ) សំរាប់បោះបង្គោលទាញខ្សែតំរង់ជួររណ្តៅ និងកូនឈើ ។ ធ្វើយ៉ាងនេះដើម្បីឱ្យកូនឈើដាំរត់ជួរបានល្អ និង បត់បែនស្របតាមដងផ្លូវ ។

-ចាំបាច់ត្រូវត្រៀមស៊ុមកូនឈើឱ្យបានគ្រប់ចំនួនសំរាប់កូនឈើដែលត្រូវដាំ ។



## ១.៩-ចំពោះការដាំឈើដើម្បីបង្កើតម្លប់លើវាលស្មៅ

ការដាំដើមឈើដើម្បីយកម្លប់ត្រូវរៀបចំទីកន្លែងដាំដូចខាងក្រោម :

-រៀបចំដីសំរាប់ដាំដើមឈើជាក្រុមៗ ពី ៩-១៦ដើម

-ចំងាយពីក្រុមមួយទៅក្រុមមួយមិនតិចជាង១០០ ម

-ត្រូវដាំគំលាតពីដើមមួយទៅដើមមួយទៀតចំងាយ ២ម ព្រោះកូនឈើដែលនៅតូចស្ថិតក្រោមកំដៅថ្ងៃខ្លាំងត្រូវការម្លប់ច្រើន។ តែដល់ពេលកូនឈើធំទើបអាចកាប់ដកហូតចេញមួយចំនួន។

-ត្រូវធ្វើរបងការពារកូនឈើដែលបានដាំរួចតាមក្រុមនីមួយៗជាចាំបាច់ ។



## ១.៥-ទំនោះការដាំដើមឈើដើម្បីការពារការហូរច្រោះ និង សំណឹក

### ១.៥.១.ការពារការហូរច្រោះតាមដងផ្លូវទឹក

នៅតាមច្រាំងនៃដងផ្លូវទឹកទាំងឡាយតែងទទួលរងនូវការហូរច្រោះ ឬ បាក់តិចឬច្រើនទៅតាមល្បឿននៃចរន្តទឹកដែលហូរខ្លាំង ឬ ខ្សោយ។ ដូច្នេះដើម្បីទប់ស្កាត់នូវរាល់ការហូរច្រោះ ឬ ការបាក់ច្រាំង ខាងលើដោយសារចរន្តទឹកនេះ ត្រូវតែដាំដើមឈើដែលសំបូរមែក និង មានប្រព័ន្ធឫសល្អនៅទីនោះតាម បច្ចេកទេសខាងក្រោម:




**តំបន់រងការហូរច្រោះ និង ដីដុះនៅតាមដងផ្លូវទឹកហូរ ( ទន្លេ ស្ទឹង អូរ ...)**

១-ត្រូវដាំដើមឈើដូចប្រភេទខាងលើដើម្បីទប់ស្កាត់ការហូរច្រោះ ឬ បាក់ច្រាំង នៅគ្រប់ទីកន្លែងទាំងអស់ ទាំងកន្លែងច្រាំងកំពុងបាក់ និង មិនទាន់បាក់ ព្រោះការបាក់ច្រាំងអាចរាលដាល។

-ក្នុងករណីទីកន្លែងច្រាំងដែលបាក់ខ្លាំង: ត្រូវមានវិធានការបណ្តោះអាសន្ន និង ជាបន្ទាន់យ៉ាងហោចណាស់ឱ្យបានមុន១ឆ្នាំដើម្បីឱ្យដីល្បប់ដុះសំរាប់ដាំដើមឈើការពារ ។ ត្រូវធ្វើការដាំដើមឈើនៅកន្លែងដីល្បាប់ដុះពីក្រោយសំរាស់ ដែលដាក់ការពារបណ្តោះអាសន្ន។





គំនូសបង្រួញសំគាល់



+ក្នុងករណើទីកន្លែងច្រាំងមិនបាក់ ឬ បាក់តិចៈ អាចដាំនៅលើជំរាលច្រាំងតែម្តង (រូប ក) ។ នៅកន្លែងច្រាំងមានរាងផត ត្រូវដាំដើមឈើជាជួរ មានទំរង់ជាស្លាបបញ្ចិតតាមបណ្តោយចរន្តទឹក ដើម្បីឱ្យមានដីដុះឡើងវិញនៅផ្នែកខាងក្រោមទឹក និង អាចធ្វើឱ្យផ្លូវទឹករួមតូចវិញបាន (រូប ខ) ។




២-ត្រូវដាំពពួកគុម្ពព្រឹក្សនៅស្រទាប់ក្រោម ហើយពពួកឈើធំនៅស្រទាប់លើ (រូប ក) ។

៣-ការដាំកូនឈើត្រូវប្រើគំលាត១×១ម ជាមធ្យមចំពោះ ប្រភេទគុម្ពព្រឹក្ស តែបើចំមុខចរន្តទឹកខ្លាំងវិញត្រូវតែដាំឱ្យបានញឹកនៅគ្រាដំបូង ។

៤-ត្រូវរួសរាន់ដាំដើមឈើដើម្បីការពារនេះនៅខែ វិច្ឆិកា-ធ្នូ ឬ ខែ កត្តិក-មិគ្គសិរ ។ ពីព្រោះប្រភេទរុក្ខជាតិដុះតាមផ្លូវទឹកនៅប្រទេសកម្ពុជាភាគច្រើនលាស់ត្រួយនៅរដូវប្រាំង ។

## ១.៥.២_ដាំដើមឈើដើម្បីការពារសំណឹកនៅទីជំរាល

១-ក្នុងករណីដាំដើមឈើដើម្បីការពារនៅទីកន្លែងជំរាលដែលមានរុក្ខជាតិខ្លះ  អាចធ្វើការដាំចំរុះ ជាមួយរុក្ខជាតិមានស្រាប់ ដោយដាំជាមុំចង្រ្កានមានជួរបន្ទាត់ដូចដាំនៅទីវាលរាបដែរ ។



២-ក្នុងករណីទីជំរាលដែលគ្មានរុក្ខជាតិសោះ ត្រូវអនុវត្តកិច្ចការមួយចំនួនដូចខាងក្រោម:

-កាប់ដីជាថ្នាក់ៗប្រវែងពី៤-៦ម  នៅតាមទីជំរាល  ពីមួយថ្នាក់ទៅមួយថ្នាក់២-៤ម  ហើយ រាយឆ្លាស់គ្នាជាមុំចង្រ្កាន ។



-កាប់មែកឈើតូចៗដាក់ និង បោះស្នឹងទប់ដើម្បីរក្សាកំណកដីសំរាប់កូនឈើដាំលើថ្នាក់នោះ

-ត្រូវដាំកូនឈើនៅក្បែរសំរាស់មែកឈើទាំងនោះ ។



## ១.៦-ចំពោះការដាំដើមឈើធ្វើជាចំណីសត្វ

-ការដាំដើមឈើសំរាប់ជាចំណីសត្វ ត្រូវប្រើកូនឈើដែលបណ្តុះតាមកំណាត់មែក។

-អាចដាំឈើជាចំណីសត្វ របៀបជាជួរនៅចន្លោះដំណាំ(រូបក) ឬ ដាំជាជួររបងតាមលំនៅដ្ឋាន ឬ តាមរបងចំការ និង ដាំរបៀបជាចំការសំរាប់ផ្គត់ផ្គង់ចំណីសត្វ ឬ លែងសត្វឱ្យស៊ីក្នុងនោះ តែម្តង។




**ការដាំដំណាំជាជួរឆ្លាស់ជាមួយដើមឈើចំណីសត្វ**




-ដាំជារងទទឹង ០,៥-១ម ក្នុងមួយរងត្រូវដាំពី ២-៣ជួរ និង ពីមួយដើមទៅមួយដើមមាន គំលាត ០,៥ម (រូប ខ) សំរាប់របៀបដាំឆ្លាស់ជាមួយដំណាំ ឬ ដាំជួររបង។

-ចំពោះរបៀបដាំជាចំការសំរាប់ផ្គត់ផ្គង់ចំណីសត្វ ត្រូវដាំជាគុម្ពៗ ពី៤-៥ដើម គំលាតពីដើមមួយទៅដើមមួយ០.៥-១ម ហើយពីគុម្ពមួយទៅគុម្ពមួយទៀតគឺ២-៣ម (រូប គ)។

-ចាំបាច់ត្រូវភ្ជួរ ឬ ផ្ទាក់ដីដែលត្រូវដាំឱ្យបានល្អ ដើម្បីឱ្យកូនឈើលូតលាស់បានល្អ។




រូប គ

## ១.៧ -ចំពោះការដាំឈើក្នុងប្រព័ន្ធកសិ -រុក្ខកម្ម

### ១.៧.១.ការអភិវឌ្ឍន៍ដីកសិកម្មនៅទីជំរាល

ដើម្បីជួយទប់ទល់នឹងសំណឹកតាមទីជំរាលដីដែលបានដាំដំណាំកសិកម្ម ត្រូវដាំឈើជាជួរនៅតាមថ្នាក់នៃទីជំរាលដើម្បីជួយទប់ ឬ បន្ថយចរន្តទឹកកុំឱ្យហូរច្រោះដី(រូប ក-ខ) ។



ដូច្នេះគប្បីអនុវត្តនូវវិធីសាស្ត្រមួយចំនួនដូចខាងក្រោម :

-ត្រូវដាំដើមឈើឱ្យស្ថិតនៅជាជួរតាមកំពស់ជិរាលស្មើគ្នា ហើយត្រូវធ្វើយ៉ាងណា ដើម្បីកុំឱ្យរបាំងនីមួយៗប្រមូលទឹកហូរចាក់ចូលទៅក្នុងជ្រលងធម្មជាតិ ដែលនាំឱ្យចរន្តទឹកហូរច្រោះកាន់តែខ្លាំង (រូប គ) ។

-គំលាតជួរដាំដើមឈើជារបាំងតាមជិរាល គិតតាមកំពស់ ពី ២-៣ម (រូប ឃ) ។




-ត្រូវដាំប្រភេទឈើគុម្ពព្រឹក្សពី២-៣ជួរក្នុង១ថ្នាក់ និង ដាំគំលាតពីដើមមួយទៅដើមមួយទៀតចំងាយ១ម ហើយដាំឆ្លាស់គ្នាជាទំរង់មុំចង្រ្កាន ដោយមានលាយជាមួយពូជឈើខ្ពស់ៗដែរ ។

-កូនឈើប្រភេទគម្ពោតព្រឹក្ស ជាកូនបានមកពីការបណ្តុះកំណាត់មែក ឬ អាចកាត់មែកយក មកដាំផ្ទាល់តែម្តង រីឯពូជឈើប្រភេទខ្ពស់ភាគច្រើនជាកូនឈើបានមកពីការបណ្តុះគ្រាប់ ។

### ១.៧.២.ការដាំដើមឈើចំរុះជាមួយដំណាំ ឬ ដាំចំរុះច្រើនស្រទាប់

ក្នុងករណីខ្លះ ការដាំឈើសំរាប់ជាម្លប់ដល់ដំណាំកសិកម្មមួយចំនួន។ បច្ចេកទេសនេះអនុវត្តជាពិសេសសំរាប់ការដាំដំណាំកសិកម្មនៅលើដីសំបូរស្មៅ ហើយចាំបាច់ត្រូវមានការផ្តល់ដំបូន្មានបន្ថែមពីអ្នកផ្សព្វផ្សាយព្រៃឈើ។ ត្រូវគិតគ្រោងជាមុនអំពី បរិស្ថាន និង សេដ្ឋកិច្ច ហើយត្រូវប្រើរយៈពេលច្រើនដើម្បីតាមដានផងដែរ។ ដូច្នេះត្រូវអនុវត្តនូវដំណាក់កាលដូចខាងក្រោម:

-ជាដំបូងត្រូវដាំដើមឈើដែលធន់នឹងកំដៅថ្ងៃខ្លាំង ហើយវានឹងក្លាយទៅជាដើមឈើសំរាប់ផ្តល់ម្លប់ ត្រូវដាំក្នុងគំលាត ពី ២-៣ម។

-ត្រូវដាំអន្តរដំណាំប្រចាំឆ្នាំនៅចន្លោះកូនឈើសំរាប់ផ្តល់ម្លប់

-អនុវត្តការដាក់ជី ធ្វើស្មៅ និង លោះមែកដើមឈើដាំផ្តល់ម្លប់នៅពេលដែលដើមឈើនេះមានម្លប់ខ្លាំងពេក។

-ធ្វើការកែលំអជាបន្តបន្ទាប់ដោយធ្វើការដកហូតចេញ ហើយរក្សាទុកនូវដើមឈើ ឬ ដំណាំណាដែលផ្តល់ផលច្រើនជាង។



## ២. របៀបកាប់រណ្តៅដាំកូនឈើ

-រណ្តៅគួរកាប់ឱ្យបានមុនការដាំយ៉ាងហោចណាស់មួយសប្តាហ៍ ដើម្បីឱ្យរណ្តៅដាំកូនឈើទទួលបានពន្លឺថ្ងៃជួយបំបែកសារធាតុសរីរាង្គនៅក្នុងរណ្តៅ និង សំលាប់មេរោគចង្រៃ ឬ ជំងឺផ្សេងៗ។

-ទំហំរណ្តៅត្រូវតែកាប់ឱ្យបានធំកាន់តែល្អ ដើម្បីជួយឱ្យឫសកូនឈើចាក់បានស្រួល និងស្រូបជីបានច្រើន។ ត្រូវជីកឱ្យបានយ៉ាងហោចទំហំ ៣តឹកបួនជ្រុង និង ជំរៅពី២-៣តឹក (រូប ក)។

-ត្រូវកាប់យកដីស្រទាប់ខាងលើដាក់មកជ្រុងម្ខាង ហើយស្រទាប់ដីក្រោមត្រូវដាក់ទៅជ្រុងម្ខាងទៀត និង ត្រូវកាប់បំផុសដីបាតរណ្តៅបន្ថែមទៀត (រូប ខ-គ)។

-ចំពោះរណ្តៅដាំកូនឈើនៅតាមទីជំរាល ឬ តាមជើងទេរផ្លូវ ត្រូវគិតជំរៅរណ្តៅពីមាត់រណ្តៅខាងក្រោម។(រូប ឃ)



## ៣.របៀបដាំកូនឈើក្នុងរណ្តៅ

-គួរដាក់ជីនៅបាតរណ្តៅ ប្រសិនបើអាចធ្វើទៅបាន ចំពោះដីដែលខ្សោះជីជាតិខ្លាំងពេក គឺ លាយដីស្រទាប់លើជាមួយជីកំប៉ុស្ត១គក្រ (រូប១) ចំពោះដីមានជីជាតិស្រាប់មិនចាំបាច់ប្រើជីជំនួយទេ។

-ត្រូវហែកថង់កូនឈើចេញថ្នមៗកុំឱ្យបែកដីមុនពេលដាក់កូនឈើទៅក្នុងរណ្តៅ (រូប២) ។

-ទប់កូនឈើក្នុងរណ្តៅឱ្យមានលំនឹងហើយកាយដីស្រទាប់ខាងលើ ឬ ដីដែលមានលាយជីរួចលប់មុនទើបកាយដីស្រទាប់ក្រោមលប់បំពេញរណ្តៅជាក្រោយ រួចសង្កត់ដោយដៃឱ្យណែនដើម្បីកុំឱ្យដីស្រុតផុតគល់កូនឈើនៅពេលមានភ្លៀង (រូប ៣ - ៤ - ៥) ។



-ត្រូវប្រយត្ន័ ដាក់កូនឈើដាំយ៉ាងណាឱ្យបានសមស្រប (រូប ៧) ។




-ត្រូវដោតចរឹងទប់កូនឈើ ការពារខ្យល់បក់បោកខ្លាំង អាចយោគរង្គើរខានដល់ការចាប់ឫស របស់កូនឈើទើបដាំ។ ត្រូវបោចស្មៅ ឬ ប្រមូលស្លឹកឈើងាប់គ្របគល់កូនឈើដើម្បីរក្សាសំណើមក្នុងដី (រូប ៨) ។



# ការថែទាំកូនឈើ

# ការថែទាំកូនឈើ

## ១.ការដាំជួសកូនឈើ

### ១.១ -ការគណនាភាគរយកូនឈើងាប់

-ដាក់តាំងឡូតិ៍គំរូយ៉ាងតិចចំនួន ៥ ក្នុង១ហិកតា (ស្មើនឹងផ្ទៃដី៥%ក្នុង១ហិកតា) ហើយឡូតិ៍នីមួយៗមានទំហំ ១០ម៉ែត្របួនជ្រុង ត្រូវជ្រើសរើសទីតាំងដាក់ឡូតិ៍គំរូដោយចៃដន្យ ឬ ពង្រាយតាមអង្កត់ទ្រូងចំការ ។




-រាប់ចំនួនកូនឈើងាប់ និង ចំនួនកូនឈើរស់ក្នុងឡូតិ៍គំរូនីមួយៗ។ កូនឈើដែលចាត់ទុកថាងាប់ គឺវាងាប់ស្ងួតជ្រុះស្លឹក រញួមទន់កជ្រុះស្លឹក បាក់ត្រឹមដើមមិនមានដុះខ្នែង បាត់ពីរណ្តៅ ឬ ភ្លេចមិនបានដាំ។



-ការគណនាភាគរយកូនឈើងាប់ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម :

$$* \text{ ភាគរយកូនឈើងាប់} = \frac{\text{ចំនួនកូនឈើងាប់គ្រប់ឡូតិ៍បូកចូលគ្នា} \times ១០០}{\text{ចំនួនកូនឈើទាំងងាប់ទាំងរស់គ្រប់ឡូតិ៍បូកចូលគ្នា}}$$

-ចំនួនកូនឈើដែលត្រូវយកមកដាំជួសគណនាតាមរូបមន្ត :

* ចំនួនកូនឈើត្រូវដាំជួស= ភាគរយកូនឈើងាប់ x ចំនួនកូនឈើដែលបានដាំពីមុន

**១.២ -ពេលវេលាសមស្របសំរាប់ការដាំជួស**

ត្រូវធ្វើការដាំជួសកូនឈើចំនួនពីរដងក្នុងឆ្នាំដាំ:

-លើកទីមួយ: ដាំជួសនៅក្រោយពេលដាំរួចរាល់កន្លងបាន១ខែ គឺច្រើនធ្វើក្នុងខែ ស្រាពណ៍ ឬ ភទ្របទ (ខែសីហា ឬកញ្ញា) ។

-លើកទីពីរ: ដាំជួសនៅក្រោយពេលដាំជួសលើកទី១ រួចកន្លងបាន១ខែ គឺច្រើនធ្វើនៅខែ អស្សុជ ឬកត្តិក (ខែ តុលា ឬ វិច្ឆិកា) ។

**១.៣ -របៀបដាំជួស**

មុននឹងដាំជួសត្រូវរកមើលមូលហេតុដែលបណ្តាលឱ្យកូនឈើងាប់ ហើយត្រូវដាំឡើងវិញឱ្យបាន សមទៅតាមករណីដែលកូនឈើបានងាប់ដូចជា:

-ការដាំពីមុនមិនបានល្អ ឬ កូនឈើអន់គុណភាព ត្រូវកាប់ស្តាររណ្តៅចាស់ហើយដាំសារជាថ្មី

-ត្រូវទទួលរងការបំផ្លាញដោយសារទឹកហូរច្រោះ ដូច្នេះការដាំឡើងវិញ ត្រូវដាំគេចឱ្យផុត ពីកន្លែងដែលហូរច្រោះនេះ ។

-កូនឈើងាប់ដោយសារការលាំទឹក ការដាំសារឡើងវិញត្រូវពូនដីត្រង់កន្លែងរណ្តៅចាស់ឱ្យផុត ពីផ្ទៃទឹក ហើយដាំជំនួសកូនឈើថ្មីឡើងវិញ ។



ការដាំជួសកន្លែងដែលមានការ
ហូរច្រោះបំផ្លាញកូនឈើ



ការដាំជួសកន្លែងដែលកូនឈើងាប់
ដោយសាររលាំទឹក

## ២. ការការពារកូនឈើពីសត្វពាហនៈបំផ្លាញ

ដើម្បីទប់ស្កាត់កូនឈើទើបដាំរួច ពីការបំផ្លាញដោយសត្វពាហនៈ គឺមានកិច្ចការចំនួនបីត្រូវធ្វើដូចខាងក្រោម :

### ២.១ -ការធ្វើរបងការពារ

-ត្រូវប្រើប្រាស់ធនធានដែលមានស្រាប់នៅមូលដ្ឋានដូចជា ឈើចរឹង ឫស្សី ធាងត្នោត និង ប្រើចំណងវល្លិ ផ្តៅ ល្អាក់ ជាដើម ដើម្បីយកមកធ្វើសុំព័ទ្ធកូនឈើហើយដោតឱ្យជាប់ទៅនឹងដី ។



-អាចប្រើដើមឬស្សី ឬ បន្លា ស្រាស់ជារបងជុំវិញចំការដើម្បីការពារសត្វពាហនៈ ប៉ុន្តែបើចង់ឱ្យរបងស្ថិតស្ថេរបានយូរអង្វែង គួរដាំរុក្ខជាតិមួយចំនួនបន្ថែមធ្វើជារបងរស់ដូចជាៈ ដើមដំបងយក្ស ដើមស្លែងក្របី ដើមរលួស ដើមឬស្សី។ល។





### ២.២-អប់រំចំពោះកុមារ ឬ ក្មេងឃ្វាលគោ

ចាស់ទុំក្នុងភូមិគឺជាបុគ្គលសំខាន់ក្នុងការអប់រំកុមារ ឬ ក្មេងឃ្វាលគោនៅក្នុងភូមិឱ្យយល់ដឹង និងចូលរួមក្នុងការការពារសត្វពាហនៈបំផ្លាញកូនឈើដូចជា:

-ត្រូវប្រាប់ដល់កុមារពីកន្លែងបានដាំឈើ និងពីកន្លែងដែលពួកកុមារគួរនាំគ្នាទៅឃ្វាលគោ

-ត្រូវហាមកុមារកុំឱ្យលែងគោឱ្យស៊ីនៅក្បែរ ឬ នៅក្នុងចំការដាំឈើនៅពេលកូនឈើនៅតូច

-ត្រូវពន្យល់កុមារឱ្យយល់ដឹងពីផលប្រយោជន៍ និងការចាំបាច់របស់ព្រៃឈើចំពោះអ្នកភូមិ។




### ២.៣-ប្រើនូវច្បាប់ទាំងឡាយរបស់ភូមិ ឬ សហគមន៍

មេភូមិ ឬ គណៈកម្មការអភិវឌ្ឍន៍ភូមិ រៀបចំពិភាក្សាប្រជាជនក្នុងភូមិស្តីពី ការរៀបចំបទបញ្ញាផ្ទៃក្នុង ឬ លក្ខន្តិកៈ ដើម្បីការពារផលប្រយោជន៍ទ្រព្យសម្បត្តិរបស់ប្រជាជនក្នុងភូមិ ក្នុងនោះរួមមានព្រៃឈើជាដើម។ បទបញ្ញា ឬ លក្ខន្តិកៈនេះត្រូវតែឱ្យមានការទទួលស្គាល់ពីអាជ្ញាធរឃុំ ឬ ខេត្ត ដើម្បីប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពក្នុងការដោះស្រាយវិវាទជាមួយប្រជាជននៅក្នុងភូមិ ក៏ដូចជានៅក្រៅភូមិ។

# ៣-ការការពារកូនឈើពីការបំផ្លាញដោយពពួកសត្វកកេរ កណ្ដៀរ ឬ ដង្កូវផ្សេងៗ

## ៣.១-បញ្ហា

-ការបំផ្លាញដោយពពួកសត្វកកេរមានសត្វទន្សាយ កណ្ដុរ ជាដើម ហើយការបំផ្លាញនេះច្រើនតែកាត់ដើម ឬកាត់អស់ត្រួយកូនឈើតែម្ដង។




-ការបំផ្លាញដោយពពួកសត្វល្អិតមានដង្កូវ ច្រើនតែបំផ្លាញនៅផ្នែកឫស ក្នុងដើម ឬ ស៊ីស្លឹកកូនឈើជាដើម ហើយសត្វកណ្ដៀរច្រើនតែបំផ្លាញកូនឈើដែលមានឫសស្រាប់។



### ៣.២-វិធានការ

-ជំរះស្មៅ និង កាប់ឆ្ការសំអាតក្នុងចំការកូនឈើ ជាការសំខាន់ ព្រោះវាជួយកាត់បន្ថយ ការបំផ្លាញដោយសត្វកកេរ និង សត្វល្អិតបានមួយកំរិត ។

-ត្រូវផលិតថ្នាំពុលដោយប្រើប្រាស់រុក្ខជាតិធម្មជាតិដែលមានជាតិល្វីងខ្លាំង និង ពុល (ស្លឹកស្ដៅ ស្លឹកស្លែងធំ ស្លឹកស្លែងតូច ស្លែងដងដឹង វល្លិ៍បណ្ដូលពេជ្រ។ល។) មកត្រាំទឹកក្នុងពាងរួចយកមកបាញ់ ឬ ប្រោះលើកូនឈើដើម្បីបំផ្លាញសត្វល្អិត ឬ កុំឱ្យពពួកសត្វកកេរមកបៀតបៀនបំផ្លាញកូនឈើបាន។ ត្រូវឈរនៅពីលើខ្យល់ និង ពាក់ម៉ាស់ក្នុងពេលកំពុងបាញ់ថ្នាំ ។



## ៤_ការការពារភ្លើងឆេះព្រៃ

### ៤.១-ការងារបង្ការភ្លើងឆេះព្រៃ

មានការងារពីរ ត្រូវធ្វើដើម្បីបង្ការភ្លើងឆេះព្រៃ ទី១ គឺត្រូវបង្កើតរបាំងការពារភ្លើង ដោយរៀបចំប្រព័ន្ធការពារកុំឱ្យមានការឆេះឆ្លងរាលដាលភ្លើងឆេះព្រៃពីខាងក្រៅចូលមកក្នុងចំការដាំឈើ ឬដើម្បីបង្ការភ្លើងកុំឱ្យឆេះរាលដាលពីចំការមួយទៅចំការមួយទៀត ហើយទី២គឺការងារជាមួយមនុស្សក្នុងមូលដ្ឋានពិសេសការអប់រំកុមារ ។

#### ក_ធ្វើរបាំងការពារភ្លើង ឬផ្លូវភ្លើង

១-កាប់ឆ្ការសំអាតព្រៃ ព្រិច ស្មៅ ឬ ស្មៅ ជាប្រឡោះទំហំពី២-៥ម៉ែត្រ ព័ទ្ធជុំវិញចំការដាំឈើ ដើម្បីធ្វើជាផ្លូវការពារភ្លើង ឬ ផ្លូវភ្លើង។ ត្រូវឆ្ការសំអាតផ្លូវភ្លើងនេះនៅចុងរដូវវស្សា ឬយ៉ាងហោចណាស់នៅចុងរដូវចំរូតឱ្យបានស្អាត ហើយប្រមូលសំរាមទាំងនេះចេញឱ្យឆ្ងាយ និងដុតចោលដោយប្រុងប្រយ័ត្ន។



២-ជ្រើសរើសយកពូជរុក្ខជាតិដែលមានពណ៌បៃតងជានិច្ច ឬ មានសំបកក្រាស់ ឬ សំបូរទឹកនៅក្នុងដើមនិងស្លឹក (ដើមដំបងយក្ស ល្ហុងខ្វង ដើមរំចេក។ល។) មកដាំព័ទ្ធជុំវិញចំការកូនឈើឱ្យបានមុនដើមរដូវវស្សា ឬ មួយឆ្នាំមុនពេលដាំកូនឈើ ដើម្បីបង្កើតជារបាំងធម្មជាតិបៃតងបង្ការភ្លើងឆេះចំការឈើ។ គួរប្រើរបៀបដាំដោយកំណាត់មែក ដើម្បីបង្កើតរបងបៃតងនេះជៀសវាងការចំណាយពេលវេលាយូរ។



៣-បង្កើតបន្ថែមរបាំងបៃតងនៅចន្លោះផ្លូវភ្លើង កាន់តែមានប្រសិទ្ធិភាព សំរាប់តំបន់ដែលសំបូរស្មៅដុះខ្ពស់ៗ។ ត្រូវអនុវត្តនៅដើមរដូវវស្សា ដោយសំអាតស្មៅទំហំពី៦-១០ម៉ែត្រទទឹង និង ដាំដើមឈើជារបាំងបៃតងនៅចន្លោះកណ្តាលចំនួន២-៣ជួរ។ នៅចុងរដូវវស្សាត្រូវសំអាតផ្លូវភ្លើងម្តងទៀត។



៤-អាចកែច្នៃប្រឡោះធម្មជាតិដែលមានស្រាប់ ទៅជារបាំងការពារភ្លើងតែម្តងដូចជា៖ ស្ទឹង អូរ ជ្រលងទឹកហូរ ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ជាដើម ដោយត្រូវសត្រាយចោលនូវរុក្ខជាតិងាប់ៗ ដែលងាយឆេះ។ ក្នុងករណីមានព្រៃដុះបៃតងជានិច្ចស្រាប់តាមជ្រលងទឹកហូរ គួរកែសំរួល ដោយសំអាតចេញនូវមែកឈើងាប់ៗ ឬ រុក្ខជាតិទាំងឡាយដែលងាយឆេះ។






### ខ_ការងារជាមួយមនុស្សក្នុងមូលដ្ឋាន

១-ត្រូវតែមានថែងពី វិធានការ និង ដំណោះស្រាយបញ្ហាភ្លើងឆេះព្រៃ នៅក្នុងបទបញ្ជាផ្ទៃក្នុង ឬ លក្ខន្តិកៈរបស់ភូមិ ឬ សហគមន៍។

២-មេភូមិ ចាស់ព្រឹទ្ធាចារ្យ និងឪពុកម្តាយ ជាអ្នកសំខាន់ ក្នុងការអប់រំកុមារ កុំឱ្យពួកគេប្រព្រឹត្តរឿងបង្កឱ្យភ្លើងឆេះព្រៃដូចជា:

-កុំទុកភ្លើងចោល ឱ្យឆេះនៅពេលយកឃ្មុំ

-កុំដុតព្រៃដើម្បីដេញចាប់សត្វ

-កុំដុតជញ្ជ្រាំង ឬ ស្មៅលេង ។ល។



## ៩.២ -ការពន្លត់ភ្លើងឆេះព្រៃ

ការពន្លត់ភ្លើងឆេះព្រៃជាកិច្ចការមួយលំបាក និងអាចមានគ្រោះថ្នាក់ ហេតុនេះអ្នកពន្លត់ភ្លើងឆេះព្រៃ នៅសហគមន៍មូលដ្ឋានត្រូវស្វែងយល់នូវចំណេះដឹងមួយចំនួនដូចខាងក្រោម :

### ក_ឧបករណ៍ជំនួយក្នុងការពន្លត់ភ្លើងព្រៃនៅមូលដ្ឋាន

-កាំបិតដងវែង ពូថៅ កណ្ដៀវ ប្រើសំរាប់កាប់មែកឈើស្រស់ទុកវាយពន្លត់ភ្លើង ឬ ប្រើសំរាប់កាប់ឆ្ការត្រាយប្រឡោះ ច្រូតស្មៅ ស្បូវ និង រុក្ខជាតិផ្សេងទៀត ដើម្បីធ្វើជាប្រឡោះទប់ស្កាត់ភ្លើងរាលដាល ។ ល ។

-ចបកាប់ រ៉ែល ត្រសេះ រនាស់ដៃ ប្រើសំរាប់កកាយដីជាប្រឡោះ ឬ ជីកដីបាចលើភ្លើងកំពុងឆេះ ឬ កាយមែកឈើ ស្បូវ ដែលកាប់ឆ្ការរួចចេញពីចំនុចដែលភ្លើងត្រូវឆេះរាលដាល ។ល ។

-ធុងទឹក សំបកបាវចាស់ៗប្រើសំរាប់ដងទឹកជញ្ជូន និង គ្របពន្លត់ភ្លើងឆេះ ។ ក្នុងករណីមានភ្លើងឆេះទ្រង់ទ្រាយធំបន្តិច រទេះគោ ឬ រទេះសេះជាមធ្យោបាយសំរាប់ដឹកទឹកមួយចាំបាច់ ។





## ខ.របៀបពន្លត់ភ្លើងឆេះព្រៃ

១-ការពន្លត់ភ្លើងដែលឆេះតែស្មៅទាបៗ ហើយមានសភាពខ្សោយៈ ត្រូវចូលពីខាងមុខភ្លើងជាមុន បន្ទាប់មកពន្លត់ពីចំហៀងភ្លើង និង ពន្លត់កន្ទុយភ្លើងជាក្រោយ ។



២-ការពន្លត់ភ្លើងព្រៃដែលមានសភាពខ្លាំង:

-ត្រូវពន្លត់ភ្លើងដោយប្រយោល ហើយត្រូវចូលពន្លត់ផ្ទាល់ពីជំហៀង និង ពីក្រោយភ្លើង ក្នុងស្ថានភាពដែលអំណោយផលល្អ។

-ត្រូវប្រើវិធីឆ្ការសំអាតស្មៅ-ស្បូវ ឬ កាយដីលប់ ដើម្បីបើកប្រឡោះកាត់ផ្តាច់កុំឱ្យភ្លើងឆេះរាលដាលបន្តទៀតបាន។



**គួរប្រុងប្រយ័ត្ន:**

-ពេលមានកំដៅថ្ងៃខ្លាំង មានខ្យល់បក់បោកខ្លាំង សំបូរធាតុឆេះ(ស្មៅខ្ពស់ ស្បូវងាប់ច្រើន។ល។) ព្រៃក្រាស់ និងតាមតំបន់ទីជំរាល ភ្លើងឆេះកាន់តែមានកំលាំងខ្លាំង ក្នុងករណីនេះ អ្នកពន្លត់ភ្លើងឆេះព្រៃត្រូវនៅឱ្យឆ្ងាយ ឬ ធ្វើសកម្មភាពដោយប្រយោល។

-ត្រូវកត់សំគាល់ទីកន្លែង ឬ ច្រកសំរាប់រំដោះខ្លួន ពេលកំពុងពន្លត់ភ្លើងឆេះព្រៃ ហើយត្រូវជួបភាពអាសន្ន។

-ត្រូវស្ថិតក្នុងទីតាំងជិតៗគ្នាដើម្បីពន្លត់ភ្លើងឆេះព្រៃ ដើម្បីកុំឱ្យភ្លើងឆេះរាលដាលត្រង់ចំនុចចន្លោះ គ្មានអ្នកពន្លត់។

## ៥_ការជំរះស្មៅ

ការជំរះស្មៅ ត្រូវអនុវត្តនៅឆ្នាំដំបូងមួយដង នៅពេលដែលអស់ទឹកភ្លៀងក្នុងខែ អស្សុជ-កត្តិក (ខែវិច្ឆិកា-ធ្នូ)។ នៅឆ្នាំបន្តបន្ទាប់ទៀតត្រូវជ្រួយដី ពូនគល់នៅដើមខែវស្សា ពិសាខ-ជេស្ឋ និង សំអាតរុក្ខជាតិឥតប្រយោជន៍ចោលម្តងទៀតនៅពេលអស់ទឹកភ្លៀង។

ការជំរះស្មៅ ជួយឱ្យកូនឈើបានស្រឡះពីការរួបរិតពីរុក្ខជាតិ និង កូនឈើឥតប្រយោជន៍ ហើយ ទទួលបានពន្លឺ និង សន្សើមគ្រប់គ្រាន់សំរាប់ការលូតលាស់។ ការសំអាតរុក្ខជាតិឥតប្រយោជន៍ចោល មានសារៈសំខាន់សំរាប់កូនឈើដូចជា:

- -គ្មានការប្រជែងស្រូបយកជីជាតិពីរុក្ខជាតិឥតប្រយោជន៍
- -កាត់បន្ថយការបំផ្លាញកូនឈើដោយសត្វល្អិតចង្រៃ
- -ពុំបង្កឱ្យមានភ្លើងឆេះរាលដាលបាន។



នៅពេលកូនឈើមានអាយុពី២-៤ឆ្នាំឡើងទៅ កូនឈើខ្លះត្រូវបានវល្លិ៍រួបរិតរំខាន ហេតុនេះត្រូវសំអាតវល្លិ៍ចេញដើម្បីឱ្យកូនឈើមានឱកាសលូតលាស់បានល្អ។



សំអាតវល្លិទោងកូនឈើ

## ៦. ការក្រីមែកដើមឈើ(កូនឈើ)

ការក្រីមែកធ្វើឡើងភាគច្រើនចំពោះដើមឈើក្នុងចំការកសិ-រុក្ខកម្ម ឬ ចំពោះដើមឈើដាំតាមជួររបងចំការ។ តែនៅក្នុងចំការដាំឈើសុទ្ធទុកឱ្យមានការក្រីមែកដោយធម្មជាតិ ឬ ក្រីមែកតែដើមឈើដែលនៅជាយខាងចំការ។ ដូច្នេះនៅពេលដំណាំដែលបានដាំចំរុះជាមួយដើមឈើត្រូវការពន្លឺ នោះត្រូវក្រីមែកដើមឈើចេញដើម្បីឱ្យដំណាំទទួលបានពន្លឺគ្រប់គ្រាន់។ ជាទូទៅ គេច្រើនក្រីមែកនៅរដូវដែលដើមឈើមានការលូតលាស់ខ្លាំង។

យើងប្រើឧបករណ៍ កាំបិត រណារ កន្ត្រៃដែលមុតល្អ និង ស្រួលកាត់សំរាប់ក្រីមែកកូនឈើ។ ការប្រើកាំបិតក្រីមែកត្រូវប្រុងប្រយត្ន័កុំឱ្យរយះដល់សាច់ដើមឈើ។ ត្រូវបន្សល់ទុកគល់មែកដែលក្រីត្រឹមពី១-២សង្ទីម៉ែត្រ។ ករណើក្រីមែកធំ(ឈើហូបផ្លែ)ត្រូវប្រើរណារដៃ ហើយអារជាបីមុខ(ដូចរូប) ទើបមិនរយះមែក។ មែកដែលត្រូវក្រីមានដូចជា:

- -មែកខ្ចៃងនៅស្រទាប់ក្រោមចំនួន១/៤នៃមែកទាំងអស់
- -មែកជំពាម
- -មែកមានជំងឺ (ងាប់ពីចុង មហារីក ឬ ដំបៅ។ល។)

ក្រោយពេលក្រីមែករួចត្រូវធ្វើអនាម័យដោយប្រមូលមែកឈើដែលកាត់រួចចេញពីចំការ ហើយដុតចោល ឬ ប្រមូលធ្វើជាអុសដុត។





Farmers' Tree Planting Manual, 2003
Producers: CTSP-DANIDA, GTZ-CGFP, DFW, JICA, PRASAC

## ៧-ការធ្វើឱ្យរហាល

ពេលឃើញថា ដើមឈើក្នុងចំការដុះប្រជ្រៀតប្រជែងគ្នារកពន្លឺហើយ ត្រូវកាប់ដកហូតចេញនូវដើមឈើមួយចំនួនឱ្យរហាល ដើម្បីឱ្យដើមឈើបន្សល់ទុកបានរីកធំធាត់ល្អ។ ត្រូវអនុវត្តការធ្វើឱ្យរហាលនេះនៅដើម ឬ ចុងរដូវភ្លៀង។

ត្រូវកាប់ដកហូតដើមឈើមិនល្អចេញជាជំហាន១ បន្តិចម្តង១ កុំឱ្យព្រៃរហាលឆាប់រហ័សពេក ។ គួរកាប់ដកហូតដើមឈើដែលមានលក្ខខណ្ឌដូចខាងក្រោម:

ក-ដើមមានជំងឺ ត្រូវកាប់យកចេញមុនគេ

ខ-ដើមឈើឥតប្រយោជន៍ ដែលដុះប្រជែងជាមួយឈើដែលមានប្រយោជន៍

គ-ដើមឈើមានប្រយោជន៍តែតូចលូតលាស់យឺតនៅស្រទាប់ក្រោម

ឃ-ដើមវៀចកោង ឬ បែកជំពាមច្រើន ត្រូវកាប់ក្រោយគេ។

ត្រូវធ្វើការពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញផ្សព្វផ្សាយព្រៃឈើ ដើម្បីជៀសវាងនូវផលវិបាកពីការធ្វើរហាលមិនបានសមស្រប។ ត្រូវប្រមូលយក ដើមឈើដែលបានកាប់ចេញឆ្ងាយ ឬ ប្រើជាអុស។



## ៨.ការថែទាំព្រៃខ្នង

-នៅប្រទេសកម្ពុជាយើងសំបូរព្រៃខ្នងណាស់។ ព្រៃខ្នងទាំងនេះជាព្រៃដែលដុះចេញពីគល់នៃដើមឈើដែលត្រូវបានកាប់យកដើមពីកំណើតមកប្រើប្រាស់ ហើយភាគច្រើនជាប្រភេទពូជឈើដែលដុះនៅក្នុងព្រៃរបោះ។ ព្រៃខ្នងតែងត្រូវបានកាប់យកផលម្តងហើយម្តងទៀត១ ពី៤-១០ឆ្នាំម្តង ទៅតាមប្រភេទផលដែលគេចង់បានដូចជា អុស ឈើបង្គោល ហើយការផ្តល់ផលនេះក៏អាស្រ័យទៅនឹងគុណភាពដីផងដែរ។ ហេតុនេះហើយ ក្រោយពេលប្រមូលផល ត្រូវចេះថែទាំគល់ខ្នងឱ្យបានល្អ ដើម្បីបានទទួលផលលើកក្រោយ១ទៀត។ ការងាររបស់កសិករចំពោះព្រៃខ្នងដែលនៅរយៈពេលចន្លោះពីការធ្វើអាជីវកម្មមួយលើកទៅមួយលើកមានៈ ការសំអាតគល់ក្រោយប្រមូលផល និង ការថែទាំដើមខ្នង ។



## ៨.១-ការងារជំនួយក្រោយពេលប្រមូលផលដើម្បីឱ្យខ្នែងដុះបានល្អ

ការងារបន្ទាន់ក្រោយពីការប្រមូលផលភ្លាមៗ គឺត្រូវសំអាតគល់ ដើម្បីផ្តល់លក្ខខណ្ឌល្អដល់គល់ឆាប់ដុះខ្នែង និង កំលាំងល្អ។ ក្រោយអាជីវកម្មអាចមានគល់ពីរប្រភេទគឺ:

-ជាគល់ឈើចាស់ដែលធ្លាប់បានដុះខ្នែងកន្លងមក

-ជាគល់ឈើថ្មីដែលទើបតែកាប់យកដើមពីកំណើត (ចំការព្រៃដាំ ឬ ព្រៃធម្មជាតិ)។

តែទោះជាយ៉ាងណាក៏គល់ឈើទាំងពីរប្រភេទនេះ ត្រូវតែសំអាតដូចគ្នា។ ដើម្បីឱ្យទទួលបានលទ្ធផលដុះខ្នែងល្អ ការសំអាតគល់ត្រូវអនុវត្ត ឱ្យបានដូចខាងក្រោម:

-ត្រូវកាត់គល់ឱ្យបានកៀកនឹងដី ចំពោះគល់ឈើថ្មីដែលទើបធ្វើអាជីវកម្មរួច

-មុខកាត់ ត្រូវឱ្យបានស្មើហើយមានជំរាលបន្តិច ធ្វើឱ្យទឹកហូរចេញ មិនឆាប់ពុកគល់ខូច

-ចំពោះគល់ខ្នែងចាស់ ត្រូវកាត់ឱ្យបានកៀកនឹងមុខកាត់ចាស់។



## ៤.២-របៀបថែទាំដើមខ្នែង

### ក-ការថែទាំសំរាប់ឆ្នាំទី១

ក្រោយពីសំអាតគល់រួចហើយ ត្រូវសំអាតរុក្ខជាតិឥតប្រយោជន៏ចេញ ដូចជា ស្មៅ ស្បូវ ព្រិច ដែលដុះនៅជុំវិញគល់ ដើម្បីឱ្យមានពន្លឺថ្ងៃចូលដល់គល់ឈើបានគ្រប់គ្រាន់។ ព្រោះខ្នែងថ្មីត្រូវការពន្លឺថ្ងៃគ្រប់គ្រាន់ដើម្បីដុះឡើងបាន និង មានកំលាំងខ្លាំង តែបើនៅក្នុងម្លប់លទ្ធភាពដុះមានតិច ហើយមិនសូវលូតលាស់ល្អទេ។

ក្រោយពីខ្នែងដុះបានល្អហើយមានអាយុមួយឆ្នាំ ឬ ចុងឆ្នាំទីមួយ យើងអាចមើលដឹងថាខ្នែងណាមានសុខភាពល្អ និង ខ្នែងណាពុំសូវល្អត្រូវក្រីវាចោល ដោយបន្សល់ទុកខ្នែងដែលមានសុខភាពល្អចំនួន ពី ៣-៤ខ្នែងក្នុងមួយគល់ ដើម្បីឱ្យខ្នែងដែលបន្សល់ទុកមានកំលាំងលូតលាស់បានធំល្អ។



### ខ-ការងារថែទាំនៅឆ្នាំបន្តបន្ទាប់

-ត្រូវក្រីមែកចោលខ្លះជាបន្តបន្ទាប់ ដើម្បីឱ្យផ្នែកដើមលូតលាស់បានល្អ និង ជួយឱ្យមានពន្លឺថ្ងៃគ្រប់គ្រាន់ សំរាប់ចិញ្ចឹមរុក្ខជាតិបន្ទាប់បន្សំនៅស្រទាប់ក្រោម។ ចំពោះមែកដែលក្រី ត្រូវកាត់ឱ្យបានកៀកនឹងដើមតាមដែលអាចធ្វើទៅបាន។

-ត្រូវសំអាតវល្លិ៍ដែលតោងរំខានដល់ដើមឈើ

-ចំពោះព្រៃខ្ទង់ដែលបានប្រមូលផលញឹកញាប់ បណ្តាលឱ្យដីខ្សោះជីជាតិ ដូចនេះត្រូវតែបំប៉នជីដល់ដីឡើងវិញដោយប្រើប្រាស់កំទិចកំទីស្លឹកឈើពុករលួយជាដើម។



-ក្រោយពីពេលធ្វើការក្រីមែកមក ពេលព្រៃខ្នងឡើងណែនវិញ ត្រូវធ្វើឱ្យរហាលដោយដកហូតយកដើមខ្នងណាដែលៈ ខ្សោយជាងគេ ដើមវៀចកោង និង ដើមឥតប្រយោជន៍ ដើម្បីជួយជំរុញដល់ការលូតលាស់របស់ដើមដែលបន្សល់ទុក។ មិនត្រូវកាប់អស់ខ្នងរលីងពីគល់ណាមួយទេ។ បើចាំបាច់នូវបច្ចេកទេស ត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីផ្សព្វផ្សាយព្រៃឈើដែលនៅជិតមូលដ្ឋាន ដើម្បីឱ្យការងារនេះទទួលលទ្ធផលកាន់តែល្អប្រសើរ។ ព្រោះត្រូវធ្វើឱ្យរហាលដោយសន្សឹមៗ និងរង់ចាំមើលការប្រែប្រួលនៃការរីកចំរើន និង តំរូវការរបស់ព្រៃ។

-ត្រូវការពារភ្លើងឆេះព្រៃរៀងរាល់រដូវប្រាំង ។



# បណ្ណាល័យសាស្ត្រ

1-CTSP-DANIDA: Tree Seed Extension Posters, 2002

2-CTSP-DANIDA: Biology, Development and Ecology of Tree Seed, 2002

3-FAO, Regional Wood Energy Development Programme in Asia: "Collection, Storage and Treatment of Tree Seeds" a Handbook for Small Farm Tree Planters, August 1993

4-GTZ: Manual of Reforestation and Erosion Control for The Philippines, 1976

5-HMG/EEC/ODA National Tree Seed Project: "Tree Seed Handling" a manual for field staff in Nepal.

6-ICRAF: Imperata Grassland Rehabilitation using Agroforestry and Assist Natural Regeneration, 1999

7-JICA: Textbook on "Coppice and Coppicing" 2002

8-Konrad-Adenauer-Foundation: Compost Fertilizer, 1999

9-Kenya/Japan Social Forestry Training Project: Social Forestry Techniques, Copyright © 1991

# ឧបសម្ព័ន្ធ

**តារាងឧបសម្ព័ន្ធ១** **ប្រព្រឹត្តិកម្មគ្រាប់ពូជសំរាប់ប្រភេទឈើមួយចំនួន**

| ឈ្មោះដើមឈើ | របៀបប្រព្រឹត្តិកម្ម | ចំនួនថ្ងៃអាចដុះពន្លក | ចំនួនគ្រាប់ក្នុង១គីឡូក្រាម |
|---|---|---|---|
| គគោះ<br>*Sindora siamensis* | -ត្រាំទឹកក្តៅ (៧០-៨០អង្សា) ទុកឱ្យត្រជាក់ពី១០-១២ ម៉ោង។ | ៧ - ១០ | ៣០០ - ៣៥០ |
| ក្រៅក<br>*Delonix regia* | a)-ត្រាំទឹកក្តៅ (៧០-៨០ អង្សា) រយៈពេល ១០នាទី ហើយត្រាំទឹកធម្មតាមួយយប់។<br>b)-ឬមួយកាប់សំបកគ្រាប់បន្តិច រួចត្រាំទឹកធម្មតា ២៤ម៉ោង | ១២ - ២០ | ១៦០០ - ២៣០០ |
| ក្រញូង<br>*Dalbergia cochinchinensis* | -ត្រាំងទឹកក្តៅ | | ៣.៥០០ |
| កន្ធំថេត<br>*Leucaena leucacephala*<br>(Ipil-ipil) | a)-ត្រាំក្នុងទឹកធម្មតារយៈពេល ៣៦ ម៉ោង<br>b)-ឬមួយស្រុះទឹកក្តៅហើយត្រាំទឹកត្រជាក់ពី២៤-២៧ ម៉ោង | ៥ - ១២ | ១៣.០០០ |
| ខ្នុរ<br>*Artocarpus heterophyllus*<br>(Jack fruit tree) | -យកសំបកចេញ ហើយត្រាំទឹកធម្មតា រយៈពេល ២៤ ម៉ោង | ៣ - ៥ | ៤៥ - ៩០ |
| ខ្ទាវ<br>*Haldina cordifolra* | -ត្រាំទឹកក្តៅ (៣០-៣៥អង្សា) ទុកឱ្យត្រជាក់ពី៨-១០ ម៉ោង | | ១.៥០០ - ១.៨០០ |
| គគីរ<br>*Hopea odorata* | -ត្រាំក្នុងទឹកធម្មតារយៈពេល ៨ម៉ោង ឬ យកទៅសាបភ្លាមៗ ដោយផ្ទាល់នៅក្នុងថ្នាល ។ | | ២.៥០០ - ៣.០០០ |
| គ្រាប់បែក<br>*Swietenia macrophylla*<br>(Mahogany) | -ត្រាំទឹកក្តៅ (៥០ អង្សា) រយៈពេល៥នាទី រួចត្រាំទឹកត្រជាក់ពី ៨-១០ម៉ោង។ | ១៤ - ២៨ | ២.៣០០ |
| ចំរៀក<br>*Albizia lebbeckoides*<br>(Indian walnut siris) | -ត្រាំក្នុងទឹកក្តៅទុកអោយត្រជាក់មួយយប់ រួចលាងទឹកផ្ទាប់។ | ៣-៤ | |

| | | | |
|---|---|---|---|
| ច្រេស<br>*Albizia lebbeck*<br>(Indian walnut siris) | -ត្រាំទឹកក្តៅ(៥០ អង្សា) ទុកឱ្យត្រជាក់មួយយប់រួចលាងទឹកផ្ទាប់ ។ | ៣ - ៤ | ៦.០០០ - ១៦.០០០ |
| ឈើទាលទឹក<br>*Dipterocarpus alatus* | -ត្រាំទឹកត្រជាក់រយៈពេល៨ម៉ោង រួចផ្ទាប់ ។ | | ២៥០ - ៣១០ |
| ដូនចែម<br>*Tarrietia javanica* | -ត្រាំទឹកក្តៅ (៣៥-៤០) ទុកឱ្យត្រជាក់មួយយប់ រួចលាងសំអាត ហើយផ្ទាប់ ។ | | ១.៥០០ - ១.៧០០ |
| ត្រសេក<br>*Peltophorum dasyrrhachis* and<br>ត្រាំកង់<br>*Peltophorum plerocarpum* | -ត្រាំទឹកក្តៅ(៦០-៧០អង្សា) ទុកឱ្យត្រជាក់ពី១០-១៥ម៉ោង រួចលាងសំអាត ហើយផ្ទាប់ ។ | | ៩.៥០០- ១១.០០០ |
| ធ្នង់<br>*Pterocarpus macrocarpus* | -ត្រាំទឹកក្តៅ(៦០-៧០អង្សា) ទុកឱ្យត្រជាក់មួយយប់ រួចលាងសំអាតហើយផ្ទាប់ ។ | ៤ - ១៥ | ១.៥០០ - ២.០០០ |
| បេង<br>*Afzelia xylocarpa* | -ត្រាំទឹកក្តៅ(៧០-៨០អង្សា) ទុកឱ្យត្រជាក់មួយយប់ ។<br>-ឬកាប់សំបកគ្រាប់បន្តិចត្រាំទឹកធម្មតាមួយយប់រួចលាងទឹកផ្ទាប់ ។ | ៧ - ១០ | ១១០ - ១៦០ |
| ប្រេងខ្យល់<br>*Eucalyptus camadulensis* | -ត្រាំទឹកក្តៅ(៣៥-៤០អង្សា) ទុកឱ្យត្រជាក់ពី៦-៨ម៉ោង ។ | | ១៨០.០០០- ១៩០.០០០ |
| ផ្ដៀក<br>*Anisoptera costata* | -យកទៅសាបភ្លាមដោយផ្ទាល់នៅក្នុងថ្នាល ។ | | ១.៥០០ - ២.០០០ |
| មៃសាក់<br>*Tectona grandis* | -ត្រាំក្នុងទឹកហូរ ២៤ម៉ោង រួចហាលថ្ងៃ ហើយផ្សើមវិញ រួចហាលថ្ងៃហើយផ្សើមវិញចំនួន ៣ថ្ងៃ ។ | ១៤ - ៦៨ | ១.០០០ |
| ល្មៀងរាជ<br>*Cassia fistula*<br>(Golden shower) | -កាប់សំបកគ្រាប់ចេញបន្តិច ហើយត្រាំទឹកធម្មតា១យប់ រួចលាងផ្ទាប់ | ៥ - ៧ | ២.០០០ - ៦.០០០ |

| | | | |
|---|---|---|---|
| ស្រល់<br>*Pinus merkusii* | -ត្រាំទឹកក្តៅ(៤០-៤៥អង្សា) ទុកឱ្យត្រជាក់១យប់រួចលាងផ្លាប់ | ១៤ | ៣.០០០ - ៤.០០០ |
| ស្វាយចន្ទី<br>*Anacardium occidentale* (Cashew nut tree) | -កាប់សំបកគ្រាប់ចេញបន្តិច ដើម្បីកាត់បន្ថយជ័រ ហើយត្រាំក្នុងទឹកក្តៅ (៤០-៤៥អង្សា) ទុកឱ្យត្រជាក់ពី១០-១៥ម៉ោង ។ | ១២ | ២០០ - ៩០០ |
| ស្វាវ<br>*Casuarina equisetifolia* | -ត្រាំទឹកក្តៅ(៤០-៤៥អង្សា) ទុកឱ្យត្រជាក់១យប់រួចលាងផ្លាប់ | ៧ - ២១ | ៦៥០.០០០-៧០០.០០០ |
| ស្តៅ<br>*Azadirachta indica* | -យកទៅសាបដោយផ្ទាល់នៅក្នុងថ្នាលតែម្តង ។ | ៣ - ៥ | ៤.០០០ - ៦.០០០ |
| សណ្តែកខ្លឹង<br>*Cajanus cajan* (Pigeon pea) | -ត្រាំក្នុងទឹកធម្មតារយៈពេល ២៤ម៉ោង | ២ - ៣ | ៣.៥០០ |
| ស្វាយ<br>*Mangifera indica* (Mango) | -កាប់បកយកសំបកគ្រាប់ចេញ ហើយដាក់បណ្តុះដោយផ្ទាល់នៅក្នុងថ្នាល ។ | ៦ - ៩ | ៤០ |
| អង្គាញ់<br>*Cassia siamea* | -ត្រាំទឹកក្តៅ(៦០-៧០អង្សា) ទុកឱ្យត្រជាក់១យប់រួចលាងផ្លាប់ | ៣ - ៧ | ២០.០០០-២៥.០០០ |
| អង្គារដី<br>*Sesbania bispinosa* (Preckly sesban) | -ត្រាំក្នុងទឹកធម្មតា ២៤ ម៉ោង | ៥ - ៨ | ១០.០០០-១៥.០០០ |
| អាកាស្យាស្លឹកតូច :<br>*Acacia auriculiformis* | -ស្រុះក្នុងទឹកពុះ ៣០វិនាទីទៅ ១នាទីហើយត្រាំក្នុងទឹកធម្មតា ១យប់រួចលាងសំអាត ។<br>-ឬត្រាំក្នុងទឹកក្តៅទុកឱ្យត្រជាក់ ១យប់រួចលាងផ្លាប់ ។ | ៣ - ៨ | ៧.៤០០ - ៨.០០០ |
| អាកាស្យាស្លឹកធំ : Acacia mangium (Sabah acacia) | -ត្រាំក្នុងទឹកពុះ៣០វិនាទី ហើយត្រាំក្នុងទឹកធម្មតា១យប់ រួចលាងផ្លាប់ ។ | ៣ - ៦ | ៤០.០០០-៧០.០០០ |

ឧបសម្ព័ន្ធ២

## ភាពផ្សេងគ្នារបស់ផ្លែ និង គ្រាប់ឈើ



# ឧបសម្ព័ន្ធ៣

## គំរោងព្រៃឈើ កម្ពុជា-អាល្លឺម៉ង់ (CGFP)

German Technical Cooperation

| | | |
|---|---|---|
| **ឈ្មោះគំរោង** | : | ការគាំទ្រដល់ការស្តារឡើងវិញ និង ការអភិវឌ្ឍន៍វិស័យព្រៃឈើ គំរោងព្រៃឈើ កម្ពុជា-អាឡឺម៉ង់ (CGFP) |
| **ទីភ្នាក់ងារប្រតិបត្តិ** | : | នាយកដ្ឋាន រុក្ខា-ប្រមាញ់ |
| **រយៈពេល** | : | ដំណាក់កាលទី ១ ពីខែ វិច្ឆិកា ១៩៩៦ ដល់ ខែ មេសា ២០០០<br>ដំណាក់កាលទី ២ ពីខែ ឧសភា ២០០០ ដល់ខែ មេសា ២០០៤ ។ |
| **ការសន្យាជាអឺរ៉ូ** | : | ប្រហែល ............. |
| **គោលបំណងគំរោង** | : | ស្ថាប័ន និង ប្រជាជនដែលចូលរួមក្នុងវិស័យព្រៃឈើកាន់តែកើនឡើង ដែលអនុវត្ត និង ជម្រុញគោលការណ៍គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ។ |

## លទ្ធផល យុទ្ធសាស្ត្រ និង សមិទ្ធិផលសំខាន់ៗ

### ១.សេវាកម្មប្រឹក្សាអំពីបញ្ហាជម្រើសទាក់ទងទៅនឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវបានផ្តល់សេវាទៅតាមតម្រូវការ

គំរោងមានភារកិច្ចគាំទ្រដៃគូរបស់ខ្លួនក្នុងការបរិយាយពន្យល់ និងការអនុវត្តន៍គោលនយោបាយព្រៃឈើថ្នាក់ជាតិ នៃក្របខ័ណ្ឌច្បាប់សំរាប់ការគ្រប់គ្រង និងអភិរក្សព្រៃឈើដោយនិរន្តរភាព ជាពិសេសគឺគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សំរាប់សហគមន៍ព្រៃឈើ ។ គំរោងសន្យាធ្វើការតាមវិធីសាស្ត្រ និង ដំណើរការដែលមានអ្នកពាក់ព័ន្ធចម្រុះ និង សមស្របទៅតាមលទ្ធផល និង ដំណើរការគោលនយោបាយរចនាសម្ព័ន្ធសកល ដូចជា សន្ធិសញ្ញា និង កិច្ចព្រមព្រៀងអន្តរជាតិ និង កម្មវិធីព្រៃឈើថ្នាក់ជាតិ ។ ដើម្បីសម្រេចការងារទាំងនេះបាន គំរោងកំពុងតែធ្វើការលើបញ្ហាសំខាន់ៗដូចមានរៀបរាប់ខាងក្រោមនេះ :

- ការចូលរួមក្នុងការបរិយាយពន្យល់ពីអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើដោយផ្អែកលើដំណើរការពិគ្រោះយោបល់ដែលមានអ្នកពាក់ព័ន្ធទូទាំងប្រទេសចូលរួម ។
- ការចូលរួមក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍កម្មវិធីថ្នាក់ជាតិស្តីពីសហគមន៍ព្រៃឈើ ។

- ការផ្តួចផ្តើមបង្កើតនូវដំណើរការពិគ្រោះយោបល់អន្តរអ្នកពាក់ព័ន្ធស្តីពីការរៀបចំបង្កើតឱ្យមានសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយវិស័យព្រៃឈើជាតិ ។
- ការបង្កើតឱ្យមានការពិភាក្សាអន្តរអ្នកពាក់ព័ន្ធស្តីពីការរៀបចំផែនការ និង ការអនុវត្តន៍កម្មវិធីព្រៃឈើថ្នាក់ជាតិសំរាប់ការកែទំរង់ និង ការអភិវឌ្ឍន៏វិស័យព្រៃឈើទៅថ្ងៃអនាគត ។

## ២. ប្រព័ន្ធអប់រំ និង បណ្តុះបណ្តាលសំរាប់បុគ្គលិកផ្នែកព្រៃឈើត្រូវបានកែលំអ

គំរោងបង្កលក្ខណៈងាយស្រួលដល់បុគ្គលិកផ្នែកព្រៃឈើបានចូលរួមការវាស់ស្ទង់បង្កើនសមត្ថភាពដោយផ្តោតលើផ្នែកគោលនយោបាយវិស័យព្រៃឈើ និង ការផ្សព្វផ្សាយព្រៃឈើ ។ គំរោងក៏ធ្វើការសហការជាមួយមហាវិទ្យាល័យព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និង ផ្នែកព្រៃឈើនៃសាលាកសិកកម្មព្រែកលៀប ដើម្បីបង្កើតកម្មវិធី បង្កើនចំណេះដឹង និង ការបង្រៀនរបស់គ្រូបង្រៀន បង្កើតសម្ភារៈបង្រៀន និង សម្របសម្រួលការសរសេរនិក្ខេបទ BSc និង កម្មវិធីហាត់ធ្វើការងារសំរាប់និស្សិត។ ជាពិសេស គំរោងគាំទ្រមហាវិទ្យាល័យព្រៃឈើនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មដើម្បីបញ្ចូលខ្លួនទៅក្នុងបណ្តាញសាកលវិទ្យាល័យថ្នាក់តំបន់ និង អន្តរជាតិ ។

## ៣.ទស្សនៈដាក់ស្តែងសំរាប់ប្រព័ន្ធផ្សព្វផ្សាយព្រៃឈើត្រូវបានបង្កើត និង សាកល្បង

ដើម្បីគាំទ្រដល់ការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជម្រុញ និង អនុវត្តទស្សនៈសហគមន៏ព្រៃឈើជាស្ពាបចាក់សំខាន់មួយសំរាប់ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពស្ថិតក្នុងក្របខ័ណ្ឌនយោបាយទាំងស្រុងនៃការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គម គំរោងបានធ្វើការគាំទ្រដល់ការបង្កើតប្រព័ន្ធផ្សព្វផ្សាយព្រៃឈើ ដែលអាចដំណើរការទៅបាន។ លើវិស័យនេះ គំរោងកំពុងតែសហការជាមួយដៃគូជាច្រើនទៀតដែលមិនត្រឹមតែធ្វើការបង្កើតប្រព័ន្ធផ្សព្វផ្សាយព្រៃឈើរួមគ្នាប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យការអនុវត្តន៏អាចដំណើរការទៅបាន។ គំរោងចូលរួមក្នុងដំណើរការសំខាន់ៗដូចខាងក្រោមនេះ:

- ស្ថិតក្នុងក៏រិតនៃការគាំទ្រភាពជាដៃគូទូលំទូលាយមួយនៃការបង្កើតប្រព័ន្ធផ្សព្វផ្សាយព្រៃឈើមួយផ្អែកលើការវាយតំលៃទូលំទូលាយទូទាំងប្រទេសអំពីវិធីសាស្ត្រសហគមន៏ព្រៃឈើការបរិយាយពន្យល់អំពីទស្សនៈផ្សព្វផ្សាយព្រៃឈើ និងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការគោលនយោបាយសហគមន៏ព្រៃឈើ ។
- ការចូលរួមក្នុងការបរិយាយនៃសៀវភៅបច្ចេកទេសដាំឈើ ។
- ស្ថិតក្នុងការគាំទ្រវិធីសាស្ត្រដៃគូមួយនៃគំនិតផ្តួចផ្តើមតាមមូលដ្ឋានដើម្បីអនុវត្តការរៀបចំដីធ្លីដោយមានការចូលរួម (PLUP) និង សហគមន៏ព្រៃឈើ ។

## ១_អំពីគំរោងគ្រាប់ពូជឈើនៅកម្ពុជា

គំរោងគ្រាប់ពូជឈើកម្ពុជា គឺជាផ្នែកមួយនៃកម្មវិធីគ្រាប់ពូជឈើក្នុងតំបន់: " ការគាំទ្រការកសាងសមត្ថភាពស្ថាប័ននៃវិស័យគ្រាប់ពូជឈើជាតិនៅឥណ្ឌូចិន"។

គំរោងគ្រាប់ពូជឈើកម្ពុជាសហការជាមួយនាយកដ្ឋានរុក្ខាប្រមាញ់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ គំរោងនេះ បានទទួលការឧបត្ថម្ភពីរដ្ឋាភិបាលដាណឺម៉ាក្ស តាមរយៈជំនួយអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក្សហៅកាត់ថា ដានីដា (DANIDA)។ សេវាពិគ្រោះយោបល់ និង ការគាំទ្រខាងបច្ចេកទេស ត្រូវបានផ្តល់ដោយមជ្ឈមណ្ឌលគ្រាប់ពូជឈើដានីដា។

គោលបំណងរួមរបស់គំរោង គឺដើម្បីបង្កើនគុណភាពសមត្ថភាពស្ថាប័នក្នុងការប្រើប្រាស់គ្រាប់ពូជប្រកបដោយគុណភាពល្អនៅទូទាំងប្រទេសកម្ពុជា ជាពិសេសប្រភេទពូជឈើក្នុងស្រុក និង ការអភិរក្ស ធនធានហ្សែនព្រៃឈើ។

គំរោងគ្រាប់ពូជឈើកម្ពុជាមានគោលបំណង៤សំខាន់ៗគឺ:

១- ពង្រឹងស្ថាប័នវិស័យគ្រាប់ពូជឈើ
២- បណ្តុះបណ្តាល ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ធនធានមនុស្ស
៣- ផ្ទេរចំណេះដឹង និង បច្ចេកវិជ្ជាវិស័យគ្រាប់ពូជឈើ
៤- បង្កើតយុទ្ធសាស្ត្រអភិរក្សធនធានហ្សែនព្រៃឈើនៅកម្ពុជា

| |
|---|
| **ប្រទេសកម្ពុជាមានជីវចំរុះដ៏សំបូរបែប ដែលជាសក្តានុពលសំរាប់បង្កើតប្រភពគ្រាប់ពូជប្រកបដោយគុណភាពល្អ។ យើងត្រូវថែរក្សាប្រភពពូជឈើសំខាន់ៗនិងមានតំលៃទាំងអស់ឱ្យទាន់ពេលវេលាសំរាប់កូនចៅយើងជំនាន់ក្រោយ។** |

## ២_ព្រៃឈើនៅកម្ពុជា

ប្រទេសកម្ពុជាមានគំរបព្រៃឈើប្រហែល៥០%ដែលជាប្រភេទព្រៃមានតំលៃដូចជា: ព្រៃស្រោង ព្រៃរល្បោះ និង ព្រៃកោងកាង ព្រៃលិចទឹក។ល។ ព្រៃឈើទាំងនេះមានសក្តានុពល ជីវចំរុះ ដ៏សំបូរបែប។

ក៏ប៉ុន្តែព្រៃឈើជាច្រើនកំពុងតែរេចរឹល ឬ ប្រែក្លាយទៅជាដីប្រើប្រាស់ផ្សេងៗ ដោយសារតែការធ្វើកសិកម្មពនេចរ ភ្លើងឆេះព្រៃ និង ការធ្វើអាជីវកម្មឈើហួសកំរិត។ ដោយសារតែភាពរេចរឹល

ព្រៃឈើកាន់តែខ្លាំងឡើង និង ការធ្វើអាជីវកម្មក្នុងព្រៃព្រហ្មចារីយ៍ចេះតែបន្តនោះ ធនធានហ្សែននៃប្រភេទឈើសេដ្ឋកិច្ចសំខាន់ៗ ត្រូវទទួលរងការគំរាមកំហែង និង បណ្តាលឱ្យប្រភពដើមពូជល្អៗ និង ដំណុះឡើងវិញដោយធម្មជាតិនៃប្រភេទពូជទាំងនេះនឹងត្រូវវិនាសជាមិនខានឡើយ ។

## ៣-ប្រភេទពូជឈើក្នុងស្រុក

ប្រភេទឈើក្នុងស្រុកមានតួនាទីសំខាន់ណាស់ វាត្រូវបានប្រើប្រាស់ជាច្រើនសតវត្សមកហើយ សំរាប់ធ្វើសសរ ទ្វារ បង្អួច សំភារៈសំណង់ និង សង្ហារឹមផ្សេងៗ ។ល ។ ក្រៅពីនេះ នៅមានអនុផលព្រៃឈើផងដែរ ដូចជា ជ័រឈើ ផ្លែឈើ រុក្ខជាតិថ្នាំ ដែលមានសារៈសំខាន់បំផុតចំពោះជីវភាពរបស់សហគមន៍មូលដ្ឋាន ។

ពិតមែនថា ពូជឈើក្នុងស្រុកលូតលាស់យឺតជាងពូជឈើនាំចូល ក៏ប៉ុន្តែវាបានដុះដាលបន្តពូជជាច្រើនជំនាន់មកហើយ ។ គេបានដឹងថា មិនទាន់មានពូជឈើក្នុងស្រុកណាមួយនៃប្រទេសកម្ពុជាត្រូវបានគេបញ្ចូលក្នុងកម្មវិធីសុរុំឡិកម្មដើមឈើនៅឡើយ ។ ដូច្នេះ ពូជឈើក្នុងស្រុកមានសក្តានុពលខ្ពស់ណាស់សំរាប់ធ្វើការសិក្សា និង បញ្ចូលក្នុងកម្មវិធីបង្កើនគុណភាពនិងអត្រាលូតលាស់របស់វា ។ការគណនាខាងសេដ្ឋកិច្ចប្រៀបធៀបពូជឈើក្នុងស្រុក និង ក្រៅស្រុកដែលលូតលាស់លឿន បង្ហាញថាពូជឈើក្នុងស្រុកមានគុណ-ភាពខ្ពស់ មានតំលៃអាចទូទាត់នឹងអត្រាលូតលាស់យឺតរបស់វាបាន ។ ការពិចារណាខាងតំលៃរបស់វា គេបានគិតបញ្ចូល ទាំងតំលៃជីវសាស្ត្រ និង សង្គម ហើយតំរូវការនាអនាគត ក៏បង្ហាញយ៉ាងច្បាស់ថា មាននិន្នាការដាំប្រភេទពូជឈើក្នុងស្រុកផងដែរ ។

ការបង្កើនការប្រើប្រាស់គ្រាប់ពូជឈើប្រកបដោយគុណភាព ទាមទារការសិក្សាស្រាវជ្រាវបន្ថែម ព្រោះថាការយល់ដឹងអំពីវិស័យនេះនៅមានកំរិតនៅឡើយ ។ ដូច្នេះ ការពិសោធន៍ ការសិក្សាស្រាវជ្រាវជាការងារចាំបាច់ដែលត្រូវអនុវត្ត ដោយប្រើប្រាស់វិធីសាស្ត្រងាយៗ តែមានប្រសិទ្ធភាព ដូចជាវិធីសាស្ត្រប្រមូលគ្រាប់ពូជ ការប្រលេះយកគ្រាប់ និង ការធ្វើប្រព្រឹត្តិកម្ម និង បណ្តុះគ្រាប់ជាដើម ដែលអាចឱ្យអ្នកផលិតគ្រាប់ពូជ បុគ្គលិក-កម្មករថ្នាល និងប្រជាជនតាមជនបទអាចរៀនសូត្របាន ។

## ៤-ប្រភពគ្រាប់ពូជ

ចំណុចចាប់ផ្តើមនៃការផលិតគ្រាប់ពូជ និង ការអភិរក្សធនធានហ្សែន គឺការជ្រើសរើស និង ថែរក្សាគុណភាពដើមពូជឱ្យបានល្អ ។ ការប្រើប្រាស់ ឬ ការធ្វើអាជីវកម្មឈើគ្មានផែនការច្បាស់លាស់អាចបណ្តាលឱ្យបាត់បង់ធនធានហ្សែនដ៏មានតំលៃសំរាប់ការប្រើប្រាស់នាអនាគត និង បាត់បង់នូវគុណភាពពូជឈើក្នុងស្រុក ។

ការរៀបចំបណ្តាញប្រភពគ្រាប់ពូជដែលតាងឱ្យតំបន់អេកូឡូស៊ីខុសគ្នានឹងអាចរក្សាបាននូវមូល-ដ្ឋានហ្សែនចំរុះគ្រប់គ្រាន់ សំរាប់កម្មវិធីដាំឈើ និង សុវិឡិកម្មដើមឈើនាអនាគត។ ដូច្នេះ ការបង្កើតប្រភពផលិតគ្រាប់ពូជប្រកបដោយគុណភាពខ្ពស់សំរាប់ ផ្គត់ផ្គង់ក្នុងស្រុក គឺជាបេសកកម្មមួយយ៉ាងសំខាន់។

| |
|---|
| **ការប្រៀបធៀបតំបន់ផលិតគ្រាប់ និង ទីកន្លែងដែលត្រូវដាំ គឺជាកត្តាកំណត់ជោគជ័យដល់កម្មវិធីដាំដើមឈើឡើងវិញ។** |

## ៥. ការអភិរក្សខ្លួនតាមការប្រើប្រាស់

បច្ចុប្បន្នមានការទទួលស្គាល់កាន់តែច្រើនឡើងថា ការថែរក្សាធនធានហ្សែនព្រៃឈើ គឺជាលក្ខខណ្ឌចំបងសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

ប្រភេទឈើមួយចំនួនកំពុងរងការគំរាមកំហែងដោយសារតែភាពរេចរិលនៃហ្សែនដែលបណ្តាលមកពីការធ្វើអាជីវកម្មកាប់ជ្រើសយកតែដើមល្អៗ។ ការអភិរក្សហ្សែនចំរុះគឺមានប្រយោជន៍សំរាប់កម្មវិធីសុវិឡិកម្មដើមឈើនាអនាគត។

| |
|---|
| **ដើមឈើល្អ ដុះចេញពីគ្រាប់ពូជដែលមានគុណភាពសេនេទិចល្អ** |

ធម្មតា ពូជឈើភាគច្រើនងាយអភិរក្សបំផុតនៅក្នុងតំបន់ធម្មជាតិរបស់វា ប៉ុន្តែក្នុងកាលៈទេសៈខ្លះ ព្រៃធម្មជាតិត្រូវបានគេរំខាន ហើយប្រជាជនមូលដ្ឋាន អាជ្ញាធរព្រៃឈើ។ល។ មិនអាចការពារបានដូច្នេះ គួរឱ្យយើងបង្កើតតំបន់អភិរក្សនៅក្រៅតំបន់ធម្មជាតិរបស់វា។

បច្ចុប្បន្នគំរោងគ្រាប់ពូជឈើកម្ពុជា កំពុងតែប្រមូលទិន្នន័យសំរាប់សំរួលដល់ដំណើរការរៀបចំយុទ្ធសាស្ត្រអភិរក្សធនធានហ្សែន ព្រៃឈើកម្ពុជា។

ការអភិរក្សព្រៃឈើដែលមានជីវចំរុះខ្ពស់ នឹងបង្កើតបានជាមូលដ្ឋានផលិតគ្រាប់ពូជមួយប្រកបដោយគុណភាពខ្ពស់សំរាប់ ប្រើប្រាស់ក្នុងការស្តារព្រៃឈើឡើងវិញ។ លើសពីនេះ ការរៀបចំបណ្តាញតំបន់ប្រភពផលិតគ្រាប់ពូជនៅក្នុងព្រៃធម្មជាតិដែលមិនទាន់ធ្វើអាជីវកម្មនឹងផ្តល់នូវសក្តានុពលយ៉ាងខ្ពស់ដល់ការងារស្រាវជ្រាវផងដែរ។

| |
|---|
| កសិករអាចរកប្រាក់ចំណូលបានមកពីការប្រមូលគ្រាប់ពូជឈើ |

**កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ននឹងទទួលបាននូវការកោតសរសើរពីកូនចៅជំនាន់ក្រោយជាមិនខាន។**

គំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ បានចាប់ផ្តើមនៅក្នុងខែ ធ្នូ ឆ្នាំ២០០១ ជាកិច្ចសហប្រតិបត្តិការបច្ចេកទេស រវាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) និង នាយកដ្ឋានរុក្ខា-ប្រមាញ់ ( DFW ) នឹងបញ្ចប់ នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៤។ គោលបំណងគឺបង្កើនសមត្ថភាពលើវិស័យព្រៃឈើ ដែលរួមទាំងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់មន្ត្រីនាយកដ្ឋានរុក្ខា-ប្រមាញ់ ក៏ដូចជាមន្ត្រីស្ថាប័នផងដែរ។

គំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ បានធ្វើឱ្យមានការជឿនលឿនជាជំហាន១។ ស្នាដៃដែលបានសំរេចមានជាអាទិ៍ :

- បើកកិច្ចប្រជុំ និង សិក្ខាសាលាដែលពាក់ពន្ធ័នឹងការពង្រឹងសមត្ថភាព
- ការបង្កើត និង វិភាគទិន្ន័យលើការបណ្តុះបណ្តាលកន្លងមក
- ការវិភាគសំនួរចំលើយរបស់មន្ទីររុក្ខា-ប្រមាញ់ខេត្ត-ក្រុង
- ការរៀបចំកម្មវិធីដែលទាក់ទង និងរូបមន្តចាំបាច់
- កម្មវិធីបណ្តុះបណ្តាលទូទៅឆ្នាំ ២០០៣
- ការសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើ និង សត្វព្រៃ
- ការអនុវត្តន៍ សង្គម-សេដ្ឋកិច្ច នៅជុំវិញមជ្ឈមណ្ឌល
- ការផ្តល់ឧបករណ៍សំភារៈចាំបាច់
- ការវាស់វែងព្រៃឈើ

គំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ បានប្តូរទីតាំងទៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិស័យព្រៃឈើ និង សត្វព្រៃ។ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៣ មជ្ឈមណ្ឌលនេះ ត្រូវបានសម្ពោធឱ្យប្រើប្រាស់ជាផ្លូវការដោយ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

នៅក្នុងឆ្នាំ ២០០៣ គំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ អនុវត្តន៍កម្មវិធីបណ្តុះបណ្តាលឆ្នាំ ២០០៣ ដែលរួម មាន៦មុខវិជ្ជា ដូចជា : ច្បាប់ព្រៃឈើ , សហគមន៍ព្រៃឈើ , ថ្នាលបណ្តុះកូនឈើ , រុក្ខវប្បកម្ម , ការគ្រប់គ្រងព្រៃឈើ /ចំការឈើ និង ការវាស់វែងព្រៃឈើ។

# កម្មវិធីគាំទ្រផ្នែកកសិកម្មនៅកម្ពុជា ( PRASAC II )

Cambodia-EU
PRASAC

ប្រាសាក់បានចាប់ផ្តើមប្រតិបត្តិការក្នុងឆ្នាំ១៩៩៥ ជាកម្មវិធីស្តារកសិកម្មនៅក្នុងខេត្តចំនួន៦ដែលស្ថិតនៅជុំវិញរាជធានីភ្នំពេញ។ ការពិតពីដើមឡើយ កម្មវិធីស្តារនេះបានចេញជាពាក់រោង ( ប្រាសាក់១, ប្រាសាក់២, ប្រាសាក់៣) ។ នៅក្នុងឆ្នាំ១៩៩៨ គំរោងទាំងនោះត្រូវបានដាក់បញ្ចូលគ្នា ហើយការអនុវត្តន៍មានរយៈពេលចាប់ពី០១/០១/៩៥-៣០/០៤/៩៩ ដែលរយៈពេលនេះបានក្លាយទៅជាជំហានទី I របស់ប្រាសាក់ ( ប្រាសាក់ I , **PRASAC I**) ។

ប្រាសាក់ II, ជំហានទី II, ចាប់ផ្តើមរៀបចំពី ០១/០៥/១៩៩៩-៣១/១២/២០០៣ ។ សំរាប់ជំហាននេះ ការបង្វែរទិសយុទ្ធសាស្ត្រពី កម្មវិធីសង្គ្រោះបន្ទាន់ ឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ជនបទមួយត្រូវបានគ្រោងទុកជាមុន។ ការបញ្ចូលសមិទ្ធិផលប្រាសាក់ I និង ការបន្តការងារ គឺជាគោលការណ៍ចំបងសំរាប់ដឹកនាំការអនុវត្តន៍ការងារគំរោងនៃប្រាសាក់ II នេះ ដោយរួមបញ្ចូលគ្រប់សកម្មភាពការងារទាំងអស់របស់គំរោងទៅក្នុងស្ថាប័នជាតិជាដៃគូ ហើយ និង ការពង្រឹងការដឹកនាំ និង ស្ថាប័នស៊ីវិលផង ។

ប្រាសាក់គឺជាភាគមួយនៃដំណើរការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្ពោះទៅរកយុទ្ធសាស្ត្រការអភិវឌ្ឍន៍មធ្យមមួយនៅជនបទរបស់កម្ពុជា។ បទពិសោធន៍ជាក់ស្តែងយ៉ាងសំបូរបែប បានធ្វើឱ្យជំហានទាំងពីរនេះអាចជាគន្លឹះសំរាប់គោលការណ៍អភិវឌ្ឍន៍ទៅថ្ងៃអនាគត។ ទិសដៅទៅមុខរបស់ប្រាសាក់គឺជាយន្តការទ្រទ្រង់ការអនុវត្តន៍ផ្ទាល់ឆ្ពោះទៅដល់ការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ។

ខាងក្រោមនេះគឺជាគោលការណ៍ពិស្តារក្នុងការអនុវត្តន៍គំរោងប្រាសាក់ **II** :

**គោលបំណង** : អនុវត្តបន្តនូវសកម្មភាពការងារអភិវឌ្ឍជនបទនៅទូទាំង៦ខេត្ត លើវិស័យផ្គត់ផ្គង់ទឹកស្អាត កសិកម្ម អភិវឌ្ឍន៍ សហគមន៍ ឥណទាន ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និង ការពង្រឹងសមត្ថភាពស្ថាប័ន ។

**ទីតាំង** : -ផ្នែកគ្រប់គ្រងគំរោងនៅភ្នំពេញ ។
-ខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម ព្រៃវែង និង ខេត្តស្វាយរៀង។

**សមាសភាគ** :-ផ្គត់ផ្គង់ទឹកស្អាត: *សាងសង់ និង អនាម័យទឹក ( ខួងអណ្តូង ដៅចំណុចទឹក បង្កើត និង បណ្តុះបណ្តាលគណៈកម្មាការទឹក)* ( ជាភាគមួយនៃការងារជំពូក២) ។
-កសិកម្ម: *កសាង ( ស្តារប្រព័ន្ធស្រោចស្រព សាងសង់ផ្លូវលំជនបទ...)* ( ជាភាគមួយនៃការងារជំពូក២) ការផ្សព្វផ្សាយ កសិកម្ម *( ផលិត និង ពង្រីកពូជ ដំណាំរួមផ្សំ បណ្តុះបណ្តាលកសិករ ការក្រាស់កូនត្រី...)*( ជាភាគមួយនៃការងារជំពូក៣) ។
-អភិវឌ្ឍន៍សហគមន៍ *( ផ្សព្វផ្សាយ និង បណ្តុះបណ្តាល)* ។